00837079



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Aug-2012, 15:22
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៨ នាទី**

**សវនាការលើកទី៩៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា

*(Mr. Matteo CRIPPA)*

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារាវស្ឋី

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក រេយ៍ន័រ កែត

*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr. Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក ហុង គីមសួន

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី បេនី យេ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក ស្នួង ស៊ីគឿន (TCW-694) | ខ្មែរ |
| លោកស្រី ស សៀក (TCW-609) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)
សួរបន្តដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖........................................................ទំព័រ ៥

**ការសួរសំណួរទៅសាក្សី÷ លោកស្រី ស សៀក ហៅ ស៊ឹម** (TCW-609)
សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖.......................................................ទំព័រ ៥១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាដំបូងនេះលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី!**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។

លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯសាក្សី ស សៀក មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មុននឹងផ្ដល់វេទិកាជូនទៅមេធាវីដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះសម្រេចលើបញ្ហាមួយចំនួន។ ទី១ គឺសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។ លោកវេជ្ជបណ្ឌិត ដែលជាគ្រូពេទ្យពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះហើយកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំង ពេលធ្វើចលនាបន្តិចបន្តួច បត់ជើងធំ -- បត់ជើងតូចញឹកញាប់ ឈឺចង្កេះពេលអង្គុយយូរ ហើយបណ្ដាលឱ្យវិលមុខ

និងបានផ្តល់ អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោម។

[០៩:១០:៤៥]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយអាចសម្រួលទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:១១:៣៥]

ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

បាទ ជាបន្ត អង្គជំនុំជម្រះផ្តល់ ប្រគល់ភារកិច្ចជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ក្នុងនាមអង្គជំនុំជម្រះ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា កាលពីម្សិលមិញដែលពាក់ព័ន្ធនឹងការដាក់ឯកសារដេញដោលចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញលោកស្រី!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់សំណើដែលធ្វើឡើងដោយក្រុមមេធាវីការពារលោក នួន ជា ពីម្សិលមិញទាក់ទងទៅនឹងឯកសារជាក់លាក់មួយចំនួនដែលខ្លួនចង់ប្រើនៅក្នុងការសួរដេញដោលសាក្សីរូបនេះ។ ហើយឥឡូវនេះ យើងនឹងដោះស្រាយបញ្ហានេះដោយជាក់លាក់។ អង្គជំនុំជម្រះមិនមានលទ្ធភាពក្នុងការកំណត់អត្តសញ្ញាណឲ្យច្បាស់លាស់ថា ឯកសារណាមួយដែលលោកយោងទៅរកនោះទេ។ ដោយហេតុថា យើងមិនមានប្រតិចារឹក។ ដូច្នេះ យើងសូម

ឲ្យលោកកំណត់អត្តសញ្ញាណឲ្យជាក់លាក់នូវឯកសារនោះ ដែលលោកចង់ប្រើ ហើយក៏ជូនដំណឹងមកអង្គជំនុំជម្រះថាតើខ្លួនបានដាក់ ថាឯកសារនេះបានដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? នេះជាជំហានទី១។ ខ្ញុំចង់ស្តាប់ពីលោក។

[០៩:១៣:១៧]

**លោក ហ្សាស្តើ ប៉ោះ៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយយើងអាចនឹងជូនសេចក្តីលម្អិតនោះ ហើយខ្ញុំនឹងធ្វើបែបនោះតាមសំណើនៅក្នុងតុលាការ ឬក៏តាមរយៈអ៊ីម៉ែល ដើម្បីបំភ្លឺសំណើរបស់ខ្ញុំពីម្សិលមិញនោះ គឺមិនទាក់ទងទៅនឹងឯកសារតែមួយជាក់លាក់នោះទេ ដែល -- ហើយយើងសួរសំណួរទៅនឹងសំណើដែលនិយាយឯកសារទាំងអស់ដែលត្រូវលើកឡើងនៅក្នុងសវនាការ ដែលយើងកត់សម្គាល់ឃើញថា ចំពោះភាគីផ្សេងទៀត ទំនងជាមានសេចក្តីសម្រេចផ្សេង ហើយខ្ញុំបានពិនិត្យមើលប្រតិចារឹកនៃសវនាការ សួង ស៊ីគឿន។ អ្វីដែលខ្ញុំបាននិយាយម្សិលមិញនោះ គឺត្រឹមត្រូវ មិនមែនគ្រប់ពេលដែលឯកសារជូនទៅសាក្សីមិនបានសួរថាតើគាត់បានឃើញ ឬមិនបានឃើញសាក្សី -- មិនបានឃើញនោះដោយហេតុនោះ គឺថាឯកសារនោះមិនត្រូវបានដកហូតជានិច្ចទេ បើសាក្សីថាមិនឃើញ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយខ្ញុំសូមកាត់លោកត្រង់នេះ ដោយសារអង្គជំនុំជម្រះទទួលស្គាល់ថា នេះជាដែលថាលោកត្រូវការសេចក្តីបំភ្លឺ។ ឥឡូវនេះយើងនឹងនិយាយពីខ្លឹមសារទូទៅអំពីបញ្ហានេះ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការថ្ងៃស្អែក ប៉ុន្តែថ្ងៃនេះសូមឲ្យលោកបំភ្លឺពីឯកសារជាក់លាក់មួយ ដែលលោកចង់យកមកប្រើដើម្បីសួរដេញដោលសាក្សីរូបនេះនៅពេលដែលសាក្សីកំពុងវត្តមាន។ ចំណុចទី១ សួរលោកថាតើឯកសារហ្នឹងបានដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយក្រោយមក យើងនឹងត្រឡប់ទៅរកបញ្ហាឯកសារទូទៅនៅក្នុងការប្រជុំរៀបចំសវនាការនៅថ្ងៃស្អែក។

[០៩:១៥:០៦]

**លោក ហ្សាស្តើ ប៉ោះ៖**

ខ្ញុំសូមជម្រាបថា សំណើរបស់ខ្ញុំពីម្សិលមិញនេះយោងទៅរកឯកសារទាំងអស់ដែលយើងខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រើនៅពេលដែលសួរទៅសាក្សី ហើយខ្ញុំនឹងផ្តល់នូវសេចក្តីលម្អិតអំពីឯកសារទាំងអស់នោះមុនសម្រាកថ្ងៃនេះ តាមរយៈអ៊ីម៉ែល ឬក៏ជម្រាបនៅក្នុងសាលសវនាការនេះ ប្រសិនជាលោក

ស្រីចៅក្រមចង់បាន។ នេះជាការបំភ្លឺខ្ញុំជំហានដំបូង ហើយខ្ញុំអាចជម្រាបថា ឯកសារមួយ គឺ E3/ -- លើឯកសារ បាទ លេខ -- ហើយខ្ញុំបានជម្រាបថា បានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ហើយខ្ញុំរង់ចាំការសម្រេច ឬក៏ការណែនាំពីតុលាការនៅក្នុងករណីនេះ។

[០៩:១៥:៥៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

អង្គជំនុំជម្រះ គឺចង់ឲ្យលោកបំភ្លឺបញ្ហានេះ។ ដូច្នេះហើយ គឺថាដើម្បីឲ្យលោកមានឱកាសនឹងសួរទៅសាក្សីអំពីឯកសារនោះ។ ប៉ុន្តែលោកត្រូវតែជម្រាបតុលាការថា តើឯកសារនេះតែមួយ ឬក៏ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ពេលនោះ យើងអាចអនុញ្ញាតឲ្យលោកនូវពេលវេលាដើម្បីសួរសាក្សីរូបនេះដែលមានភាពពាក់ព័ន្ធ ហើយកុំឲ្យប្រើសំណួរដដែល។ ដូច្នេះត្រូវគោរពវិធាននេះ។ នៅពេលដែលលោកបានផ្តល់ព័ត៌មាននេះដល់យើង គឺថាពេលនោះគឺលោកអាចនឹងប្រើឯកសារនោះមកសួរសាក្សីរូបនេះ ដើម្បីឲ្យសមស្របទៅតាមកាលៈទេសៈទាំងអស់។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំច្បាស់ហើយ។ តាមអ្វីដែលខ្ញុំយល់ គឺថាអាចជួយដល់ភាគីទាំងអស់នៅក្នុងសវនាការនេះដែរ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា មានភាពខុសគ្នារវាង ដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះនោះហើយ។ ហើយមួយទៀត ឯកសារដែលបញ្ជាក់នៅក្នុងបញ្ជីៗរបស់ភាគីនៅក្នុងខែមេសា ឆ្នាំ២០១១។ ហើយតាមអ្វីដែលខ្ញុំយល់នោះ ឯកសារទាំងនោះ គឺថាអាចប្រើសម្រាប់យកមកជាមូលដ្ឋាននៃការតាំងសំណួរ។ ហើយខ្ញុំមិនគិតថា អង្គជំនុំជម្រះមានការបែងចែក គឺថាយល់ខុសគ្នាថា ឯកសារនៅក្នុងបញ្ជី ឬឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះហ្នឹង គឺយើងមិនច្បាស់ទេ។ ប្រហែលថា ដោយមានការឆ្លើយឆ្លងពេលនេះ គឺថាអាចនឹងឲ្យភាគីទាំងអស់បានយល់ស្របនោះហើយ។

[០៩:១៧:៤២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

គឺថាចំណុចទូទៅ យើងនឹងពិភាក្សានៅថ្ងៃស្អែក ហើយខ្ញុំមិនគិតថា អាចនឹងកើតមានឡើងទាក់ទងទៅនឹងសំណើររបស់លោក ទាក់ទងនឹងសាក្សីរូបនេះទេ។ ហើយយើងនឹងព្យាយាមដោះស្រាយប្រសិនបើមាន ហើយយើងមិនឈានទៅដល់បញ្ហាទូទៅទូលាយនោះទេ ពីព្រោះថា សំណួរសួរ -- ពេលត្រូវ

ស្តួរសាក្សីហ្នឹង គឺសំខាន់ណាស់ គឺយើងត្រូវបញ្ចប់ -- បញ្ជាក់ឲ្យច្បាស់ ហើយថាឯកសារហ្នឹង គឺឯកសារណាដែលលោកចង់ប្រើសម្រាប់សាក្សីរូបនេះ។ ហើយតាមពិត គឺថាលោកអាចនឹងត្រូវសួរសំណួរដែលពាក់ព័ន្ធ មិនសួរសំណួរដដែល។ ពេលនោះ អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកប្រើ ដើម្បីសួរ។

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកស្រីចៅក្រម។

[០៩:១៨:៣១]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្នួង ស៊ីគឿន។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ ហើយនិងសាធារណជន ហើយជម្រាបសួរលោកសាក្សី។

ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា យើងសូមអរគុណចំពោះការបំភ្លឺ ហើយនិងសេចក្តីសម្រេចក្នុងការអនុញ្ញាតឲ្យយើងខ្ញុំជាមេធាវីការពារដូចជាសហព្រះរាជអាជ្ញាដែរ ដើម្បីពិនិត្យមើលបញ្ហានេះឡើងវិញ។

**សួរបន្តដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំចាប់ផ្តើមពីចំណុចដែលយើងឈប់ពីម្សិលមិញ យើងនិយាយអំពីរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ យើងមើលប្រតិចារឹកនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ នៅពេលដែលមានសំណួរមួយចំនួនដែលគេសួរលោកទាក់ទងទៅនឹងទីភ្នាក់ងារសារព័ត៌មានកម្ពុជា ដែលខ្ញុំយល់សក្ខីកម្មរបស់លោកនោះ ពីឆ្នាំ១៩៧០ ដល់៧៤ លោកតំណាងឲ្យនៅប្រទេសចិន ហើយនិងកន្លែងផ្សេងទៀត។ តើត្រូវដែរឬទេ?

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ជាបឋម សូមគោរពលោកប្រធាន សូមគោរពបងៗ និងសូមគោរពអង្គសវនាការទាំងមូល។ បាទគឺថា អ្វីដែលលោកមេធាវីបានមានប្រសាសន៍អំមិញហ្នឹង គឺថាត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទាក់ទងទៅនឹងបញ្ហានេះ។ តើអ្នកណាជាអ្នកតែងតាំងលោកឲ្យធ្វើការងារក្នុងតំណែងនេះ?

**ឆ៖** គឺលោក អៀង សារី ជា -- បានតែងតាំងខ្ញុំ ឲ្យខ្ញុំធ្វើជាតំណាងទីភ្នាក់ងារ អា.កា.អ៊ីសារព័ត៌មានខ្មែរ អា.កា.អ៊ី ប្រចាំប្រទេសចិនបាទ។

[០៩:២១:០២]

**ស៖** តើលោកនៅទីណានៅពេលដែលលោកទទួលការតែងតាំងនេះ? បាទ លោកនៅកន្លែងណានៅពេលដែលលោកទទួលការតែងតាំងនេះ?

**ឆ៖** ខ្ញុំស្ថិតនៅអគារ ស្ថិតនៅ គេហៅ សណ្ឋាគារមិត្តភាពនៅទីក្រុងប៉េកាំង ក្នុងបរិវេណអគារនៃទីស្តីការរដ្ឋមន្ត្រី រដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** បាទ ហើយខ្ញុំសូមសួរថាតើហេតុអ្វីបានជាលោកទៅប៉េកាំង លោកនៅកាលនោះ ពីព្រោះថាលោកជានិស្សិតនៅប៉ារីស? តើលោក -- ហេតុអ្វីបានជាលោកទៅប៉េកាំង?

**ឆ៖** ពេលនោះ ខ្ញុំជាប្រធានសហភាពនិស្សិតខ្មែរ នៅប្រទេសបារាំង ហើយសមាជិកទាំងអស់របស់សហភាពនេះ បានគាំទ្រសេចក្តីប្រកាសរបស់សម្តេច នរោត្តម សីហនុ ចុះថ្ងៃទី២៣ ខែមីនា ១៩៧០ ហើយបានបញ្ជូនខ្ញុំឲ្យទៅថ្វាយចំពោះព្រះអង្គ នូវសេចក្តីគាំទ្ររបស់និស្សិតខ្មែរនៅប្រទេសបារាំង ចំពោះការតស៊ូរបស់ព្រះអង្គបាទ។

**ស៖** ហើយខ្ញុំសួរតទៅទៀត តើអ្នកណាជាអ្នកត្រួតត្រា ឬក៏អ្នកគ្រប់គ្រងទីភ្នាក់ងារសារព័ត៌មានកម្ពុជា សម្តេច ឬក៏រណសិរ្ស ឬក៏លោក អៀង សារី តើអ្នកជាអ្នកគ្រប់គ្រងទីភ្នាក់ងារព័ត៌មានកម្ពុជានេះ?

**ឆ៖** អ្វីដែលខ្ញុំដឹងគឺ ផ្នែកតស៊ូក្នុងប្រទេសជាអ្នកគ្រប់គ្រង មិនមែនសម្តេចព្រះ នរោត្តម សីហនុ ឬមិនមែនរណសិរ្សនៅក្រៅប្រទេស ដែលជាអ្នកគ្រប់គ្រងបាទ។

[០៩:២៣:៣៦]

**ស៖** តើសម្តេច គឺថាបានប្រើ -- អាចប្រើព័ត៌មាននេះទេ ប្រសិនជាព្រះអង្គចង់នោះ តាមដែលលោកដឹង?

**ឆ៖** គឺប្រាកដណាស់ហើយបាទ ក្នុងឋានៈព្រះអង្គជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ព្រះអង្គអាចនឹងប្រើប្រាស់អង្គការរដ្ឋអ្វីៗ ដែលនៅក្រោមឱវាទរបស់រណសិរ្ស ហើយដែលរួមតស៊ូនៅក្នុងក្របខ័ណ្ឌ

រណសិរ្សរួបរួមជាតិកម្ពុជាបាទ។

**ស៖** នៅពេលដែលថា នៅក្នុងក្របខ័ណ្ឌតើមានន័យថា ព័ត៌មានទាំងអស់នេះត្រូវបានពិនិត្យផ្ទៀងផ្ទាត់មុនផ្សាយ ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំសូមជម្រាបថា ព័ត៌មានដែលខ្ញុំទទួលពីក្នុងប្រទេសមក ព័ត៌មាននៃសារព័ត៌មានកម្ពុជាហ្នឹង គឺខ្ញុំទទួលពីក្នុងប្រទេសមកតាមរយៈស្ថានទូត សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ប្រចាំទីក្រុងប៉េកាំងបាទ។ ត្រង់តែថា គេផ្ញើ អ្នកណាផ្ញើអីតាមរបៀបណា ខ្ញុំមិនបានដឹងទេបាទ។

[០៩:២៥:០៨]

**ស៖** សូមលោកជួយបំភ្លឺឱ្យច្បាស់នៅពេលមួយនោះ គឺសម្តេចមិនបានយាងទៅប៉េកាំងទេ បន្ទាប់ពីរដ្ឋប្រហារ ព្រះអង្គមិនបានគង់នៅទីនោះទេ?

**ឆ៖** ទេ តាមខ្ញុំដឹងគឺព្រះអង្គពេលនោះ ព្រះអង្គធ្វើទស្សនកិច្ចនៅសហភាពសូវៀត ហើយព្រះអង្គទ្រង់ជ្រាបអំពីដំណឹងអំពីរដ្ឋប្រហារនេះ នៅពេលដែលព្រះអង្គចាកចេញពីទីក្រុងម៉ូស្គូមកប្រទេសចិនមកប៉េកាំង ហើយអ្នកដែលជម្រាបហ្នឹងគឺថា ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទី១ នៃសហភាពសូវៀតលោក អាឡិចស៊ី កូស៊ីគីន តាមខ្ញុំ បើខ្ញុំមិនច្រឡំទេបាទ។

**ស៖** ប៉ុន្តែបន្ទាប់ពីនោះមក លោកនិយាយថា លោកនៅប៉េកាំងចាប់ពីឆ្នាំ១៩៧០ ដល់ ៧៤ បន្ទាប់ពីនោះមក សម្តេចមិនបានយាងទៅគង់នៅប៉េកាំងទេ នៅពេលដែលព្រះអង្គជាប្រមុខរបស់រណសិរ្សរួបរួមជាតិកម្ពុជា លោកបានបញ្ជាក់បែបនេះកាលពីម្សិលមិញ?

**ឆ៖** ទេ ខ្ញុំដូចព្រះអង្គនៅប៉េកាំងហ្នឹង ព្រោះខ្ញុំបាន -- នៅថ្ងៃដែលខ្ញុំទៅប៉េកាំងហ្នឹង ព្រះអង្គ -- ខ្ញុំបានចូលគាល់ព្រះអង្គ ដើម្បីថ្វាយសេចក្តីគាំទ្ររបស់និស្សិត និងបញ្ញាជនខ្មែរយើងនៅប្រទេសបារាំងចំពោះរណសិរ្សរបស់ការតស៊ូរបស់ព្រះអង្គហ្នឹង គឺថា ព្រះអង្គគង់នៅប៉េកាំងពីឆ្នាំ--

**ស៖** ខ្ញុំសូមអនុញ្ញាតឱ្យលោកបញ្ឈប់សិន ពីព្រោះខ្ញុំសួរសំណួរឱ្យច្បាស់ ប្រហែលជាមានការបកប្រែច្រឡំ ហើយខ្ញុំសួរលោកថា នៅពេលដែលលោកនៅប៉េកាំងលោកប្រាប់ថា លោកនៅទីនោះចាប់ពីឆ្នាំ៧០ ដល់ ៧៤ នៅក្នុងពេលនោះ តើព្រះអង្គ -- សម្តេចនោះ គង់នៅទីនេះដែរឬក៏មិននៅ? ខ្ញុំដឹងថា នៅពេលដែលព្រះអង្គធ្វើដំណើរហ្នឹង ខ្ញុំនឹងសួរ ប៉ុន្តែនៅក្នុងសម័យពី៧០ ដល់៧៤ ព្រះអង្គគង់នៅទីនោះដែរឬទេ?

[០៩:២៧:៣៣]

**ឆ៖** បាទ ខ្ញុំៗច្បាស់ហើយ គឺថាពីឆ្នាំ៧០ ដល់ ៧៤ -- ១៩៧០ ដល់១៩៧៤ ព្រះអង្គគង់នៅប៉េកាំង លើកលែងតែមួយខែ តាមដែលខ្ញុំចាំនៅខែមីនា ឆ្នាំ១៩៧៣ ដែលព្រះអង្គយាងចូលមកក្នុងប្រទេសដោយមានលោក អៀង សារី អមដំណើរផងបាទ។

**ស៖** បាទ សូមអរគុណ។ នេះហើយជាចំណុចដែលខ្ញុំឲ្យលោក -- ចង់ឲ្យលោកបញ្ជាក់ ហើយខ្ញុំសួរថា លោកចង្អុលបង្ហាញថា លោកបានទទួលព័ត៌មានមកពីខាងក្នុង។ ហើយខ្ញុំសួរសំណួរអំពីសម្តេចដែលថា តើព្រះអង្គអាចប្រើព័ត៌មាន ទីភ្នាក់ងារព័ត៌មានហ្នឹងបានឬអត់ ដែលលោកជាអ្នកទទួលខុសត្រូវ? សំណួររបស់ខ្ញុំចំពោះលោកគឺថា ក្នុងសម័យដែលសម្តេចនៅទីក្រុងប៉េកាំង ហើយលោកក៏នៅទីនោះដែរ តើព្រះអង្គអាចបញ្ជូនសាររបស់ព្រះអង្គផ្ទាល់ ឬក៏ត្រូវពិនិត្យជាមុនសិនអំពីវិសាលភាព ថាតើមានការកម្រិតជាវិសាលភាពអ្វីទេ មុននឹងបញ្ជូនទៅឲ្យទីភ្នាក់ងារ អា.កា.អ៊ី នេះ?

[០៩:២៩:០៣]

**ឆ៖** ខ្ញុំមិនបានចាំច្បាស់ទេ ប៉ុន្តែខ្ញុំអាចជម្រាបថា ពេលទន្ទឹមនឹងខ្ញុំជាតំណាងទីភ្នាក់ងារ អា.កា.អ៊ី ហ្នឹងខ្ញុំក៏ជាប្រធានការិយាល័យព័ត៌មាន នៃរណសិរ្សរួបរួមជាតិប្រចាំទីក្រុងប៉េកាំងដែរ។ ហើយជាធម្មតាគឺបើព្រះអង្គមានសារអី គឺខ្ញុំផ្សាយសារហ្នឹងនៅក្នុងព្រឹត្តិបត្រៗប្រចាំអាទិត្យ ហើយក្រោយមកព្រឹត្តិបត្រហ្នឹងចេញពីរអាទិត្យ -- ពីរដងក្នុងមួយអាទិត្យ។ បាទ ខ្ញុំនឹងផ្សាយថ្វាយព្រះអង្គនៅក្នុងព្រឹត្តិបត្ររបស់ខ្ញុំបាទ។ អាហ្នឹងខ្ញុំអាចជម្រាបអ៊ីចឹងបាន ប៉ុន្តែត្រង់ អា.កា.អ៊ី ហ្នឹងខ្ញុំមិនបានចាំថាព្រះអង្គបានប្រើប្រាស់ ឬបានមានអ្វីទាក់ទងជាមួយ អា.កា.អ៊ី ទេ ព្រោះ អា.កា.អ៊ី វានៅខាងក្នុងប្រទេស។ ដូច្នោះការ--

[០៩:៣០:០២]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅចំណុចមួយទៀត ដើម្បីសន្សំពេលវេលា តាមអ្វីដែលខ្ញុំយល់សក្ខីកម្មរបស់លោក ហើយនិងរបស់អ្នកផ្សេងទៀត លោកបានអមដំណើរសម្តេចទៅប្រទេសរ៉ូម៉ានី តើលោកនៅចាំដែរឬទេ ប្រហែលជានៅក្នុងទសវត្សរ៍ឆ្នាំ៧០?

**ឆ៖** បាទ ខ្ញុំចាំបាទ។ ឆ្នាំ តាមខ្ញុំនេះដូចឆ្នាំ១៩៧៣។

**ស៖** មូលហេតុដែលខ្ញុំសួរនោះគឺថា លោកបានបញ្ជាក់ថា ហើយលោកក៏បានទៅប៉ុយការ៉េសឆ្នាំ១៩៩៤ គឺមានដំណើរច្រើនជាងមួយទៅរ៉ូម៉ានីជាមួយព្រះអង្គ តើដំណើរម្តងឬក៏ច្រើនដង?

**ឆ៖** តាមខ្ញុំចាំ ខ្ញុំទៅរ៉ូម៉ានីហ្នឹងតែរួមដំណើរទស្សនកិច្ចជាមួយព្រះអង្គ ព្រះបាទនរោត្តម សីហនុ

នៅឆ្នាំ១៩៧៣ ហើយខ្ញុំទៅរ៉ូម៉ានីម្តងទៀតនៅឆ្នាំ១៩៧៤ ពេលនេះខ្ញុំជាជំនួយការរបស់គណៈប្រតិភូដែលដឹកនាំដោយលោកខៀវ សំផន ហើយដែលមានលោក អៀង សារី ចូលរួមផងដែរបាទ។

[០៩:៣១:៣៣]

**ស៖** មូលហេតុដែលខ្ញុំចង់សួរនោះគឺថា អនុលោមតាមលោកដេវីដ ឆេនដ័ល័រ សក្ខីកម្មរបស់គាត់នៅក្នុងសាក្សីមួយទៀតដែលបានបង្ហាញខ្លួន គឺអុង ថុងហឿង ដំណើរនោះគឺនៅក្នុងឆ្នាំ១៩៧៤ នៅពេលដែលលោកអៀង សារី ហើយនិងសម្តេចនៅទីក្រុងៗប៊ុយការ៉េស តើអាចទេ ដែលថាលោក -- ហើយថាលោកមិនចាំកាលបរិច្ឆេទ ដែលតាមពិតគឺឆ្នាំ១៩៧៤ ទេ មិនមែន១៩៧៣ តើលោកអាចខុសទេពីការចងចាំនេះ?

**ឆ៖** ខ្ញុំមិនៗខុសទេ ព្រោះគណៈប្រតិភូវាពីរ ហើយខុសគ្នា។ គណៈប្រតិភូមួយដឹកនាំដោយសម្តេច នរោត្តម សីហនុ ហើយពេលនុ៎ងលោក ខៀវ សំផន គាត់នៅក្នុងប្រទេស គឺនៅឆ្នាំ១៩៧៣។ ព្រោះខ្ញុំចូលរួមទាំងពីរហ្នឹង ហើយខ្ញុំមិនចាំទេលោក -- ខ្ញុំមិនភ្លេចទេលោកមេធាវី។ ហើយនៅឆ្នាំ១៩៧៤ ខ្ញុំក៏ត្រឡប់ទៅប៊ុយការ៉េស ប្រទេសរ៉ូម៉ានីវិញ ក្នុងឋានៈក្នុងគណៈប្រតិភូពីខាងក្នុងប្រទេស ដែលដឹកនាំដោយលោកខៀវ សំផន។ អ្នកផ្សេងអាចភ្លេច ប៉ុន្តែខ្ញុំខ្លួនខ្ញុំផ្ទាល់អត់ភ្លេចទេបាទ។ លោកចង់ដឹង គឺថាខ្ញុំជាអ្នកប្រវត្តិសាស្ត្រ រឿងថ្ងៃខែខ្ញុំមិនសូវភ្លេចទេបាទ។

**ស៖** បាទនៅក្នុងដំណើរនោះ ក្នុងឆ្នាំ១៩៧៤ តើសម្តេចនៅទីនោះជាមួយលោក អៀង សារី ដែរឬទេ? តើលោកចាំដែរឬទេ?

**ឆ៖** ខ្ញុំដឹងថា នៅឆ្នាំ១៩៧៣ នេះគឺលោក អៀង សារី ក៏បានធ្វើដំណើរ--

[០៩:៣៣:៣៨]

**ស៖** លោកសាក្សីសូមបញ្ឈប់! ខ្ញុំមិននិយាយពីឆ្នាំ១៩៧៤។ សំណួរគឺច្បាស់ណាស់ ពេលវេលាខ្ញុំមានកម្រិតណាស់។ ខ្ញុំមិនចង់ឲ្យលោកយល់ថា ខ្ញុំ--ប៉ះពាល់អារម្មណ៍លោកទេ ប៉ុន្តែខ្ញុំនិយាយពីដំណើរឆ្នាំ១៩៧៤ ទៅប៊ុយការ៉េស។ តើលោក អៀង សារី អមដំណើរជាមួយសម្តេច សីហនុ ដែរទេ? បើលោកចាំលោកឆ្លើយថា ចាំ បើមិនចាំខ្ញុំសួរទៅមុខទៀត។

**ឆ៖** លោកមេធាវីចង់ចំណេញពេល ប៉ុន្តែមែនទែនធ្វើឲ្យខាតពេល ខ្ញុំមិនដឹងឆ្លើយហ្នឹង។ ថាខ្ញុំក្នុងពេលដែលខ្ញុំនៅអមដំណើរគណៈប្រតិភូហ្នឹង លោក អៀង សារី នៅជាមួយខ្ញុំដែរ មានបីនាក់ ពីខាងក្នុង គឺថាជាមួយលោក អ៊ិន សុភាព។ ដូច្នោះ នៅឆ្នាំ១៩៧៣ មិនមែន៧៤ ទេ។ ខ្ញុំចង់ប្រាប់ ចង់ជម្រាប

00837092



ប៉ុណ្ណឹងបាទ។

[០៩:៣៤:៣៤]

**ស៖** សំណួររបស់ខ្ញុំ តើសម្ដេច នរោត្តម សីហនុ នៅទីនោះជាមួយលោកដែរឬទេ? នេះជាសំណួរ តើលោកនៅចាំដែរឬទេ?

**ឆ៖** លោកមេធាវីថា សូមបញ្ជាក់អំពីឆ្នាំ។ ឆ្នាំ១៩៧៣ ឬ៧៤?

**ស៖** ខ្ញុំនិយាយឆ្នាំ១៩៧៤ នៅក្នុងសក្ខីកម្មរបស់លោកថា -- ហើយ អុង ថុងហឿង និយាយថា ឆ្នាំ១៩៧៤ ដែលលោកទៅ -- ដែលគាត់ទៅប៉ិយការ៉េស គាត់ជួបសម្ដេច ហើយនិងលោក អៀង សារី។ ហើយក៏បញ្ជាក់នៅក្នុងសៀវភៅ ដេវីដ ឆេនដ័ល័រ ដែរ ប្រហែលជាពួកគាត់ចាំកាលបរិច្ឆេទខុស ឬក៏អាចលោកខុស។ ដូច្នេះហើយដែលខ្ញុំចង់បានអង្គហេតុនោះឲ្យត្រឹមត្រូវ។ ដូច្នេះហើយបានខ្ញុំចង់សួរសំណួរលោកពីបញ្ហានេះនោះ។

**ឆ៖** ខ្ញុំជម្រាបលោកថា នៅឆ្នាំ១៩៧៤ លោក អៀង សារី មិនអាចនៅជាមួយសម្ដេច នរោត្តម សីហនុ ទេ ព្រោះគាត់នៅជាមួយគណៈប្រតិភូ ដឹកនាំដោយលោក ខៀវ សំផន ហើយខ្ញុំនៅក្នុងគណៈប្រតិភូហ្នឹងដែរ។ បើឆ្នាំ១៩៧៣ អាហ្នឹងគាត់ ព្រោះខ្ញុំនៅជាមួយសម្ដេច នរោត្តម សីហនុ ហើយលោក អៀង សារី ក៏នៅជាមួយខ្ញុំដែរ ឬថាៗខ្ញុំនៅជាមួយលោក អៀង សារី ដែរបាទ។ ដូច្នេះនៅឆ្នាំ១៩៧៣ ដែលលោក អៀង សារី មានវត្តមានព្រមជាមួយគ្នានឹងសម្ដេចព្រះនរោត្តម សីហនុ បាទ។ សូមជម្រាបលោកមេធាវី ហើយបើលោកមេធាវីជឿខ្ញុំក៏ជឿទៅ បើជឿអ្នកផ្សេងទៀតក៏ជឿទៅ។ ហើយទៅមើលទៅសួរនៅរ៉ូម៉ានីហ្នឹងដឹងហើយ។

[០៩:៣៦:៣២]

**ស៖** សូមអរគុណសាក្សី។ ឥឡូវនេះនិយាយអំពីឆ្នាំ១៩៧៣ ម្ដងទៀត។ លោកចាំអំពីសារនៅក្នុងកិច្ចនៅទីក្រុងប៉ុយការ៉េស។ តើសារអ្វីដែលនៅទីនោះ ដែលសម្ដេច នរោត្តម សីហនុ បានមានព្រះឱង្ការនៅក្នុងកិច្ចប្រជុំនោះ?

**លោក សួង ស៊ីគឿន៖**

លោកប្រធានសូមៗ ឲ្យលោកមេធាវីបញ្ជាក់បន្តិច។ សួរឲ្យច្បាស់បន្តិច ព្រោះប្រជុំវាច្រើន មិនមែនប្រជុំ -- ព្រោះខ្ញុំមិនមែនជាអ្នកនេះទេ ប្រជុំខ្លះខ្ញុំចូលរួម ប្រជុំខ្លះខ្ញុំអត់បានចូលរួមទេបាទ។ សូមបញ្ជាក់ពីប្រជុំហ្នឹង ប្រជុំស្អី បាទ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកបានចូលរួមការប្រជុំណាមួយដែរទេ ដែលសម្តេច សីហនុ បានថ្លែងនៅក្នុងប្រជុំនោះ បើសិនលោកចាំ?

[០៩:៣៧:៤៩]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំបានចាំថា ពេលមួយនោះ នៅប្រេឌីអាល់ៗ នៅក្នុងជួរភ្នំកាប៉ាតហ្នឹង នៅប្រទេសរ៉ូម៉ានីហ្នឹង សម្តេចព្រះ នរោត្តម សីហនុ ត្រូវសម្ភាសដោយលោក អង់រី ខាន់។ លោក អង់រី ខាន់ ជាកាសែតរបស់ *អ៊ុនទែរណាស់ស្យូណាល់ ទ្រីប៊ូន* បាទ ហើយពេលនោះខ្ញុំ និងលោក អៀង សារី ក៏នៅទីនោះដែរ ដែលខ្ញុំចាំមានប្រជុំដែលមានលោក អៀង សារី ហើយនិងព្រះអង្គ -- ព្រះនរោត្តម សីហនុ ហើយនិងខ្ញុំនៅជាមួយគ្នា។ ខ្ញុំចាំបានកន្លែងហ្នឹងបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងមើល ទុកការសម្ភាសនោះនៅមួយឡែកសិន។ តើលោកបានចូលរួមក្នុងការប្រជុំរវាងសម្តេច សីហនុ ហើយនិងៗ និស្សិតកម្ពុជាដែលមកទីក្រុងប៉ារីសដែលទៅជុំគ្នានៅកន្លែងនោះដែរឬទេ?

[០៩:៣៨:៥៥]

**ឆ៖** ខ្ញុំមិនបាន -- ខ្ញុំសូមជម្រាបថា ខ្ញុំពេលដែលអមទៅគណៈប្រតិភូសម្តេចនេះ ខ្ញុំនៅក្រុមជាមួយលោក អៀង សារី។ ក្នុងហ្នឹងមានលោក អ៊ិន សុភាព ដែរ មានបីនាក់។ ដូច្នេះ អ្វីដែលទាក់ទងជាមួយនឹងសម្តេច--

**ស៖** សូមអភ័យទោស! ចម្លើយទៅនឹងសំណួរខ្ញុំ ទេ ឬៗក៏មែន។ តើលោកវត្តមាននៅក្នុងកិច្ចប្រជុំនោះដែរឬទេ?

**លោក សួង ស៊ីគឿន៖**

លោកប្រធាន ខ្ញុំសូមកុំឧស្សាហ៍កាត់ខ្ញុំ។ ជួនកាលខ្ញុំរៀបឆ្លើយទៅគាត់ គាត់កាត់ខ្ញុំទៅ ខ្ញុំបាត់ខ្សែគំនិតខ្ញុំបាត់ហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបសម្រួលរបៀបក្នុងការតាំងសំណួរដេញដោល ចៀសវាងធ្វើឱ្យដាក់សម្ពាធទៅលើសាក្សី នាំឱ្យសាក្សីអាចមានការតប់ប្រមល់ក្នុងអារម្មណ៍ អាច -- មិនអាចឆ្លើយតបបានទេ។ ទី២

ក្នុងការតាំងសំណួរ សូមៗឲ្យលោករៀបចំឲ្យបានត្រឹមត្រូវ សំណួរបាទ ឬទេនេះ យើងបានជម្រាបហើយ ថានៅក្នុងប្រព័ន្ធនៃការសួរដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ អង្គជំនុំជម្រះបានចេញលិខិតជម្រាបជូនរួចហើយថា ប្រើប្រាស់អនុវត្តតាមស៊ីវិលឡ គឺមិនគប្បីប្រើប្រាស់ក្នុងការតាំងសំណួរបែបនាំមុខ ឲ្យឆ្លើយបាទ ឬក៏ទេនោះទេ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនសួរសំណួរនាំមុខទេ ប៉ុន្តែខ្ញុំសូមអនុញ្ញាតដើម្បីកាត់ ដើម្បីជាគាត់ -- ពេលដែលគាត់ឆ្លើយ មិនឆ្លើយតបនឹងសំណួររបស់ខ្ញុំ ប៉ុន្តែខ្ញុំសួរឡើងវិញ។

[០៩:៤០:៤៨]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកសាក្សី តើលោកបានចូលរួមការប្រជុំណាមួយនៅប៉ុយការ៉េស ដែរឬទេ ដែលសម្តេច នរោត្តម សីហនុ មានព្រះឱង្ការទៅនិស្សិតខ្មែរដែលមកពីទីក្រុងប៉ារីសមកគាល់ព្រះអង្គ ឬក៏មកជួបគណៈប្រតិភូណាផ្សេងទៀតនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំដូចមិនចាំ ពេលដែលខ្ញុំបានចូលរួម ព្រោះជាមួយនឹងនិស្សិត ជាមួយនឹងសម្តេច នរោត្តម សីហនុ ពីព្រោះមិនមាននាទីខ្ញុំទេ។ ប៉ុន្តែខ្ញុំអាចជម្រាបថា បើលោក អៀង សារី គាត់ទទួលនិស្សិតមកពីប្រទេសបារាំងនៅរ៉ូម៉ានី អាហ្នឹងខ្ញុំបានចូលរួមបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះចូលទៅទំព័រ៨៣ ទំព័រខ្មែរ 00831427, បារាំង 00382814 ដល់ 15, អង់គ្លេស 00832700 នេះនៅក្នុងថ្ងៃទី២ ខែសីហា សវនាការ។ ហើយលោកបានឆ្លើយសំណួរដែលភាគី ឬក៏ចៅក្រមសួរលោកទាក់ទងទៅនឹងផ្នែកមួយ ហើយខ្ញុំចង់ឲ្យលោកបំភ្លឺ៖ "តាមខ្ញុំយល់គឺកម្លាំងសម្តេច សីហនុ ហ្នឹងហើយគឺជាកម្លាំងយុទ្ធវិធី ប៉ុន្តែកម្លាំង -- គឺបក្សកុម្មុយនីស្តកម្ពុជា ជ្រើសរើសបុគ្គល ជាបុគ្គលមួយចំនួនឲ្យចូលរួមតាំងពីដំបូងដល់ទីបញ្ចប់។ នោះគឺជាក្រុមយុទ្ធវិធី។ ប៉ុន្តែជាកម្លាំងបន្ទាប់បន្សំទេ ប៉ុន្តែឋានៈជាបុគ្គលគឺមានបុគ្គលខ្លះធ្វើដំណើរទៅឆ្ងាយដែរបាទ។ ហើយគេចាត់ទុកថា ជាកងកម្លាំងរយៈពេលវែងសម្រាប់ចលនានេះ"។

[០៩:៤២:៤៩]

ឥឡូវនេះ លោកពន្យល់សេចក្តី -- បានពន្យល់អំពីយុទ្ធសាស្ត្រ និងយុទ្ធវិធី។ តើនៅពេលនេះ

តើកម្លាំងយុទ្ធវិធី និងកម្លាំងយុទ្ធសាស្ត្រហ្នឹងយ៉ាងដូចម្ដេចបាទ?

**លោក ស្វង ស៊ីគឿន៖**

ខ្ញុំ -- លោកប្រធាន ខ្ញុំដូចបានឆ្លើយនឹងសំណួរហ្នឹងម្ដងហើយបាទ។ តើខ្ញុំមានភារកិច្ចឆ្លើយម្ដងទៀតទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមមេធាវីបន្តសំណួរថ្មី ពីព្រោះសំណួរនេះជាសំណួរច្រំដែល។

**លោក ម៉ែខល កាណាវាស៖**

បាទ ដើម្បីកំណត់ត្រាតុលាការ ប្រធានបទខុសគ្នា ប៉ុន្តែខ្ញុំនឹងទៅមុខទៀតបាទ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំសូមចូលទៅដល់កាលបរិច្ឆេទដដែល ខ្មែរ 00831431, បារាំង 00832820, អង់គ្លេស 00832705។ នៅកន្លែងនេះគឺមានសំណួរមួយទៅលោក ហើយលោកឆ្លើយថា៖ “ខ្ញុំបានទៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧០ នៅខែឧសភា អមដំណើរសម្ដេច នរោត្ដម សីហនុ នៅពេលដែលព្រះអង្គជាប្រធាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ធ្វើទស្សនកិច្ចនៅវៀតណាម”។ ខ្ញុំសូមបញ្ឈប់ត្រឹមនេះ។

ជាបឋមតើលោកចាំដែរឬទេ ថាបានឆ្លើយបែបនេះ? តើលោកប្រកាន់ចម្លើយនេះដដែល ឬក៏យ៉ាងម៉េច?

[០៩:៤៥:១៧]

**លោក ស្វង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំប្រកាន់ចម្លើយដដែលបាទ។

**ស៖** តើលោកអាចជម្រាបខ្ញុំបានទេ តើដោយប្រាជកនោះ អ្វីជាគោលបំណងនៃដំណើរទស្សនកិច្ចទៅវៀតណាមក្នុងឆ្នាំ១៩៧០ ប្រសិនបើលោកដឹង?

**ឆ៖** ពេលនោះ គឺនៅខែឧសភា ដូច្នោះរាជរដ្ឋាភិបាល -- រណសិរ្សរួបរួមជាតិកម្ពុជាទើបនឹងបានបង្កើត ហើយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាក៏ទើបបានបង្កើតដែរ។ ហើយប្រទេសដែលគាំទ្ររណសិរ្ស និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ពេលនោះគាំទ្រភ្លាមហ្នឹង គឺមានសាធារណរដ្ឋប្រជា

មានិតចិន ហើយមានសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ដូច្នោះ ជាកាតព្វកិច្ចរបស់ព្រះអង្គ ព្រះអង្គទៅថ្លែងអំណរគុណចំពោះអ្នកដឹកនាំវៀតណាមនៅពេលនោះ ចំពោះការគាំទ្ររបស់ប្រជាជនវៀតណាម និងរដ្ឋអំណាចវៀតណាម ដល់ការតស៊ូរបស់ប្រជាជនកម្ពុជាបាទ។

**ស៖** តើលោកបានចូលរួមក្នុងកិច្ចប្រជុំមួយដែលព្រះអង្គមានព្រះឱង្ការនោះទេ?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំអាចជម្រាបថា ខ្ញុំមិនបានចូលរួមប្រជុំទាំងអស់ទេ ប៉ុន្តែចូលរួមដូចជាមីទិង អបអរសាទរគណៈប្រតិភូកម្ពុជាអី អាហ្នឹងខ្ញុំបានចូលរួមបាទ។ ប៉ុន្តែចូលរួមប្រជុំជាមួយអ្នកដឹកនាំវៀតណាម ខ្ញុំមិនបានចូលរួមទេ ព្រោះពេលនោះខ្ញុំសមាជិកគណៈប្រតិភូក្នុងឋានៈខ្ញុំជាតំណាងនិស្សិតដែលមកពីប្រទេសបារាំងបាទ។ ព្រោះមានតំណាងនិស្សិតមកពីសហភាពសូវៀតក៏បានចូលរួមហើយ បាទពេលនោះ។

**ស៖** សូមអរគុណ។ តើលោកនៅចាំដែរឬទេ តើមានយុទ្ធវិធី -- តើមានការប្រជុំយុទ្ធវិធីយុទ្ធសាស្ត្រអ្វីទេ ឬក៏មានការប្រជុំដែលនិយាយពីយុទ្ធវិធី យុទ្ធសាស្ត្រដែរឬទេ? ថាតើវៀតណាមអាចជួយអ្វីខ្លះដល់រណសិរ្សនោះដែរឬទេ?

[០៩:៤៧:៥៨]

**ឆ៖** ខ្ញុំមិនបានចូលរួមក្នុងប្រជុំរបៀបនេះទេ ហើយខ្ញុំក៏ខ្ញុំមិនបានដឹងអំពីខ្លឹមសារនៃការប្រជុំហ្នឹងដែរបាទ។ ខ្ញុំគ្រាន់ជម្រាបថា អ្នកដឹកនាំវៀតណាមបានទទួលសម្តេច នរោត្តម សីហនុ យ៉ាងកក់ក្តៅជាភាតរភាពខ្លាំងក្លាណាស់បាទ។ គឺពេលដែលជប់លៀងអី គឺបទភ្លេងចម្រៀងរបស់សម្តេច ខាងវៀតណាមគេបានច្រៀង បានផ្តុំឲ្យគណៈប្រតិភូយើងស្តាប់ទាំងអស់បាទ។ ខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** សូមអរគុណច្រើន។ ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ចំណុចមួយដើម្បីឲ្យលោកបំភ្លឺ ខ្មែរ 00831437, បារាំង 00832826, អង់គ្លេស 00832711 ហើយខ្ញុំនឹងចូលទៅដល់រហូតទៅដល់ 12 ខាងចុង។ ឥឡូវនេះ គឺថាលោកនិយាយថាលោកទទួលខុសត្រូវអំពីព័ត៌មានអន្តរជាតិ ដំណឹងអន្តរជាតិនៅពេលដែលលោកនៅទីក្រុងហាណូយ ហើយមានសំណួរសួរទៅលោកថា “តើ អៀង សារី និង ខៀវ សំផន ផ្តល់ការណែនាំអ្វីដល់លោកទេ?” ហើយលោកនិយាយថា “មិនមានទេ គឺមិនស្ថិតនៅក្រោមអំណាចរបស់ពួកគាត់ទេ”។ ខ្ញុំសូមសួរលោក ថាតើអ្នកណាជាអ្នកផ្តល់ការណែនាំដល់លោកក្នុងការធ្វើការងារនោះ?

[០៩:៤៩:៥៥]

**ឆ៖** ខ្ញុំទទួលការណែនាំផ្ទាល់ពីលោកស្រី អៀង ធីរិទ្ធ ដែលគាត់ជាប្រធានសំឡេងសហ -- សំឡេងរួបរួមជាតិកម្ពុជា -- រណសិរ្សរួបរួមជាតិកម្ពុជា។

**ស៖** ខ្ញុំកត់សម្គាល់ទៅនេះ លោកបាននិយាយថា លោកសរសេរអត្ថបទ ហើយចាក់ផ្សាយ ហើយគាត់ជាអ្នកពិនិត្យមើល។ តើនេះផ្អែកលើការណែនាំអំពីអ្វីដែលត្រូវសរសេរឬ? ឬក៏លោកមានសេរីភាពក្នុងការសរសេរខ្លឹមសារដែលកាលនោះ គេអាចយកទៅពិនិត្យ ហើយនិងផ្តល់ការឯកភាពមុននឹងផ្សាយនោះ?

**ឆ៖** មិនមានការណែនាំឱ្យសរសេរ ព្រោះដំណឹងពីការដូចថាសកម្មភាពនៅក្រៅប្រទេសគាំទ្រការតស៊ូរបស់រណសិរ្សរួបរួមជាតិកម្ពុជា វាមានច្រើន ប្រភពព័ត៌មានមានច្រើន គឺថាគ្រាន់តែជ្រើសរើសទៅ ឆ្លង -- ទៅឆ្លងលោកស្រី អៀង ធីរិទ្ធ ទៅ។ គាត់សម្រេច ហើយគាត់ផ្សាយទៅបាទ។

[០៩:៥១:១៨]

**ស៖** តើលោកគឺជាផ្នែកមួយនៃការជ្រើសរើសព័ត៌មាន ហើយបន្ទាប់មកសរសេរជាអត្ថបទដើម្បីសុំការយល់ព្រម ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ អាចថាអ៊ីចឹងក៏បានដែរបាទ។ ក៏ប៉ុន្តែលោកស្រី អៀង ធីរិទ្ធ ក៏គាត់អាចដូចថាអាចលើកឡើងនូវព័ត៌មានមួយ ឬពីរអ៊ីចឹងដើម្បីឱ្យខ្ញុំសរសេរ អាហ្នឹងក៏អាចមានដែរ។ ព្រោះក្នុងជាក់ -- ការជាក់ស្តែងក្នុងការធ្វើការ វាមានការទាក់ទងរបៀបនេះបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត នៅខែសីហា ថ្ងៃទី២ ឆ្នាំ ២០១២ ដដែលនេះ។ ERN ជាភាសាខ្មែរ 00831441, ជាភាសាបារាំង 00832831, ជា អង់គ្លេស 00832716។ ខ្ញុំសូមយោងទៅលើឯកសារនេះនៅត្រង់ទំព័រនេះ និងទំព័រមួយទៀត ដើម្បីសុំឱ្យលោកជួយបញ្ជាក់។ នៅទីនេះ គឺគេបានសួរលោកថា “តើលោកមានដឹងថា ប៉ុល ពត ផ្តល់ការបញ្ជាទៅឱ្យ អៀង សារី ដែរទេទាក់ទងទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ?” លោកឆ្លើយថា “ខ្ញុំមិនធ្លាប់បានដឹងទេ មិនបានដឹងទេ ពីព្រោះនេះវាជារឿងលោកទាំងពីរ”។ ហើយបន្ទាប់មកមានសំណួរមួយទៀត នេះជាសំណួរចុងក្រោយ “ក្រៅពី ប៉ុល ពត តើមានការប្រជុំណាមួយជាមួយកម្មាភិបាលថ្នាក់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យហ្នឹងយ៉ាងដូចម្តេច ទាក់ទងទៅនឹងនយោបាយការបរទេសដែលលោក អៀង សារី ធ្វើជារដ្ឋមន្ត្រី។ ឧទាហរណ៍ដូចជា លោក ខៀវ សំផន , លោក នួន ជា និងអ្នកផ្សេងទៀត។ តើមានការប្រជុំទាក់ទង និងកំណត់មាគ៌ានយោបាយទេ?” ចម្លើយថា “ខ្ញុំមិនបានដឹងទេ”។

ហើយបន្ទាប់មកលោកពន្យល់បន្ថែមថា លោកមានការពន្យល់បន្ថែមទៀត។ ដូច្នេះសូមរំឭកលោកសាក្សីថា ខ្ញុំសូមចូលទៅសារមួយទៀត។

[០៩:៥៣:៥៤]

សារចុះថ្ងៃទី៦ ខែសីហា ឆ្នា២០១២។ បាទ ប្រតិចារឹក គឺចុះថ្ងៃទី៦ ខែសីហា ២០១២ ERN ជាភាសាខ្មែរ 00832181 ដល់ 82, ERN អង់គ្លេស 00833351, ជាភាសាបារាំង 0082314 (ស៊ីក) ទៅ 35 បាទ។ នៅទីនេះ គឺថាគេបានសួរលោកថា លោកឆ្លើយថា "ខ្ញុំអត់ដឹងទេ។ ខ្ញុំគ្រាន់តែដឹងថាគាត់ទទួលបន្ទុកការបរទេស នៃគណៈមជ្ឈិម គឺលោក អៀង សារី ហើយសម្រាប់បញ្ញាជនដែលមកពីបារាំង ដែលជាអតីតវង់ ម៉ាក្ស-ឡេនីន គាត់ក៏ទទួលខុសត្រូវចំពោះក្រុមនេះដែរ។ គាត់គ្រប់គ្រងលើខ្ញុំផងដែរ។ ខ្ញុំក៏ជាផ្នែកមួយនៃវង់នេះដែរ។ ខ្ញុំសូមបញ្ជាក់អំពីការងារ"។ សូមដកស្រង់៖ "ការទទួលខុសត្រូវ"។ បិទការដកស្រង់។ ទទួលខុសត្រូវនៅពេលដែលខ្ញុំធ្វើសេចក្តីថ្លែងការណ៍ គឺគាត់ជាអ្នកគ្រប់គ្រងលើខ្ញុំ សម្រាប់មជ្ឈិម គឺសម្រាប់ ប៉ុល ពត។ ដូច្នេះ ប៉ុល ពត គាត់ធ្វើសេចក្តីសម្រេចដែរ ទាក់ទងទៅនឹងការចាត់តាំងឲ្យពួកយើងមកធ្វើការនៅទីនេះ ឬក៏នៅទីណានោះ។ អៀង សារី គ្រាន់តែជាអ្នកដែលទទួលខុសត្រូវផ្ទាល់របស់យើងទាំងអស់គ្នា"។ ដោយអានសារទាំងពីរនេះបញ្ចូលគ្នាទៅ ខ្ញុំសូមសួរទៅលោក ជាដំបូង ថាតើលោកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំណាមួយ ដែល ប៉ុល ពត មានការនិយាយមានការសន្ទនាជាមួយ អៀង សារី ដែរឬទេ នៅជុំវិញគណៈមជ្ឈិម ឬក៏សម្រាប់គណៈមជ្ឈិមនេះផ្ទាល់តែម្តង លោកដែលមានវត្តមានទេ?

[០៩:៥៦:០៩]

**ឆ៖** ខ្ញុំមិនដែលមានវត្តមានទេបាទ។

**ស៖** ឥឡូវនេះគឺ ហាក់បីដូចជាថា -- ឥឡូវខ្ញុំសូមបញ្ជាក់ពាក្យ "ទទួលខុសត្រូវ" និងពាក្យ "គ្រប់គ្រង"។ ខ្ញុំសូមសួរទៅលោកថា តួនាទីរបស់លោកនៅក្រសួងការបរទេស គឺតួនាទីហ្នឹងអ្នកណាជាអ្នកចាត់តាំងលោក?

**ឆ៖** អ្នកសម្រេចគឺ ប៉ុល ពត ជាអ្នកសម្រេច លោក អៀង សារី ជាអ្នកស្នើ ប៉ុន្តែសម្រេចឲ្យខ្ញុំទៅណាមកណា គឺស្រេចតែ ប៉ុល ពត ទេបាទ។ ខ្ញុំអាចបំភ្លឺពីចំណុចនេះ នៅពេលក្រោយមកទៀត ប៉ុន្តែវាវែងឆ្ងាយ ខ្ញុំគ្រាន់តែអាចឆ្លើយខ្លីអីចឹងបាទ។

[០៩:៥៧:១២]

**ស៖** ឥឡូវយើងខ្ញុំសូមផ្តោតទៅលើប្រធានបទនេះបន្តិចទៀត។ លោកបាននិយាយថា គឺលោក អៀង សារី បានស្នើសុំឱ្យចាត់តាំងលោក។ តើធ្វើម៉េចបានជាលោកដឹងថា ប៉ុល ពត ខ្លួនគាត់ផ្ទាល់ជាអ្នកចាត់តាំងលោក មិនមែនជាគេហៅថា ថ្នាក់ដឹកនាំសមូហភាពនោះ ម៉េចជាបានដឹងថា ប៉ុល ពត ជាអ្នកជ្រើសតាំងលោកតែឯងនោះ?

**ឆ៖** អានេះ គឺច្បាស់ណាស់ ព្រោះនៅក្នុងគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ ឧបមាថា ប៉ុល ពត បើបង នួន ជា អីមាននរណា ក្រៅ -- បង នួន ជា គាត់អត់ស្គាល់ខ្ញុំទេ ប៉ុល ពត បានគាត់ស្គាល់ខ្ញុំច្បាស់ ស្គាល់សមត្ថភាព។ ដូច្នេះ គាត់អ្នកចាត់តាំង។ ឥឡូវ ខ្ញុំជម្រាបវែងឆ្ងាយបន្តិច ប៉ុន្តែដើម្បីឱ្យយល់គឺ ឧបមាថា អតីតភរិយាខ្ញុំ គាត់សុំចូលមកក្នុងប្រទេសមកកម្ពុជា កាលកម្ពុជាប្រជាធិបតេយ្យ គឺអ្នកដែលសម្រេចឱ្យមកនោះគឺ លោក ប៉ុល ពត មិនមែនលោក អៀង សារី ទេ។ លោក ប៉ុល ពត ហ្នឹងគឺថា គាត់ឱ្យលោក អៀង សារី ធានាចំពោះគាត់ ធានាគឺថា អតីតភរិយាខ្ញុំហ្នឹងចំពោះគាត់។ ហើយលោក អៀង សារី ហ្នឹងឱ្យខ្ញុំធានាអំពីអតីតភរិយារបស់ខ្ញុំ ចំពោះលោកខ្លួនលោក អៀង សារី ឃើញទេ៎ ហើយខ្ញុំបន្ថែមចុះដើម្បីឱ្យយល់ គឺពេលដែលក្រោយមក គណៈភូមិ -- តំបន់ ដែលមេទ័ពនៅតាមតំបន់ហ្នឹង នៅប៉ៃលិន នៅម៉ាឡៃ នៅអីគឺថា អត់ប៉ានសម្រេចវាសនារបស់ខ្ញុំទេ មានតែមជ្ឈិមទេ អាចសម្រេចបាន។ ពួកហ្នឹងអត់ប៉ានប៉ះខ្ញុំ ចង់និយាយថា តែដល់ពេលខ្ញុំហើយ គេអត់ប៉ានប៉ះទេ ចង់និយាយថា ប៉ះគេអត់ប៉ានទុកថា ខ្ញុំក្បត់គេប្រឆាំងគេ ក៏គេអត់ប៉ានធ្វើអីខ្ញុំដែរ ព្រោះខ្ញុំដូចជាបងៗ ឬមិត្តឯទៀត ជាបញ្ញាជនមកពីប្រទេសបារាំងហ្នឹង គឺថាលោក ប៉ុល ពត ជាអ្នកសម្រេចវាសនាទាំងអស់។ លោក អៀង សារី គ្រាន់តែអ្នកប្រើទេ គាត់ប្រើធ្វើអីៗ ព្រោះគាត់ -- ខ្ញុំចង់ជម្រាបប៉ុណ្ណឹងចប់បាន។

[០៩:៥៩:៥០]

**ស៖** ឥឡូវខ្ញុំសូមសួរសង្កត់បន្តិច។ លោកប្រើពាក្យថា មជ្ឈិម។ ដូច្នេះលោកនិយាយថា ប៉ុល ពត ធ្វើសេចក្តីសម្រេចនេះ ប៉ុន្តែក្នុងចម្លើយរបស់លោកនេះ លោកបញ្ជាក់ថា វាសនារបស់លោក គឺស្ថិតនៅក្នុងដៃរបស់មជ្ឈិម នេះតាមមើល ខ្ញុំយល់តាមចម្លើយរបស់លោកឆ្លើយអម្បាញ់មិញ។ ដូច្នេះ ខ្ញុំសូមឱ្យលោកបញ្ជាក់ត្រង់នេះបន្តិច តើលោកអាចញែកពីគ្នាបានទេ រវាង ប៉ុល ពត និងមជ្ឈិម ដើម្បីឱ្យយើងខ្ញុំបានយល់ច្បាស់ ឬក៏ ប៉ុល ពត និងមជ្ឈិមតែមួយ?

**ឆ៖** តាមខ្ញុំមើលទៅតែមួយទេបាទ ដែលខ្ញុំនិយាយថា មជ្ឈិមហ្នឹងគឺថា គេហៅថាកម្មាភិបាលដែលក្រោមការគ្រប់គ្រងរបស់មជ្ឈិម។ មជ្ឈិមហ្នឹង គឺ ប៉ុល ពត ហើយបាទ។

**ស៖** ខ្ញុំសូមនៅត្រង់ប្រធានបទនេះសិន ខ្ញុំចង់បញ្ជាក់ចំណុចមួយដែលលោកក៏បានលើកឡើងពីចំណុចនេះដែរ។ ខ្ញុំចង់ផ្ដល់នូវការបរិច្ឆេទសិន ខ្ញុំយោងទៅប្រតិចារឹក ខែសីហា ទី០៦ គឺ ERN 00872153, ជាភាសាបារាំង 00833090, អង់គ្លេស 00833214។ នៅទីនេះ គឺគេបានសួរលោកអំពី ឌី.អ៊ុន.យូ.អែម ហៅថា *ទូម* នៅពេលដែលគេបង្កើត*ទូម* នេះឡើង ហើយនៅក្នុងចម្លើយរបស់លោក គឺយើងនិយាយអំពីក្រោយឆ្នាំ៧៩ ពេលនុ៎ង ប៉ុន្តែខ្ញុំចង់សំដៅទៅលើ តើលោកនិយាយយ៉ាងម៉េច? លោកថា "ក្រោយពី ១៩៧៩ តាមពិតទៅអ្វីដែលខ្ញុំចង់បញ្ជាក់ គឺ អៀង សារី បានផ្ដល់នូវការណែនាំដល់ខ្ញុំ ប៉ុន្តែគាត់មិនមានអំណាចក្នុងការសម្រេចនោះទេ។ សេចក្ដីសម្រេច គឺធ្វើឡើងនៅក្នុងកម្រិតគណៈអចិន្ត្រៃយ៍ គឺពិសេសដោយ ប៉ុល ពត តែម្ដង។ ដូច្នេះ ការចាត់តាំងរបស់ខ្ញុំនោះ គឺមិនមែនធ្វើឡើងដោយ អៀង សារី ទេ គឺដោយ ប៉ុល ពត ។ ដូច្នេះ ប៉ុល ពត ទី១ គាត់ត្រូវធ្វើសេចក្ដីសម្រេចដែលថា រដ្ឋមន្ត្រីទទួលបន្ទុកហ្នឹងត្រូវតែចេញបញ្ជា ឬក៏គ្រាន់តែបញ្ជូនបញ្ជា ឬបញ្ជូនការណែនាំហ្នឹងទៅថ្នាក់ក្រោម។ នេះជារចនាសម្ព័ន្ធនៃខ្សែចង្វាក់ក្នុងការបញ្ជា"។ ដូច្នេះ សំណួរដែលខ្ញុំត្រូវសួរនៅក្នុងអំឡុងពេល គឺបរិបទនៃចម្លើយដែលឆ្លើយហ្នឹង ខ្ញុំសួរថា នៅក្នុងចម្លើយរបស់លោកនេះ តើលោកនិយាយអំពីក្រោយ -- អំពីស្ថានភាពក្រោយឆ្នាំ៧៩ តើវាខុសយ៉ាងម៉េចដែរ រវាងចន្លោះពី៧៥ ទៅ៧៩ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេសនោះ?

[១០:០៣:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ ខាងការពារក្ដីនិយាយថា ជាសំណួរដែលទាក់ទងទៅនឹងមុនថ្ងៃទី០៦ សីហា និយាយពីរយៈពេលក្រោយ៧៩ ខ្ញុំគិតថា ចោទ -- ខាងការពារក្ដីហ្នឹងចោទសំណួរនេះច្បាស់លាស់ហើយ ទាក់ទងទៅនឹងសម្រង់ដែលទើបតែ -- សម្រង់ដែលអានថ្ងៃទី០៦ សីហា។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំអានជាភាសាអង់គ្លេស ប្រហែលជាមិនច្បាស់ជាភាសាបារាំងនៅពេលដែលបកប្រែទៅ -- ប្រហែលនេះគឺអ្វីដែលខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់លាស់។ ខ្ញុំសួរឲ្យសាក្សីគាត់ធ្វើការ

បញ្ជាក់ឡើងវិញ។ តើវាអ៊ីចឹងមែនទេ រវាង៧៥ ទៅនឹង ៧៩ ឬក៏គាត់និយាយតែចំពោះក្រោយឆ្នាំ១៩៧៩ ទេ? ខ្ញុំអត់មានចង់ស្នើសុំអីទេ គ្រាន់តែចង់ឱ្យសាក្សីបញ្ជាក់ ពីព្រោះពេលក្រោយមកគឺអង្គជំនុំជម្រះនឹងប្រាកដជាសំអាងទៅលើប្រតិចារឹកនេះហើយ។

**ឆ៖** គឺសភាពការណ៍នេះ --

[១០:០៤:៥១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១០:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីចាំនូវសំណួរ ដែលលោកមេធាវី ម៉ែខល កាណាវាស សួរលោកចុងក្រោយអំមិញដែរឬទេ? បើចាំលោកអាចឆ្លើយបាន បើមិនចាំទេ លោកអាចសូមឱ្យតាំងសំណួរសាជាថ្មីម្តងទៀត។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោក ម៉ែខល កាណាវាស ថា បញ្ហាទី១ សូមលោកមេធាវីតាំងសំណួរឱ្យបានខ្លី ឱ្យបានច្បាស់លាស់ ហើយចៀសវាងនូវសំណួរច្រំដែល ហើយនិងសូមឱ្យមាន -- ឱ្យសំណួរដែលសួរហ្នឹងគឺមានការពាក់ព័ន្ធនឹងទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការ ដែលមាននៅក្នុងដីកាដំណោះស្រាយ។

**លោក សួង ស៊ីគឿន៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំសូមលោកប្រធានឱ្យលោកមេធាវី គាត់បញ្ជាក់សំណួរម្តងទៀត ព្រោះខ្ញុំភ្លេច។

[១០:១១:១៤]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន អរគុណលោក លោកស្រីចៅក្រម អរគុណលោកសាក្សី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំយោងទៅសក្ខីកម្មរបស់លោកនៅ កាលពីថ្ងៃទី០៦ ខែសីហា គឺលោកបញ្ជាក់ថា "ក្រោយឆ្នាំ១៩៧៩ តាមពិតទៅខ្ញុំចង់បញ្ជាក់អ៊ីចេះទេ គឺចង់បញ្ជាក់ថា អៀង សារី គាត់ជាអ្នកប្រើខ្ញុំ។ ក៏ប៉ុន្តែគាត់

មិនមែនជាអ្នកសម្រេចត្រូវប្រើខ្ញុំទៅណាមកណាទេ ដែលចំពោះកិច្ចការដែលត្រូវដាក់មកឲ្យខ្ញុំនោះទេ។ សេចក្ដីសម្រេច គឺសម្រេចលើពីគណៈមជ្ឈិម ជាពិសេសគឺ ប៉ុល ពត ហ្នឹងតែម្ដង។ ដូច្នេះ ការចាត់តាំងឲ្យខ្ញុំទៅធ្វើនេះធ្វើនោះ មិនមែន អៀង សារី ទេ គាត់ជាអ្នកចាត់តាំងទេ គឺ ប៉ុល ពត។ ដូច្នេះ ប៉ុល ពត ត្រូវធ្វើសេចក្ដីសម្រេចទៅដល់រដ្ឋមន្ត្រី ដែលទទួលខុសត្រូវហ្នឹងឲ្យបញ្ហា ឬក៏បញ្ជូនបញ្ហា ឬក៏ការណែនាំចូលទៅថ្នាក់ក្រោម ចូលទៅកូនចៅរបស់ខ្លួន។ នេះឯងគឺៗ ជារចនាសម្ព័ន្ធនៃខ្សែចង្វាក់ក្នុងការបញ្ហា"។ នេះគឺជាចម្លើយរបស់លោក។ អ៊ីចឹងសំណួរខ្ញុំ តើនេះគឺជាស្ថានភាពដែលគេបានធ្វើឡើងនៅចន្លោះ ៧៥-៧៩ ដែរ ឬក៏តែស្ថានភាពសម្រាប់តែក្រោយ ៧៩ ទេ?

[១០:១២:៤៨]

**លោក ស្វង ស៊ីគឿន៖**

**ឆ៖** ស្ថានភាពនេះ គឺថាវាត្រូវប្រើនៅចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩ ហើយបន្តក្រោយពី ៧៩ នេះទៀតរហូតដល់ការផ្ដាច់ខ្លួនរបស់លោក អៀង សារី ពីចលនាខ្មែរក្រហមនៅឆ្នាំ១៩៩៦ បាទ។

**ស៖** សូមអរគុណលោក។ ខ្ញុំសូមចូលទៅផ្នែកមួយផ្សេងទៀតនៅក្នុងសក្ខីកម្មរបស់លោក ដែលខ្ញុំសូមឲ្យលោកបញ្ជាក់បន្ថែមបន្តិច។ នេះគឺជាប្រតិចារឹកចុះខែសីហា ERN ជាភាសាខ្មែរ 00832156, ERN បារាំង 00833095, អង់គ្លេស 00833218។ នៅត្រង់នេះគឺគេបានសួរលោកអំពីការទុកចិត្តគ្នា។ ជាភាសាខ្មែរ គឺចាប់នៅ 00832156 ដែលចាប់ផ្ដើមពីពាក្យថា "វានិយាយអំពីសហការជិតស្និទ្ធ ហើយនិងទុកចិត្តគ្នាទាំងអស់ -- សហការីជិតស្និទ្ធនិងការទុកចិត្តគ្នា"។ សូមដកស្រង់ពាក្យ "ការទុកចិត្ត" បិទការដកស្រង់។ "ពីព្រោះមិនមានការទុកចិត្តគ្នា១០០ភាគរយទេ ឧទាហរណ៍ថា និយាយថា ៥១ភាគរយចុះ អាហ្នឹងក៏ខ្ញុំជាប់មធ្យមភាពដែរ ដូច្នេះមិនមែនជាបញ្ហាទេ។ បើដូចពាក្យដែលប្រើពាក្យថា ទុកចិត្តក្នុងជីវភាពផ្ទៃក្នុងរបស់បក្ស ដូចគេមិនមានចោទបញ្ហាហ្នឹងទេ ព្រោះអ្វីជាការវិវត្ត និងជាការតស៊ូស្រួចស្រាល់ក្នុងរយៈពេលកន្លងមក"។ ដូច្នេះខ្ញុំចង់សួរលោកចំពោះការទុកចិត្តគ្នា។ សំណួររបស់ខ្ញុំគឺតាមលោកយល់ ពាក្យថា "ការទុកចិត្តគ្នា" ហ្នឹងក្នុងអំឡុងពេលហ្នឹងមានន័យថាម៉េច? ជាពិសេស "ការទុកចិត្តគ្នា" ពាក់ព័ន្ធទៅនឹងការលាក់ការសម្ងាត់?

**លោក ស្វង ស៊ីគឿន៖**

អត់ទោសលោកប្រធាន ដោយខ្ញុំមិនបានយល់គ្រប់ជ្រុងជ្រោយចំពោះសំណួរនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ពិគ្រោះយោបល់ជាមួយមេធាវីរបស់ខ្ញុំបានទេបាទ?

**ប្រធានអង្គជំនុំ៖**

មិនអាចធ្វើដូច្នោះទេ សំណួរនេះចម្លើយមិនៗជាចម្លើយដែលនាំឲ្យលោកមានការដាក់ពិរុទ្ធភាពលើខ្លួនលោកទេ។ គ្រាន់តែបញ្ជាក់ខ្លឹមសារនៃចម្លើយដែលលោកបានផ្ដល់ពីមុនមកប៉ុណ្ណោះ ដើម្បីឲ្យកាន់តែច្បាស់លាស់ វាចៀសវាងមានការភ័ន្តច្រឡំ ឬក៏បញ្ហាខុសគ្នា។ ការពិភាក្សាជាមួយលោកមេធាវីបានតែសំណួរណាដែលនាំ ឲ្យចម្លើយរបស់លោកឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងតែប៉ុណ្ណោះ។

[១០:១៦:៣៤]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំអាចសួរឡើងវិញ ដើម្បីអាចឲ្យវាក្ដោបក្ដាប់ទៅលើអត្ថន័យបានទូលំទូលាយ។ លោកបានផ្ដល់ព័ត៌មាននេះ ហើយយើងបានឮពាក្យថា "ការរក្សាការសម្ងាត់" គឺជាចំណុចកំពូលបំផុត។ នេះគឺៗជាការតស៊ូដើម្បីរក្សាការសម្ងាត់។ ក្នុងបរិបទនេះ ខ្ញុំចង់ឲ្យលោកជួយពន្យល់មកខ្ញុំចំពោះការទុកចិត្តគ្នា ជំនឿទុកចិត្តនេះ ថាតើៗសំដៅទៅលើអ្វី?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ សូមអរគុណលោកប្រធានដែលបានបំភ្លឺខ្ញុំហ្នឹង។ ខ្ញុំមានការលំបាកឆ្លើយបន្តិច ព្រោះថាបញ្ហាទុកចិត្ត ឬមិនទុកចិត្តហ្នឹងវាជាមានន័យវាទាល់ប្រៀបធៀប។ ឧបមាថា ក្នុងភារកិច្ចមួយ ឧបមាថា ជាអ្នកផ្សព្វផ្សាយចុះ ជាឧបមាជាប្រធានវិទ្យុផ្សាយសំឡេងចុះ។ អាហ្នឹងបើមានបេក្ខជនបីបួននាក់ហ្នឹង អាហ្នឹងការទុកចិត្តវាអាចយើងថា ៥១ភាគរយ, ៦០ភាគរយ, ៧០ភាគរយ យើងអាចថាបាន ប៉ុន្តែមានចំពោះតែម្នាក់។ ឧបមាថា មានចំពោះខ្លួនខ្ញុំគឺថា "ការទុកចិត្ត" ហ្នឹងមានតែចំពោះតែ ៥០ភាគរយ ដូចខ្ញុំនិយាយ ៥១ភាគរយ គេធ្វើហើយបាទ។ ឬមួយគឺថានៅពេលនោះជាក់ស្ដែង ឬមួយគេអាចចាត់តាំងអ្នកដែលមិនទុកចិត្តហ្នឹង ១០០ បានការទុកចិត្តហ្នឹង តែ ៤៩ ឬ ៤៨ភាគរយ ប៉ុន្តែដល់ការអនុវត្តជាក់ស្ដែង គឺលេខាបក្សហ្នឹងគាត់សម្រេច ដំណើរការផ្ទាល់ជាមួយនឹងអ្នកដែលនៅក្រោមបង្គាប់ និងអ្នកដែលជាប្រធានវិទ្យុហ្នឹង។ ខ្ញុំលើកឧទាហរណ៍ ព្រោះកន្លងមកវាមានការកិច្ចដំណើរការអ៊ីចឹង។

[១០:១៨:៥៣]

ដូច្នោះ មិនមានជាបញ្ហាទុកចិត្ត ឬមិនទុកចិត្ត ការទុកចិត្តហ្នឹងវា គឺថាវាអាស្រ័យតែ គឺប្រវត្តិនៃសមាជិកម្នាក់ៗ ហើយការដូចថា សុទ្ធតែប្រៀបធៀប ខ្ញុំមិនអាច វាមានឧទាហរណ៍ច្រើន ប៉ុន្តែខ្ញុំសូមជម្រាបតែប៉ុណ្ណឹងបានបាទ។

**សៈ** សូមអរគុណ។ ចុះចំពោះព័ត៌មាននេះវិញ ទស្សនៈនៃពាក្យថា "ការទុកចិត្តគ្នា" នេះ តើវាមានខុសគ្នាទេក្នុង -- នៅក្នុងអំឡុងពេលនោះ? ព័ត៌មានដែលថាអាចត្រូវបញ្ជូនពីថ្នាក់លើមកថ្នាក់ក្រោម តើទស្សនៈនៃពាក្យថា "ទុកចិត្តគ្នា" នេះ គេយកមកប្រើប្រាស់ដែរឬទេ? ជាពិសេសទាក់ទងទៅនឹងការរក្សាការសម្ងាត់ខ្ពស់បំផុត ហើយយ៉ាងម៉េចដែរចំពោះការបំពានទៅលើការរក្សាការសម្ងាត់នេះ តើវាយ៉ាងណាដែរ?

**ឆះ** តាមខ្ញុំយល់ គឺពីខាងលើមកខាងក្រោម ហើយខាងក្រោមបន្តបន្ទាប់មកទៀត គឺច្បាស់ហើយគឺថាត្រូវតែមានការទុកចិត្តគ្នាមួយកម្រិតដែរ បានយើងអាចផ្តល់ព័ត៌មានឲ្យបាន។ ហើយក្នុងទីនេះ គឺថាខ្ញុំចង់ជម្រាបថា អាហ្នឹងវាអាស្រ័យលើខ្សែដែរ ព្រោះសុទ្ធតែខ្សែ ដូចខ្ញុំអ៊ីចឹង ខ្ញុំចូលតស៊ូតាំងពីកូនង៉ែតមក ប៉ុន្តែខ្ញុំអត់មានខ្សែ ដូច្នេះគេអត់ទុកចិត្តដែរ។ នរណាក៏គេមិនទុកចិត្តដែរ អាច -- សុំទោសចុះ អាចគឺថាបង ខៀវ សំផន គាត់ទុកចិត្តខ្ញុំជាង ព្រោះដូចថា គាត់ក៏គ្មានអំណាច ខ្ញុំក៏គ្មានអំណាច។ អាចគាត់ទុកចិត្តគ្នា ប៉ុន្តែចំពោះការរក្សាការសម្ងាត់ គឺថាគាត់ ច្បាស់ជាគាត់ពូកែជាងខ្ញុំហើយអាហ្នឹងបាននេះ ព្រោះខ្ញុំមាត់វាដាចបន្តិចដែរ។ អាហ្នឹងចង់ជម្រាបអ៊ីចឹងបាទ។ អាហ្នឹងវា ប៉ុន្តែបើថាខ្សែដូចគ្នា អាហ្នឹងជួនកាលគេទុកចិត្តតាមខ្សែហ្នឹង ទោះជាអាខ្សែហ្នឹងនៅក្រោមបង្គាប់ខ្ញុំ ក៏ព័ត៌មានេះ គេឲ្យតាមហ្នឹង។ អានេះ ខ្ញុំចង់ជម្រាបសភាពការណ៍ពេលនោះ វាអ៊ីចឹង។ បានសភាពការណ៍ វាអ៊ីចឹង ចំពោះខ្លួនខ្ញុំផ្ទាល់វាអ៊ីចឹង មានការឈឺចាប់ច្រើន។ ក៏ប៉ុន្តែ ខ្ញុំនៅតែស្រឡាញ់ ខ្ញុំនៅតែគោរពបងៗទាំងអស់នោះ។ ខ្ញុំមិនមានតូចចិត្តអីទេ ព្រោះខ្ញុំសម្រេចហើយបាទ។

[១០:២២:០៩]

**សៈ** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចូលទៅផ្នែកមួយផ្សេងទៀត នៃសក្ខីកម្មរបស់លោក ដែលមាន ERN ជាភាសាខ្មែរ 00832156 ទៅដល់ 57, ERN បារាំង 00833096, ហើយ ERN អង់គ្លេស 00833219 ដល់ 20។ នៅត្រង់នេះ គឺលោកបានជម្រាបថាលោក គឺជាប្រធានផ្នែកនៃការនៃវិទ្យុផ្សាយសំឡេងរបស់ក្រសួងការបរទេសរហូតមកដល់ឆ្នាំ១៩៧៩ ហើយក្រោយមកលោកនិយាយថា "ប៉ុល ពត បានចាត់តាំងខ្ញុំឲ្យធ្វើប្រធានផ្នែកព័ត៌មាន ឬក៏ហៅថា ទីភ្នាក់ងារសារព័ត៌មានកម្ពុជា"។ តើ ប៉ុល ពត ជាអ្នកចាត់តាំងលោក ឲ្យលោកកាន់មុខងារនេះ មុខនាទីនេះ ឬក៏យ៉ាងម៉េច?

**ឆះ** បាទ គឺប៉ុល ពត គាត់អ្នកចាត់តាំងខ្ញុំដោយផ្ទាល់។ ពេលនោះ គឺខ្ញុំទៅជួបគាត់ជាមួយនឹងលោក អៀង សារី បាទ។ ទៅដល់នោះ គឺខ្ញុំបាន -- ខ្ញុំមិនទទួលទេបាទ ព្រោះខ្ញុំថា ការងារខ្ញុំច្រើនហើយ

គឺថា បើបងឲ្យខ្ញុំធ្វើអាហ្នឹងទៀត ក្រែងខ្ញុំបំពេញភារកិច្ចខ្ញុំនៅក្រសួងការបរទេសមិនបាន។ ខ្ញុំចង់ជម្រាបថានៅពេលនោះ នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ខ្ញុំសម្រាកមួយថ្ងៃបានតែកន្លះម៉ោងទេ គឺពីម៉ោង៤កន្លះព្រឹក ដល់ម៉ោង៥ សូមជម្រាប២ឆ្នាំ។ ដូច្នេះ ក៏ប៉ុន្តែចំពោះខ្ញុំ ការអត់ងងុយ អត់មានបញ្ហានេះទេ ព្រោះខ្ញុំសម្រាក បើខ្ញុំហត់ពេលហ្នឹង ខ្ញុំត្រឡប់ទៅផ្ទះខ្ញុំវិញ តាមឡានហ្នឹង ខ្ញុំលក់ហើយ។ សូមជម្រាបអ៊ីចឹង។ ប៉ុន្តែខ្ញុំចង់តែ និយាយថាពេលហ្នឹងសភាពការណ៍វាដូច្នេះ។ ដូច្នោះ គាត់ ខ្ញុំជម្រាបអ៊ីចឹង ក៏ប៉ុន្តែគាត់គឺ -- សុំអភ័យទោសដល់បងប្អូនដែលបាត់បង់ឪពុកម្ដាយញាតិសន្ដាន ដែលមានវត្តមាននៅទីនេះ។ ខ្ញុំនិយាយតែការពិតទេ។ ខ្ញុំមិនមានស្អីក្រៅពីហ្នឹងទេ ហើយខ្ញុំក៏មានបងប្អូនមានមាមីងខ្ញុំក៏បាត់បង់នៅពេលនោះដែរ ហើយបងៗដែលអ្នករងគ្រោះ ដែលជាអ្នកដឹកនាំក៏មានបងប្អូនគាត់បាត់ខ្លួននៅពេលនោះដែរ។ ដូច្នោះខ្ញុំចង់និយាយថាចំពោះ ប៉ុល ពត គឺគាត់ស្អីក៏គាត់សុទិដ្ឋិនិយមដែរ អត់មានបញ្ហា។ គាត់ថា អត់មានបញ្ហាទេ មិត្តធ្វើតែមួយថ្ងៃ -- មួយពេលមិត្តធ្វើតែប្រាំដំណឹងទៅបានហើយ។ ដូច្នោះ ប្រាំដំណឹងមានអីពិបាកធ្វើ អង្គុយសរសេរតែកន្លះម៉ោងទៅវាបានហើយ។ ហើយខ្ញុំក៏ព្រមទទួលទៅ អានេះ ខ្ញុំចង់និយាយថា ប៉ុល ពត គាត់ចាត់តាំងខ្ញុំផ្ទាល់បាទ។

[១០:២៥:៥០]

**ស៖** សូមអរគុណ។ ដូច្នេះ យើងឃើញថា ផ្នែកនៃចម្លើយរបស់លោក គឺនៅ ERN ត្រង់ 00832159 ដល់ 60, ជាបារាំង 00833100 ដល់ 01, ERN អង់គ្លេស 00833222 ដល់ 23។ ខ្ញុំពេញចិត្តចម្លើយរបស់លោកណាស់ ប៉ុន្តែខ្ញុំចង់សង្កត់បន្ថែមបន្តិច។ ដូច្នេះ ដូចលោកធ្វើឲ្យយើងមានការចាប់អារម្មណ៍ យើងខ្ញុំមានការចាប់អារម្មណ៍ថា លោកមានសិទ្ធិអំណាចក្នុងការ -- លោកមានសិទ្ធិបដិសេធចំពោះការចាត់តាំងរបស់ ប៉ុល ពត។ ដូច្នេះ វាផ្ទុយទៅនឹងអ្វីដែលលោកឆ្លើយថា ប៉ុល ពត ធ្វើការចាត់តាំងទាំងអស់ ហើយ ប៉ុល ពត កាលណាគាត់និយាយ គឺគាត់និយាយក្នុងនាមឲ្យមជ្ឈិមតែម្ដង។ តើលោកអាចបញ្ជាក់បន្តិចបានទេថា តើលោកមានសិទ្ធិបដិសេធ ការបញ្ជាណាមួយរបស់ ប៉ុល ពត ដែរឬទេ?

**ឆ៖** អាហ្នឹង និយាយឲ្យត្រង់ទៅ គឺថាក្នុងពេលតាមឡានហ្នឹង លោក អៀង សារី គាត់ប្រាប់ខ្ញុំថា មិត្តកុំទទួល បើគាត់ចាត់តាំង។ អ៊ីចឹងហើយខ្ញុំ ពីពេលខ្ញុំនឹកបារម្ភ នឹកឃើញថាអ្ហូ យ៉ាងម៉េចអ៊ីចេះហើយខ្ញុំពេលនោះ ខ្ញុំប៉ិនប្រកែកនឹងគាត់ ដោយសារខ្ញុំស្គាល់គាត់ ប៉ុល ពត ខ្ញុំស្គាល់គាត់ ដូចបងៗខ្ញុំអ៊ីចឹង។ ខ្ញុំអត់សូវខ្លាចគាត់ទេ ព្រោះខ្ញុំស្គាល់គាត់តាំងពីតូច។ ហើយមួយទៀត គឺថា ខ្ញុំអត់ដឹងរឿងរ៉ាវអី

ដែលខ្ញុំដឹងក្រោយពីឆ្នាំ១៩៧៩ ទេ។ ហើយខ្ញុំជម្រាបឲ្យត្រង់ បើខ្ញុំដឹងរឿងរ៉ាវដូច១៩៧៩ ខ្ញុំក៏មិនប៊ាន អ៊ីចឹងដែរ។ ពេលនោះ ខ្ញុំប៊ាន ហើយខ្ញុំប៊ានច្រើនទៀតក្នុងរយៈពេលហ្នឹង ខ្ញុំប៊ានប្រឆាំងអីគាត់ច្រើនទៀតមតិច្រើនទៀត ដូចកិច្ចចរចាត្រីភាគីអី ហ្នឹងខ្ញុំប៊ានប្រឆាំងគាត់ ខ្ញុំប៊ានមានមតិគាត់។ ដូច្នោះគាត់ទទួលមតិដែរតើ មិនមែនអ្នកមិនទទួលមតិទេ។ ប៉ុន្តែដូចថា ខ្ញុំមិនដឹងយ៉ាងម៉េច ប៉ុន្តែគឺថា ពេលនោះគាត់ -- ប៉ុន្តែគាត់គឺថា គាត់និយាយអ៊ីចឹងមក ខ្ញុំជំពាក់ដែលទទួល បើខ្ញុំមិនទទួល អាហ្នឹងខ្ញុំប្រឆាំងនឹងគាត់ហើយបាទ។

[១០:២៨:៣៦]

**សៈ** តើមានន័យថាម៉េច បើសិនណាលោកជំទាស់មិនទទួលការចាត់តាំងរបស់គាត់ហ្នឹង តើវាទៅជាយ៉ាងម៉េចដែរ?

**ផៈ** ខ្ញុំក៏មិនដឹងដែរ។ មិនបានដឹងទេ ព្រោះអាហ្នឹងអាចថាមិនបានទេ ប៉ុន្តែតាមមើលទៅដូចមិនអីទេ ព្រោះលោក អៀង សារី គាត់គាំទ្រខ្ញុំដែរ ដូចតាមមើលទៅ ដូចមិនអីទេ។ ហើយដូចគ្រាន់តែប៉ុណ្ណឹងក៏យកទៅសម្លាប់ចោល ដូចពិបាកដែរ ហើយជាពិសេសមនុស្សដែលធ្លាប់រាប់អានគ្នាអីនេះ។ អ៊ីចឹងបានខ្ញុំឈឺចាប់ណាស់ ដែលបង សុន សេន ទទួល ហើយនិងប្រពន្ធគាត់ទទួលការកាប់សម្លាប់ដោយក្រោមបញ្ជារបស់ ប៉ុល ពត ខ្ញុំគឺស្រក់ឈាម ព្រោះតែមិនគួរធ្វើដល់ប៉ុណ្ណឹងទេ។ ខ្ញុំគ្រាន់ជម្រាបប៉ុណ្ណឹងបាទ ទុកយ៉ាងណាក៏ទុកជីវិតឲ្យរស់នៅទៅ ព្រោះធ្លាប់កម្សត់កម្រជាមួយគ្នារបស់សិបឆ្នាំ។

**សៈ** យើងផ្តោតទៅលើទំព័រដដែល ដែលកំពុងតែសួរលោកនេះ ខ្ញុំសូមឲ្យលោកបញ្ជាក់បន្ថែមបន្តិច ពីព្រោះលោកបន្តនិយាយថា "ក្នុងទីភ្នាក់ងារសារព័ត៌មាននេះ គឺវាស្ថិតនៅក្នុងតារាងបញ្ជា នៅក្នុងខ្សែចង្វាក់របស់ក្រសួងព័ត៌មាន និងឃោសនាការ"។ ថាតើវាស្ថិតនៅក្នុងក្រសួងព័ត៌មាន ឬក៏ស្ថិតនៅក្នុងក្រសួងឃោសនាការ ស្ថិតនៅដាច់ពីគ្នាតែម្តង ឬក៏យ៉ាងម៉េច?

**ផៈ** អត់នៅក្នុង -- ក្រសួងការបរទេសក៏អត់នៅក្នុងហ្នឹង ក្រសួងឃោសនាការក៏អត់នៅក្នុងហ្នឹង។ គឺថា អាហ្នឹងវាទាក់ទងផ្ទាល់ជាមួយ ប៉ុល ពត តែម្តងបាទ។

**សៈ** លោកបានបញ្ជាក់ថា នេះគឺវាស៊ីពេលវេលារបស់លោកបន្តិចហើយ ថាលោកៗមិនបានសម្រាកច្រើនទេ សម្រាន្តច្រើន។ ក្នុងការទាក់ទងគ្នាជាមួយនឹង ប៉ុល ពត ជាពិសេសទាក់ទងទៅនឹងតួនាទីដែលលោកបានទទួលនេះ? បាទ សូមលោកជួយបញ្ជាក់ចំណុចនេះបន្តិច?

[១០:៣១:១៥]

**ឆ៖** ទាក់ទងគឺ ខ្ញុំតាម ខ្ញុំចាំខ្ញុំទាក់ទងតាមលេខាសាខាបក្ស គឺលោកស្រី សួរ សែ បាទ។ តើគាត់ចាត់ចែងយ៉ាងណាអាហ្នឹងខ្ញុំមិនបានដឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកដល់សាក្សី នៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់ ទាំងមេធាវីរបស់គាត់ផងមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដែលបានកំណត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២នាទី ដល់ម៉ោង ១០:៥៦ នាទី)*

[១០:៥៦:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំនឹងចូលទៅដល់ផ្នែកមួយដែលលោកពិភាក្សាអំពីតួនាទីជាអ្នកនាំពាក្យរបស់ក្រសួងការបរទេស ហើយខ្ញុំយោងទៅរកផ្នែកមួយខ្មែរ ERN 00832164 រហូតដល់ 65,

បារាំង ERN 00838107 ដល់ 09 ខ្ញុំជឿថាអ៊ីចឹង។ ហើយនៅក្នុងអង់គ្លេស 00833228 ដល់ 29។ នៅកន្លែងនេះគេសួរលោកអំពីតួនាទីរបស់លោកជាអ្នកនាំពាក្យ ហើយលោកបានចង្អុលបង្ហាញថា៖ "ថាតើអ្នកណាជាមេរបស់លោក?" ហើយលោកឆ្លើយដូចខាងក្រោមនេះ៖ "លោកអៀង សារី ជាមេដឹកនាំផ្ទាល់របស់ខ្ញុំ។ ប៉ុន្តែនៅក្នុងផ្នែកខ្លះ ឬក៏ការងារខ្លះ ខ្ញុំធ្វើការផ្ទាល់ឲ្យ ប៉ុល ពត នៅក្នុងសមត្ថភាពរបស់គាត់ជាលេខាបក្ស។ នៅក្នុងសមត្ថភាពនោះ គាត់តែងតាំងខ្ញុំឲ្យធ្វើការងារអ្វីក៏បាន ដូចជាស្របច្បាប់ តាមច្បាប់នៅពេលនោះ"។

[១០:៥៧:៥៤]

ហើយខ្ញុំសូមឲ្យលោកបំភ្លឺ ដើម្បីផ្អែកទៅលើ -- យោងទៅរកចម្លើយរបស់លោកថ្ងៃនេះនោះ លោកនិយាយថា "គាត់តែងតាំងលោកក្នុងឋានៈជាលេខាបក្ស។ នេះជាការងារស្របច្បាប់"។ នៅក្នុងការសម្រេចនេះ តើក្នុងសមត្ថភាពនេះ តើក្នុងករណីផ្សេងទៀត តើគាត់ៗធ្វើសេចក្តីសម្រេចដោយសារថាគាត់ជា ប៉ុល ពត ឬក៏យ៉ាងដូចម្តេច?

**លោក ស្លុង ស៊ីគឿន៖**

**ឆ៖** នេះគឺជាគោលការណ៍ចាត់តាំងរបស់បក្ស គឺថាខាងលើ -- ខាងក្រោមត្រូវគោរពខាងលើ ភាគតិច ត្រូវគោរពភាគច្រើនបាទ។ ហើយក្នុងឋានៈគាត់ជាលេខាបក្ស ប៉ុល ពត គាត់អាចប្រគល់ភារកិច្ចណាមួយដល់បក្ខជននៅទីកន្លែងណាក៏បានដែរ ផ្ទាល់តែម្តង មិនចាំបាច់ឆ្លងកាត់តាមអ្នកទទួលខុសត្រូវផ្ទាល់របស់បក្ខជននោះទេបាទ។ នេះជាគោលការណ៍ចាត់តាំងអ៊ីចឹងបាទ។

[១០:៥៩:១៥]

**ស៖** បាទ សូមអរគុណដែលលោកបានបំភ្លឺ។ ប្រហែលលោកអាចជួយខ្ញុំ ហើយយើងចូលទៅដល់ផ្នែកមួយទៀត ប្រតិចារឹកចម្លើយរបស់លោកគឺនៅត្រង់ខែសីហា ទី០៦ ខ្មែរERN 00832188 ដល់ 89, បារាំង ERN 00833145 ហើយអង់គ្លេស ERN 00833260។ នៅត្រង់នេះ គឺមានសំណួរមួយចំពោះលោក "តើលោកមានទំនាក់ទំនងអ្វីជាមួយលោក នួន ជា ទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?" ហើយលោកបានឆ្លើយថា "ផ្នែកមួយនោះ នួន ជា បានស្នើឲ្យលោករៀបចំអត្ថបទមួយ អំពីៗនយោបាយបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ជាឱកាសតែមួយគត់ដែលលោកបានទំនាក់ទំនងជាមួយលោក នួន ជា"។ តើលោកបានឃើញផ្នែកនៃសក្ខីកម្មរបស់លោកនេះទេលោកសាក្សី?

**ឆ៖** បាទ ខ្ញុំបានធ្វើ -- បានឃើញ ខ្ញុំបាននិយាយដូច្នោះមែន។

**ស៖** ការបំភ្លឺនេះដែលខ្ញុំចង់បានពីលោកនោះ គឺថាក្នុងសមត្ថភាពអ្វីដែល នួន ជា ស្នើលោកដោយផ្ទាល់ឲ្យសរសេរអត្ថបទមួយនោះ ដែលស្ដីអំពីនយោបាយបរទេសកម្ពុជាប្រជាធិបតេយ្យ? តើអំណាចអ្វីដែលគាត់មានលើរូបលោកនោះ? ព្រោះលោកនិយាយថា មានតែ ប៉ុល ពត ទេ ដែលគាត់ជាលេខាបក្ស គាត់មានសិទ្ធិអំណាចធ្វើអ្វីគ្រប់យ៉ាង។ តើក្នុងករណីនេះលោកអាចពន្យល់បានដូចម្ដេច?

**ឆ៖** ព្រោះលោក នួន ជា ក៏ពេលនោះ គាត់ជាអនុលេខារបស់បក្ស។ ដូច្នោះ សិទ្ធិរបស់គាត់ ក៏គាត់អាចមានសិទ្ធិទាក់ទងផ្ទាល់ជាមួយបក្ខជនបានដែរបាទ។

**ស៖** សូមអរគុណ។ សំណួរមួយទៀតទាក់ទងនឹងបញ្ហានេះ គឺថាគាត់ថា -- លោកនិយាយថា គាត់អាចធ្វើអ្វីក៏ស្របច្បាប់ ជាលេខាបក្សហើយនិងអនុលេខាបក្ស។ តើគេត្រូវឲ្យមានការបំភ្លឺអំពីលោក អៀង សារី ទេនៅក្នុងករណីនេះ? តើពួកគាត់ -- បាទយើងសួរតែប៉ុណ្ណឹង។ តើពួកគាត់ត្រូវការបំភ្លឺពីគាត់ទេ ដើម្បីអនុញ្ញាតឲ្យលោកឲ្យអនុវត្តនូវការងារ ឬមុខងារទាំងនេះនោះ?

[១១:០២:១៨]

**ឆ៖** ខ្ញុំមិនអាចដឹងច្បាស់ទេ ប៉ុន្តែគ្រាន់តែខ្ញុំករណីខ្លះគឺដូចមិនចាំបាច់ទេ។ ជួនកាលគាត់ ប៉ុល ពត គាត់ធ្វើត្រង់មកសមាជិកបក្សណាម្នាក់ដែរបាទ។

**ស៖** នៅពេលដែលគាត់ទាក់ទងផ្ទាល់ជាមួយលោក ហើយលោកយល់ថា លោកមានទំនាក់ទំនងជិតស្និទ្ធជាមួយគាត់ ប៉ុន្តែការទាក់ទងផ្ទាល់ជាមួយលោក ហើយចាត់តាំងឲ្យលោកធ្វើការងារ តើលោកតែងតែធ្វើការងារហ្នឹងជាមួយលោក អៀង សារី ពីមុនមកឬទេ ឬក៏លោកធ្វើការងារហ្នឹងតាមការណែនាំរបស់ ប៉ុល ពត?

**ឆ៖** ខ្ញុំ ការងារដែលគាត់ចាត់តាំងខ្ញុំផ្ទាល់ ខ្ញុំធ្វើការងារផ្ទាល់ជាមួយគាត់បាទ អត់ចាំបាច់មានវត្តមាន ឬសួរមតិអីចំពោះលោក អៀង សារី ទេបាទ។

**ស៖** ហើយប្រសិនបើ ប៉ុល ពត ត្រូវសុំឲ្យលោកមិនលាតត្រដាងពីអ្វីដែលលោកធ្វើការក្នុងនាមគាត់នោះ តើលោកមានកាតព្វកិច្ចត្រូវតែគោរពបញ្ហានោះដែរឬទេ? ឬដោយសារថាលោកធ្វើការឲ្យក្រសួងការបរទេស លោកត្រូវតែរាយការណ៍ទៅលោក អៀង សារី ដែរឬទេ?

[១១:០៣:៥៨]

**ឆ៖** ខ្ញុំ បើធ្វើការត្រង់ផ្ទាល់ជាមួយគាត់ ក្នុងឋានៈខ្ញុំជាបក្ខជន ខ្ញុំមិនមានកាតព្វកិច្ចអីនឹងរាយ-ការណ៍ប្រាប់លោក អៀង សារី ទេ។ ក្នុងករណីណាដែលគាត់សួរ អាហ្នឹងអាចខ្ញុំរាយការណ៍ បើគាត់

មិនសួរខ្ញុំក៏មិនមាន -- ខ្ញុំក៏មិនត្រូវរាយការណ៍ចំពោះគាត់ដែរ ព្រោះលោក -- ព្រោះ ប៉ុល ពត គាត់ -- ក្នុងបក្សគឺថាគាត់នៅខ្ពស់ជាងលោក អៀង សារី បាទ។

**ស៖** បាទ ដូច្នេះដើម្បីឱ្យខ្ញុំយល់បានត្រឹមត្រូវ ប្រសិនបើគាត់សុំឱ្យលោក ឬក៏បង្គាប់ឱ្យលោករក្សាការសម្ងាត់ ហើយមិនត្រូវប្រាប់អ្នកណានោះ ដោយហេតុថាមុខតំណែងរបស់គាត់។ តើលោកមានកាតព្វកិច្ចត្រូវតែគោរពការបញ្ជារបស់គាត់ទេ?

**ឆ៖** បាទ ច្បាស់ណាស់ គឺថាក្នុងឋានៈជាបក្ខជន ខ្ញុំត្រូវគោរព ម៉េចការបញ្ជារបស់គាត់បាទ។

**ស៖** តើគេមិនត្រូវចាត់ទុកថា ជាការមិនគោរពដែរឬទេ ទាក់ទងទៅនឹងលោក អៀង សារី បើលោកធ្វើបែបនោះ តើៗវាស្របទៅតាមគោលការណ៍ទេនៅពេលដែលថា លោកមិនឋិត ប្រាកដជាឋិតនៅក្រោមបង្គាប់លោក អៀង សារី នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគឺថាសំណួរខាងការពារក្តីនេះ គឺជាសំណួរនាំមុខមែនទែន។ ដូច្នេះសូមឱ្យគិតថាសំណួរនេះមិនសមស្របនោះទេ។ មេធាវីចង់ឱ្យសាក្សីហ្នឹងយល់ស្របនឹងការទាញការសន្និដ្ឋានរបស់ខ្លួន។ ដូច្នេះ របៀបសួរបែបនេះមិនសមស្របទាល់តែសោះ។

[១១:០៦:២៩]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំ -- លោកប្រធាន ខ្ញុំសួរឱ្យគាត់បំភ្លឺទាក់ទងទៅនឹង -- ហើយបើសិនការជំទាស់ -- សំណួររបស់ខ្ញុំហ្នឹង គឺជាបញ្ហាដែលចេញមកពីអង្គហេតុដែលចេញមកពីសាក្សី គឺខ្ញុំមិនមែនស្នើអង្គហេតុនេះទេ គឺគ្រាន់តែឱ្យគាត់បញ្ជាក់។ ដូច្នេះគឺសមស្រប ដើម្បីឱ្យសាក្សីបញ្ជាក់ បើតុលាការសម្រេចថាមិនសមស្រប ខ្ញុំនឹងបន្តទៅមុខទៀត។

[១១:០៧:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៨:១២]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះយល់ថា សេចក្តីជំទាស់របស់ -- និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាគឺ សមស្រប។ ដូច្នេះ បើសិនជាចង់តាំងសំណួរអម្បាញ់មិញនេះ សូមលោកមេធាវីសម្រួលនូវសំណួររបស់លោកឲ្យបានសមរម្យឡើងវិញ ទី១។ ទី២ គឺ សូមរំឭកលោកមេធាវីថា គប្បីចៀសវាងនូវសំណួរបែបឧបមាណវិធី រឿងដែលអង្គហេតុមិនកើតហើយឧបមា ឬប្រសិនបើ ដាក់លក្ខខណ្ឌនេះតាំងសំណួរសាក្សីនោះ គឺជាការមិនត្រឹមត្រូវទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំមិនសួរឲ្យលោកធ្វើការសន្និដ្ឋាននោះទេ ហើយខ្ញុំ ដើម្បីឲ្យពន្យល់អំពីរចនាសម្ព័ន្ធ ថាតើវាដំណើរការដូចម្តេច? ឥឡូវនេះ ខ្ញុំនឹងចូលទៅប្រធានបទ ទៅខាងមុខទៀត។ បាទ តពីអ្វីដែលយើងទើបតែបាននិយាយនេះ។ ឥឡូវនិយាយអំពីការប្រជុំ។ ជាប្រធានបទដែលលើកឡើងដោយសហព្រះរាជអាជ្ញាដែរ។ ហើយយើងអាចឃើញនៅក្នុងទំព័រដដែល ដែលលោកបាននិយាយអំពី គឺថាមានការប្រជុំច្រើនៗប្រភេទ។ ហើយនៅក្នុងបរិបទដែលរៀបរាប់អំពីកិច្ចប្រជុំនេះនៅទំព័របន្ទាប់ ហើយខ្ញុំនឹងអាន ERN ជូនលោក គឺខ្មែរ 00832165, បារាំង 00833108 ដល់ 09 , ហើយអង់គ្លេស 00833230។ នៅទីនេះ លោកបាននិយាយថា “ក្រសួងការបរទេសបែងចែកទៅជាពីរផ្នែក។ ផ្នែកមួយគឺជាផ្នែកមន្ទីរ ហើយផ្នែកមួយ គឺជាផ្នែកការិយាល័យ។ ហើយផ្នែកការិយាល័យនោះ គឺទាក់ទងទៅនឹងការបង្កបង្កើតផល សន្តិសុខ ស្បៀងអាហារ ជាឧទាហរណ៍។ ហើយផ្នែកមន្ទីរនោះគឺទាក់ទងអំពីការងារទូត -- កិច្ចការទូត។ ហើយស្ថិតនៅក្រោមអង្គការមួយចំនួន ហើយនិងក្រោមអង្គការសាខាបក្សនានា”។ ហើយខ្ញុំចង់ពិភាក្សាបន្តិចអំពីរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស។ ប្រហែលលោកអាចជួយខ្ញុំដើម្បីបំភ្លឺអំពីបញ្ហាទាំងនេះ។ លោកបានធ្វើការនៅក្នុងផ្នែកមន្ទីរ តាមដែលខ្ញុំយល់ចម្លើយរបស់លោកនោះ គឺទាក់ទងជាមួយនឹងការងារខាងការទូត។ តើជាការសន្និដ្ឋានត្រឹមត្រូវអំពីចម្លើយរបស់លោកដែរឬទេ?

**លោក ស្អួង ស៊ីគឿន៖**

**ឆ៖** មិនត្រឹមត្រូវទេ ផ្ទុយទៅវិញទេបាទ។ គឺថា ប-១ ហ្នឹងក្រសួងការបរទេសចែកជាពីរផ្នែក។ ផ្នែកមន្ទីរ ទាក់ទងនឹងសន្តិសុខ ការបង្កបង្កើតផល ហើយផ្នែកការិយាល័យ គឺទាក់ទងនឹងការងារទូត

ជាក់ស្តែងពិតប្រាកដបាទ។ ដូច្នោះ ខ្ញុំនៅក្នុងផ្នែកការិយាល័យ គឺដែលទាក់ទងនឹងការងារទូត។

[១១:១១:៥៤]

**ស៖** ដូច្នេះ លោកមិនស្ថិតនៅក្នុងផ្នែកការិយាល័យនោះទេ? បាទ អ៊ីចឹងខ្ញុំសូមអនុញ្ញាតបន្តទៅខាងមុខ។ ហើយមើលចំណុចខ្លះនៅក្នុងចម្លើយរបស់លោក--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី! ម៉េចដែរ?

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ អម្បាញ់មិញ សាក្សីគាត់បានបញ្ជាក់ហើយថា គាត់ធ្វើការនៅផ្នែកការិយាល័យ មិនមែននៅផ្នែកមន្ទីរទេ។ អ៊ីចឹងសូមឲ្យគាត់បញ្ជាក់ម្តងទៀត។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា វាមានស្ថានភាពទ្វេគ្រោះនោះទេ។ ហើយខ្ញុំសួរសំណួរ ហើយមិនមានចម្លើយ។ ដូច្នេះបន្តទៅមុខទៀត ដើម្បីកុំឲ្យរាំងស្ទះបាទ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** យើងទៅទំព័របន្ទាប់មួយទៀត គឺទំព័របន្ទាប់ ហើយលោកបានពន្យល់ថា "ផ្នែកការិយាល័យនោះ គឺជាសាខាបក្ស ដែលមានលោកស្រី សួរ សែ ជាលេខាសាខាបក្ស ហើយខ្ញុំជាសមាជិក"។ នេះគឺជាចម្លើយនៅក្នុងប្រតិចារឹក នៅក្នុងទំព័រ៤៤ ឬខ្មែរ ERN 00322165 ដល់ 66, ហើយបារាំង 00383108 ដល់ 09, អង់គ្លេស ERN 00338382 ដល់ 30 -- ដល់ 31 ដែលខ្ញុំចង់ឲ្យលោកបំភ្លឺពីចម្លើយរបស់លោក។ ហើយបន្ទាប់មក នៅក្នុងផ្នែកមួយដែលលោកនិយាយអំពីការប្រជុំរបស់សាខាបក្ស។ នេះនៅលើទំព័រខ្មែរ ERN 00832173 ដល់ 73, បារាំង 00833120 ដល់ 21, អង់គ្លេស 00833240។ ដូច្នេះ ខ្ញុំសូមឲ្យលោកបំភ្លឺបញ្ហាមួយចំនួន។ ថ្ងៃនេះ លោកបាននិយាយថា អ្វីដែលលោកយល់នោះ គឺលោកបានធ្វើការនៅក្នុងមន្ទីរមួយ ហើយនៅក្នុងផ្នែកនោះ មន្ទីរនោះ លោកនៅក្នុងផ្នែកខាងការទូត។ តើត្រឹមត្រូវដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ទៀត ខ្ញុំមិនដឹងគេបកប្រែម៉េចទេ ហើយអម្បាញ់មិញហ្នឹង មេធាវីរបស់ខ្ញុំ

បានបញ្ជាក់ដែរ។ ខ្ញុំក្រសួងការបរទេស ចែកជាពីរ ផ្នែកមន្ទីរ និងផ្នែកការិយាល័យ។ ហើយខ្ញុំធ្វើការនៅផ្នែកការិយាល័យ ដែលជាផ្នែកទទួលបន្ទុកខាងការងារការទូតពិតប្រាកដ បាទ។

**ស៖** ហើយនៅក្នុងពេលដែលមានកិច្ចប្រជុំ តើអ្នកណាជាប្រធានអង្គប្រជុំនៅក្នុងផ្នែកខាងទូតហ្នឹង? នៅក្នុងមន្ទីរ -- នៅក្នុងខាងផ្នែកដែលការទូតហ្នឹង តើអ្នកណាជាប្រធានអង្គប្រជុំ? តើម៉ាដាម សួរ សេ -- លោកស្រី សួរ សែ នោះ ឬក៏អ្នកណា?

[១១:១៥:៥៥]

**ឆ៖** បាទ ជាលោកស្រី សួរ សែ គាត់ជាប្រធានអង្គប្រជុំ ក្នុងឋានៈគាត់ជាលេខារបស់សាខាបក្សបាទ។

**ស៖** នេះគឺជាមនុស្សដដែល ដែលលោកបានបញ្ជាក់ពីខាងដើម ថាលោកបានប្រគល់លទ្ធផលការងាររបស់លោកទៅឲ្យ ដើម្បីឲ្យគាត់បញ្ជូនបន្តទៅ ប៉ុល ពត នៅពេលដែលលោករៀបចំសេចក្តីព្រាងអត្ថបទសម្រាប់ផ្សាយព័ត៌មានឃោសនានោះ?

**ឆ៖** គឺមនុស្សតែមួយ បាទ។

**ស៖** តើខ្លួនលោកផ្ទាល់ -- បាទ ខ្ញុំរៀបឡើងវិញ តើការិយាល័យរបស់លោកហ្នឹង ស្ថិតនៅកន្លែងណា? ឧទាហរណ៍ថា ដែលមានការងារផ្សេងៗខុសគ្នា តើការិយាល័យរបស់លោកនោះកាលនោះនៅកន្លែងណា? ត្រង់ចំណុចណា?

**ឆ៖** ការិយាល័យរបស់ខ្ញុំ គឺនៅគេហៅថា ផ្ទះកោង ផ្ទះកញ្ចក់ ហ្នឹង។ សព្វថ្ងៃហ្នឹង ជាទីស្តីការនាយករដ្ឋមន្ត្រី ហើយបន្ទប់ខ្ញុំផ្ទាល់ហ្នឹង គឺថានៅ ចូលមក គឺថានៅ ចូលពីខាងឆ្វេង -- អ៎! ចូលពីខាងស្តាំមក គឺនៅដើមគេតែម្តង បាទ។ ដូច្នេះ អ្នកដែលចូលមកធ្វើការ ជាកម្មាភិបាលនានា ច្រើនតែមុនចូលទៅក្នុងការិយាល័យរបស់ខ្លួន តែងតែចូលមកក្នុងបន្ទប់ខ្ញុំ បាទ។

[១១:១៧:៥៧]

**ស៖** តើនេះនៅ ប-១ ឬ?

**ឆ៖** បាទ នៅក្នុងបរិវេណ ប-១ ហ្នឹង។

**ស៖** តើលោកអាចប្រាប់ខ្ញុំ ថាតើមានអគារប៉ុន្មាននៅក្នុងបរិវេណ ប-១ នោះ?

**ឆ៖** អគារច្រើនដែរ គឺថាតាមដែលខ្ញុំដឹង អគារដែលជាការិយាល័យ មានតែអគារ ប-១ ហ្នឹងទេ អគារគេហៅថា ផ្ទះកោងហ្នឹង ផ្ទះកញ្ចក់កោងហ្នឹង។ ហើយទន្ទឹមនឹងមានអគារមួយទៀត នៅផ្ទះ

មួយទៀត ជារបៀបរឺឡាមួយជាន់ ក៏ប៉ុន្តែអាហ្នឹងមិនមែនជាការិយាល័យទេ អាហ្នឹងជាកន្លែងនៅ ហើយនៅពីក្រោយហ្នឹង គឺថាមានផ្ទះនៅរបស់កម្មាភិបាល ហើយនិងយុទ្ធជន។ មួយផ្នែកហ្នឹង មានអគារ តាមខ្ញុំដឹង ប្រហែលមានអគារបួនប្រាំទៀត បាទ។

[១១:១៩:១៤]

**សៈ** សូមអរគុណ។ ហើយយើងមើលឯកសារ E3/100 ជាចម្លើយដែលលោកបានផ្តល់នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៧ ហើយលោកបានឆ្លើយមួយចំនួន ហើយខ្ញុំនឹងពិនិត្យខ្លះនេះ។ ចំណុចទី១ ដែលយើងពិនិត្យមើល ខ្មែរ 00204147 ដល់ 48, បារាំង 00344699 ដល់ 700, ហើយអង់គ្លេស 00223636 ឬក៏ទំព័រ៣។ នៅចំណុចនេះ មានសំណួរមួយចំពោះលោក ដើម្បីឱ្យលោកពន្យល់ពីរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងការបរទេស។ ហើយខ្ញុំនឹងពិនិត្យមើលមួយផ្នែក នៃចម្លើយរបស់លោក ហើយសង្ឃឹមថា លោកអាចបំភ្លឺនូវបញ្ហានេះបាន។ លោកនិយាយថា "នៅកាលនោះក្រសួងការបរទេស គេហៅថា ប-១ លោក អៀង សារី ជាប្រធាន ហើយមានលេខា អគ្គលេខាធិការ ហើយនិង សួរ ហុង ជាប្រធានការិយាល័យមួយ។ បាទ គឺ សួរ ហុង។ ការិយាល័យនេះក៏បែងចែកទៅជាផ្នែកសន្តិសុខ ដែលមាន ភី ភួន ហៅ ជាម ជាប្រធាន។ លោកស្រី សួរ សែ ជាប្រធានអគ្គលេខាធិការដ្ឋាន ជាប្រធានផ្នែកពិធីការ ជាលេខាសាខាបក្ស។ ផ្នែកនយោបាយទូទៅ ដែលមានលោក អៀង សារី ជាប្រធានផ្ទាល់។ ក្នុងនោះមានបញ្ញាជនមួយចំនួន ដូចជា ឱក សុគន្ធ, លោក ជួន ប្រសិទ្ធិ និងលោក គាត ឈន់ ជាដើម និងអ្នកដទៃទៀត។ ផ្នែកឃោសនាការ និងព័ត៌មានមានផ្នែក ប្រធានផ្នែកគឺខ្ញុំ ជាអ្នកទទួលខុសត្រូវ។ នៅចុងឆ្នាំ១៩៧៧ លោក នី កន គាត់ជាប្រធានផ្នែកពិធីការទទួលបន្ទុក ទទួលបន្តពីលោកស្រី សួរ សែ។ លោក នី កន ពីមុនគាត់ជាលេខាតំបន់ នៅភូមិភាគបស្ចិម។ ចំពោះផ្នែកការងារបរទេស មានអ្នកទទួលខុសត្រូវដោយឡែកទៀតដែលខ្ញុំមិនបានដឹងទេ"។ ខ្ញុំសូមឈប់ត្រឹមនេះសិន។ តើលោកនៅប្រកាន់ជំហរដែលលោកបានឆ្លើយនេះដដែលទេ ដែលលោករៀបរាប់ថា លោក អៀង សារី ជាប្រធានបន្ទាប់មក លោក សួរ ហុង ជាអគ្គលេខាធិការ ហើយនៅក្រោមគាត់នោះ ភី ភួន គឺជាប្រធានខាងផ្នែកសន្តិសុខ?

[១១:២២:១៥]

**ឆៈ** បាទ ខ្ញុំនៅប្រកាន់ចម្លើយនេះដដែលបាទ។

**សៈ** បាទ ហើយបន្ទាប់ទៅលោករៀបរាប់តទៅទៀតថា "អ្វីដែលលោកស្រី សួរ សែ បានធ្វើ

ជាប្រធាននៃលេខាធិការដ្ឋាន ហើយនិងជាប្រធានពិធីការ ហើយនិងជាលេខាសាខាបក្ស"។ ខ្ញុំមើលឃើញថា ចម្លើយនេះគាត់មានតំណែងបី ខុសៗគ្នា។ តើត្រូវអ៊ីចឹងឬទេ?

**ឆ៖** បាទត្រូវហើយបាទ។

**ស៖** ឥឡូវនេះ នៅពេលមួយយើងនឹងពិភាក្សាឡើងវិញ ហើយលោកបាននិយាយប្រាប់ខ្ញុំថា លេខានៅទូត ហើយជាមនុស្សសំខាន់ជាងអគ្គរដ្ឋទូត តើលោកនៅចាំថាបានឆ្លើយបែបនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយយ៉ាងដូច្នេះ។

**ស៖** តាមពិត ដើម្បីកត់ត្រារបស់តុលាការ គឺរកចម្លើយនេះ នៅក្នុងខ្មែរ 00832199 ដល់ 200។ ខ្ញុំគិតថា អ៊ីចឹង។ អង់គ្លេស 00833273 ដល់ 274, បារាំង 00833160 ដល់ 02។ បាទ ហើយខ្ញុំមាន ឲ្យលោកបំភ្លឺថាតើគាត់ស្មើ មានឋានៈស្មើទៅនឹងលេខានៅក្នុងស្ថានទូតនៅនីមួយៗហ្នឹងដែរឬទេ?

[១១:២៤:២៤]

**ឆ៖** លោកប្រធាន សូម -- លោកប្រធាន សូមឲ្យលោកមេធាវីបញ្ជាក់បន្តិចគឺថា ចង់និយាយប្រដូចលេខាបក្សនៅក្នុងស្ថានទូត ជាមួយនឹងលោកស្រី សួរ សែ ជាលេខារបស់សាខាបក្សអីបាទ?

**ប្រធានអង្គជំនុំ៖**

មេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ដើម្បីឲ្យកាន់តែច្បាស់លាស់ ពីព្រោះសាក្សីមិនទាន់ស្តាប់បាននូវខ្លឹមសារនៃសំណួរដែលលោកសួរទេ។ ហើយសូមបញ្ជាក់ឲ្យបានច្បាស់លាស់រវាងលេខា ឬក៏ជាប្រធានអង្គភាពនេះ ព្រោះគាត់តួនាទីជាប្រធានអង្គភាពផង ជាលេខាបក្សផង ហើយទូតដូចគ្នា ពីព្រោះសាក្សីបាននិយាយច្រើនលើកច្រើនសាហើយ រវាងការងារទូត ជាឯកអគ្គរដ្ឋទូត ហើយនិងលេខាទូត លេខាធិការ -- លេខាបក្សនៅប្រចាំទូតនីមួយៗនោះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។ នេះជារកាបំភ្លឺដែលខ្ញុំចង់បាននោះឯង ហើយខ្ញុំមិនព្យាយាមបង្កើតអំណាច ឬក៏ឥទ្ធិពលអ្វីនោះទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ហើយខ្ញុំសួរម្យ៉ាងទៀត។ តើមុខងាររបស់គាត់ហ្នឹងពិតប្រាកដជាអ្វីនៅក្រសួងការបរទេសដែលលោកយល់ច្បាស់នៅកាលនោះ?

[១១:២៦:០២]

**លោក សួង ស៊ីគៀន៖**

**ឆ៖** តាមខ្ញុំដឹងលោកមេធាវីចង់សួរពីភារកិច្ចរបស់លោកស្រី សួរ សែ មែនឬទេបាទ?

**ស៖** បាទ។ បាទ នៅក្នុងសមត្ថភាពជាច្រើនរបស់គាត់។

**ឆ៖** ជាក់ស្ដែងគឺគាត់ជាលេខាបក្ស ក៏ប៉ុន្តែគ្មានអំណាចអីទេ ព្រោះនៅពីលើគាត់មានលោក សួរ ហុង ហើយមានលោក អៀង សារី។ ដូច្នោះគាត់មិនមានអំណាចអីទេ គឺជាលេខាបក្សគ្រាន់តែដឹកនាំប្រជុំប៉ុណ្ណឹងទេបាទ ហើយរាយការណ៍លទ្ធផលនៃការប្រជុំហ្នឹងជូនទៅលោក អៀង សារី ឬ លោក សួរ ហុង ។ អាហ្នឹងខ្ញុំមិនបានដឹងទេ មិនដឹងគាត់រាយការណ៍អ្នកណា ជូនអ្នកណាច្បាស់ទេបាទ។ មុខងារដែលសំខាន់របស់គាត់ គឺទទួលខុសត្រូវខាងផ្នែកអគ្គលេខាធិការដ្ឋាន ព្រោះអគ្គលេខាធិការដ្ឋានវាទទួលច្រើនមុខដែរ។ ទទួលខាងការរៀបចំឯកសារ ទទួលការខាងរៀបចំទទួលភ្ញៀវ ទទួលស្អីៗដែលជាផ្នែកសម្ភារៈ ហើយនិងផ្នែកពិធីការក៏ដូច្នោះដែរ ព្រោះផ្នែកទាំងពីរនេះមមាញឹកណាស់បាទ។

[១១:២៧:៣០]

**ស៖** សូមអរគុណ។ ហើយនៅខាងក្រោមទៅទៀត មុននឹងទៅដល់នោះគឺថា លោកបាននិយាយពីលោក សួរ ហុង តើលោកយល់អ្វីខ្លះអំពីមុខងាររបស់គាត់ ថាតើគាត់ទទួលខុសត្រូវដូចម្ដេចដែលក្នុងឋានៈគាត់ជាអគ្គលេខាធិការនោះ? ហើយនិងជាប្រធានមន្ទីរមួយនោះ?

**ឆ៖** តាមពិតទៅខ្ញុំមិនដឹងគាត់ គេថាអគ្គលេខាធិការអី ប៉ុន្តែគាត់មិនមានទាក់ទងផ្ទាល់ជាមួយផ្នែកការិយាល័យ គឺថាផ្នែកការងារទូតទេ ហើយៗគាត់ដូចមិនមានអីជំពាក់ជំពិន គាត់ទាក់ទងផ្ទាល់តែផ្នែកមន្ទីរទេបាទ។ ខាងការបង្កបង្កើនផល សន្តិសុខ ទាក់ទងពីភ្ញៀវ ព្រោះភ្ញៀវអញ្ជើញមកកម្ពុជាប្រជាធិបតេយ្យជាបន្តបន្ទាប់ហ្នឹង គឺគាត់ទទួលជាមួយលោក ភី ភួន ហើយនិងកម្មាភិបាលមួយចំនួនទៀតបាទ។

[១១:២៨:៤៧]

**ស៖** បាទ ខ្ញុំស្ដាប់លោកពីចំណុចមួយនៅក្នុងឆ្នាំ២០០២ លោកបានដឹងថា ភី ភួន គឺជាប្រធានផ្នែកខាងសន្តិសុខ តើលោកស្គាល់ទេនៅក្នុង -- លោកដឹងស្គាល់គាត់ទេ ក្នុងសម័យនោះ?

**ឆ៖** ខ្ញុំស្គាល់លោក ភី ភួន នៅពីឆ្នាំ១៩៧៥ ពេលដែលខ្ញុំទៅធ្វើការក្នុងក្រសួងការបរទេស ពេលនោះគេប្រាប់ខ្ញុំថា គាត់ទទួលសន្តិសុខការពារស្ថានទូតបរទេស និងបុគ្គលិកទូតបរទេសមកពីខាងក្រៅ មកប្រចាំនៅកម្ពុជាប្រជាធិបតេយ្យបាទ។ គេប្រាប់ខ្ញុំតែប៉ុណ្ណឹងទេបាទ។

**ស៖** សូមអរគុណ។ ប៉ុន្តែខ្ញុំមើលឃើញនៅក្នុងចម្លើយរបស់លោក គឺថាស្គាល់គាត់ជាប្រធាននៃផ្នែកសន្តិសុខ មន្ទីរសន្តិសុខ តើលោកស្គាល់គាត់ក្នុងឋានៈជាផ្នែកសន្តិសុខ ជាប្រធានសន្តិសុខទេ នៅក្នុងសម័យនោះបាទ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា នៅសម័យនោះខ្ញុំស្គាល់គាត់គឺក្នុងឋានៈគាត់ គឺថាទទួលសន្តិសុខខាងស្ថានទូត។ ប៉ុនសន្តិសុខអីផ្សេងទៀត ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ឥឡូវនេះ ឥឡូវយើងពិនិត្យមើលលោក សួរ ហុង ក្នុងពេលបន្តិចទៀត។ ចម្លើយរបស់លោកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ ខ្ញុំយោងទៅរកឯកសារ E3/372 ខ្មែរនៅទំព័រ 00290420 ដល់ 21, បារាំង 00290431 ដល់ 32, ហើយនិងអង់គ្លេស 00290426។ ហើយនៅកន្លែងនេះមានសំណួរចំពោះលោក "តើរចនាសម្ព័ន្ធនេះគាំទ្រ ឬក៏ស្ថិតនៅក្រោមលោក អៀង សារី ដែរឬទេ មានន័យថាការិយាល័យ ហើយនិងៗមន្ទីរ?" លោកបានឆ្លើយថា "ជាគោលការណ៍ បាទ។ ប៉ុន្តែក្នុងការអនុវត្តដោយសារថា ប៉ុល ពត ក្មួយ ប៉ុល ពត ជាប្រធាននៃមន្ទីរ គឺមន្ទីរនេះគឺថា -- បុគ្គលនេះអាចសម្រេចអ្វីបានដោយមិនចាំបាច់ឆ្លងតាម អៀង សារី ទេ។ ហើយដូចគ្នានេះដែរចំពោះផ្នែកការទូត"។ ហើយលោកបានឲ្យឧទាហរណ៍ តើលោកបានឃើញផ្នែកដែលខ្ញុំនិយាយនេះទេ លោកសាក្សី?

[១១:៣២:០៥]

**ឆ៖** បាទ ៗខ្ញុំបានឃើញផ្នែកនេះបាទ។

**ស៖** ឥឡូវនេះលោកបានឆ្លើយប្រាប់ខ្ញុំថា សួរ ហុង គឺជាក្មួយរបស់ ប៉ុល ពត នេះជាចម្លើយរបស់លោកឆ្នាំ២០០៩។ តើលោកបានដឹងថា គាត់ជាក្មួយរបស់ ប៉ុល ពត ដែរឬទេ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ នោះ? តើលោកបានព័ត៌មានហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំដឹងបាទ។

**ស៖** តើលោកមានដឹងទេ គាត់មានទំនាក់ទំនងយ៉ាងម៉េចដែរជាមួយនឹងពូរបស់គាត់ គឺ ប៉ុល ពត នេះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ខ្ញុំដឹងក្រោយមកទេ។ ដឹងក្រោយ៧៩ ទេ ហើយអ្នកដែលគេប្រាប់ខ្ញុំហ្នឹងក៏គេអ្នកជិតស្និទ្ធដែរ គឺ -- ហើយតាមខ្ញុំសង្កេតមើល គឺការជាក់ស្តែង ប៉ុល ពត គាត់មិនចូលចិត្ត សួរ ហុង ទេ។ ព្រោះអ្វី? ព្រោះ សួរ ហុង គាត់មនុស្ស បើយើងថា មនុស្សកណ្តាល គាត់មិនសូវស្រួចទេ។ ហើយគេប្រើពាក្យថា គាត់មិនមែនជាមនុស្សអណ្តែតទេ។ ពាក្យសម្តីរបស់គេ។ ដូច្នោះ គាត់មិនមានទុក

ចិត្តអីប៉ុន្មានទេ។ ហ្នឹងតាមដែលគេប្រាប់ខ្ញុំ ហើយការពិតជាក់ស្ដែងក៏ខ្ញុំមិនដឹងដែរបាទ។

[១១:៣៣:៤៧]

**ស៖** ខ្ញុំសូមសួរទៅលោក ថាតើអ្នកណាប្រាប់លោកចំពោះព័ត៌មាននេះ ហើយប្រាប់នៅពេលណាដែរ?

**ឆ៖** លោកប្រធាន -- លោកមេធាវី ខ្ញុំអាចមិនប្រាប់ មិនឆ្លើយនឹងសំណួរនេះបានទេបាទ?

**ស៖** បាទ មិនជាបញ្ហាអីទេ ខ្ញុំគោរពតាមចិត្តរបស់លោក។ ឥឡូវនិយាយអំពីឆ្នាំ៧៥ ដល់៧៩ វិញម្ដង តើលោកអាចមានលទ្ធភាពកត់សម្គាល់ទៅលើទំនាក់ទំនងរបស់គាត់ជាមួយនឹងពូរបស់គាត់ទេនៅពេលនេះ ប្រសិនណាជាមានទំនាក់ទំនងណាមួយ លោកមានបានកត់សម្គាល់ទំនាក់ទំនងនោះទេ?

**ឆ៖** តាមខ្ញុំសង្កេតមើល ហើយអាចខ្ញុំមិនចាំអស់ទេ ព្រោះវាយូរហើយ។ ប៉ុន្តែនៅពេលដែលខ្ញុំទៅធ្វើការម្ដងៗ ម្ដងម្យាមជាមួយ ប៉ុល ពត ដូចមិនមានវត្តមានរបស់លោក សួរ ហុង ទេ។ មានវត្តមានតែលោក អៀង សារី ប៉ុណ្ណោះ។ ការណ៍នេះអាចយល់បានដែរ ពីព្រោះគាត់មិនទាក់ទងក្នុងការងារទូតៗផ្ទាល់នោះទេ។ ហើយអ្វីៗដែលយើងខ្ញុំទាក់ទងជាមួយលោក ប៉ុល ពត ហ្នឹង គឺច្រើនជាការងារទូតដូចជាធ្វើៗរៀបចំសៀវភៅៗខ្មៅ ចេញនៅខែកញ្ញា ១៩៧៧ ជាដើមបាទ។

**ស៖** សូមអរគុណលោក។ នៅពេលដែលលោកនិយាយថា នេះគឺជាអ្វីដែលវាមានន័យថាអ៊ីចឹងតើលោក -- នេះមិនមែនជាការសន្និដ្ឋានរបស់លោកទេឬ?

[១១:៣៦:០៣]

**ឆ៖** ខ្ញុំសូម--

**ស៖** បាទនេះ គឺជាសំណួរហើយលោកសាក្សី តើៗលោកមិនមែនឆ្លើយស្មានៗឬ?

**លោក សួង ស៊ីគឿន៖**

ខ្ញុំ -- លោកប្រធាន ខ្ញុំមិនសូវយល់សំណួរគាត់ទេបាទ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** បាទ ខ្ញុំសូមបន្តទៅមុខទៀត មួយជំហានម្ដងៗ ។ តើលោកដឹងទំនាក់ទំនងរបស់ សួរ ហុង ទំនាក់ទំនងការងាររបស់ សួរ ហុង ជាមួយ ភី ភួន ដែលហៅថា ជាម នោះដែរឬទេ មុនឆ្នាំ១៩៧៥?

**លោក សួង ស៊ីគឿន៖**

**ឆ៖** មុន១៩៧៥ ខ្ញុំមិនបានដឹងទេ ខ្ញុំមិនទាំងស្គាល់អ្នកពីរហ្នឹងផងបាទ។

[១១:៣៦:៥៥]

**ស៖** តើលោកមានដែលបានដឹងទេ នៅពេលគឺចន្លោះពី៧៥ ទៅ៧៩ ហ្នឹង ថាតើបុគ្គលទាំងពីរហ្នឹងដែលធ្លាប់ធ្វើការជាមួយគ្នាទេ មុនឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំមិនបានដឹងទេ។ ដូចខ្ញុំជម្រាបហើយ ខ្ញុំមិនទាំងស្គាល់អ្នកទាំងពីរហ្នឹងផងមុន១៩៧៥ នោះ។

**ស៖** សំណួររបស់ខ្ញុំ ថាតើលោកធ្លាប់បានឮពីអ្នកណានៅចន្លោះ៧៥ ទៅ៧៩ ហ្នឹង ថាតើអ្នកទាំងពីរហ្នឹងធ្លាប់ធ្វើការជាមួយគ្នាទេ? បើតាមខ្ញុំយល់ ចម្លើយរបស់លោក លោកថាមិនដឹងទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** ថាតើលោកដឹងថា បុគ្គលទាំងពីរហ្នឹងនៅមុនឆ្នាំ៧៥ មានទំនាក់ទំនងអីជាមួយនឹង ប៉ង់ ដែរទេ?

**ឆ៖** ខ្ញុំក៏មិនដឹង--

[១១:៣៨:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយ!

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សាក្សីទើបតែឆ្លើយថា គាត់មិនស្គាល់ សួរ ហុង ឬ ជាម មុនឆ្នាំ៧៥ទេ។ ដូច្នេះ គាត់មិនដឹងថាពួកគេធ្វើជាមួយគ្នាទេ។ ឥឡូវនេះសួរគាត់ទៀត ថាតើគាត់ដឹងថាមានទំនាក់ទំនងជាមួយ ប៉ង់ នោះ។ ខ្ញុំគិតថា សាក្សីមិនអាចឆ្លើយទៅនឹងសំណួរនេះបានទេ គាត់មិនស្គាល់បុគ្គលទាំងនេះទេមុនឆ្នាំ៧៥ នោះ។ ការសួរសំណួរដែលសាក្សីមិនអាចផ្តល់ចម្លើយបាននោះ ខ្ញុំគិតថាមិនគួរអាចអនុញ្ញាតទេ ហើយវាគ្មានប្រយោជន៍អីទេនៅចំពោះមុខតុលាការនេះ។

[១១:៣៩:១២]

**លោក ម៉ៃខល កាណាវាស៖**

នេះកំពុងឲ្យចម្លើយសាក្សី។ ខ្ញុំសួរទៅគាត់ ថាតើគាត់ធ្លាប់បានដឹង ធ្លាប់ឮពីអ្នកណាម្នាក់ចន្លោះ

ពី៧៥ ទៅ៧៩ ពីព្រោះគាត់ធ្វើការនៅប-១។ ហើយជាក់ស្តែងទៅប្រហែលជាគាត់អាចនឹងបានដឹងព័ត៌មានណាមួយចន្លោះពេលហ្នឹង។ សំណួរខ្ញុំសួរថា តើគាត់ធ្លាប់បានដឹងទេ ដែលយើងសួរ ប៉ង់ នៅមន្ទីរ ៨៧០ ហើយខ្ញុំសូមឱ្យគាត់រៀបរាប់អំពីទំនាក់ទំនងរវាងអ្នកទាំងពីរនេះ។ អ៊ីចឹងសំណួរខ្ញុំ ថាតើគាត់ធ្លាប់បានឮពីអ្នកណា ឬក៏អត់? បើធ្លាប់ ថាធ្លាប់ បើមិនធ្លាប់បានដឹង ថាមិនធ្លាប់បានដឹង នោះខ្ញុំនឹងបន្តទៅមុខទៀត។

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ សហការីខ្ញុំប្រាប់ថា ពាក្យថា ពីភាសាខ្មែរ *ឡើណើង-ណូរឹង* ហ្នឹងគឺថា ជា១ វាមានន័យតែមួយទេ អ៊ីចឹងខ្ញុំសូមអធ្យាស្រ័យបើសិនណា សូមអធ្យាស្រ័យបើសិនណាជា ខ្ញុំលើកពាក្យពេចន៍ហ្នឹងមកដូចថាវាមិនសមហេតុសមផលណាមួយនោះ។ បាទ ប៉ុន្តែមិនជាអ្វីនោះទេ។ តើលោកដឹងទេចន្លោះពី ៧៥ ទៅ ៧៩ ថាតើ សួរ ហុង មានទំនាក់ទំនងណាមួយជាមួយ ប៉ង់ ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** សំណួរដដែលនេះគឺថា មាន -- ចុះទំនាក់ទំនងជាមួយ ជាម, ភី ភួន នេះវិញម្តង តើលោកដឹងថា ភី ភួន មានទំនាក់ទំនងណាមួយដោយផ្ទាល់ ឬក៏ដោយប្រយោលជាមួយ ប៉ង់ ដែរឬទេ?

**ឆ៖** ខ្ញុំក៏មិនបានដឹងដែរបាទ។

[១១:៤១:៣៥]

**ស៖** តើលោកអាចជម្រាបជូនទៅតុលាការបានទេថា តើ ភី ភួន -- តើការិយាល័យមន្ទីររបស់ ភី ភួន នៅត្រង់កន្លែងណាដែរ?

**ឆ៖** ការិយាល័យរបស់ ភី ភួន នៅច្រើនកន្លែងណាស់ មែនទែននោះអត់មានអីទេ មានឈ្មោះគាត់មួយហ្នឹង។ គ្មានការិយាល័យទេ លោកមេធាវី។

**ស៖** មានន័យថាគាត់ធ្វើការ ចេះតែធ្វើការពីកន្លែងមួយទៅកន្លែងមួយអ៊ីចឹង ឬក៏យ៉ាងម៉េច រួមទាំង១កន្លែងលោកផង?

**ឆ៖** គាត់ មើលទៅគាត់មានតែកន្លែងសម្រាកប៉ុណ្ណឹងបាទ។ ហើយគាត់ដើរពីកន្លែងមួយទៅកន្លែងមួយ ដើម្បីបំពេញភារកិច្ចរបស់គាត់បាទ។

**ស៖** នៅពេលដែលគាត់អណ្តែតអ៊ីចឹង ធ្វើការបែបអណ្តែតអ៊ីចឹង ពីទៅ១កន្លែងអគារដែល

លោកមានការិយាល័យរបស់លោកនៅទីនោះ?

**ឆ៖** បាទ គាត់ធ្លាប់ទៅដែរ ទៅ ប៉ុន្តែគ្រាន់តែចូលលេងអ៊ីចឹង សួរសុខទុក្ខមួយម៉ាត់ពីរ គាត់ទៅទៀតបាទ។

[១១:៤៣:១៣]

**ស៖** ដូច្នេះ តាមចម្លើយរបស់លោកនេះពី ៥៧ ទៅ ៧៩ នៅពេលដែលគាត់អណ្តែតពីការិយា-ល័យមួយទៅការិយាល័យមួយដែលលោកធ្វើការនោះ តើលោកដែលមានឱកាសណាមួយបានជួប ឬក៏បាននិយាយជាមួយ ភី ភួន ហៅ ជាម នេះដែរឬទេ?

**ឆ៖** ខ្ញុំប្រាកដជាខ្ញុំបាននិយាយអីជាមួយគាត់ហើយ ប៉ុន្តែខ្ញុំអត់បានចាំថានិយាយអីទេ ប៉ុន្តែគ្រាន់តែថាការដែលនិយាយនេះ ការនិយាយធម្មតាទេក្នុងឋានៈជាមិត្តភាពអ៊ីចឹងទេ មិនមានចូលក្នុងកិច្ចការអីទេ។

**ស៖** ហេតុអ្វីក៏លោកមិនអាចសួរអំពីតួនាទីភារកិច្ចរបស់គាត់? ហេតុអីក៏លោកមិនអាចសួរសំណួរបែបនេះបាន?

**ឆ៖** អាហ្នឹងវាចូលក្នុងគោលការណ៍របស់កម្ពុជាប្រជាធិបតេយ្យ។ "អ្នកណាធ្វើការនៅកន្លែងណា ដឹងតែកន្លែងនោះ មិនត្រូវដឹងពីកិច្ចការ ឬអ្វីដែលក្រៅពីនេះទេ" បាទ។ ដូច្នេះ បើខ្ញុំសួរទៅ ភី ភួន វាមានន័យថា ខ្ញុំមិនគោរពគោលការណ៍របស់បក្ស។ ដូច្នោះអ្វីដែលខ្ញុំខ្លាច មិនមែនខ្លាចបក្សអីប៉ុន្មានទេ ខ្លាច ភី ភួន ហ្នឹង ដែលខ្ញុំស្រឡាញ់រាប់អានហ្នឹង វិនិច្ឆ័យចំពោះខ្ញុំថា ខ្ញុំហ្នឹងជាបក្ខជនបបរ។ ដូច្នោះខ្ញុំមិនមានអីទៅចង់សួរគាត់ទេ ពីបញ្ហានេះបាទ។

[១១:៤៥:១៤]

**ស៖** នេះ គឺខ្ញុំងាកសួរទៅពីបញ្ហាខាងដើម អំពីបញ្ហារក្សាការសម្ងាត់ ហើយនិងពាក្យស្លោកថា "ការរក្សាការសម្ងាត់" នេះ គឺមានន័យថា បើបដិវត្តន៍ឈ្នះបាន ៥០ភាគរយនេះជាគោលការណ៍។ តើអ៊ីចឹងមែនទេ ដែលថាដឹងតែអ្វីដែលខ្លួនឯងធ្វើបានហើយ ហើយកុំដឹងរឿងគេ។ តើអ៊ីចឹង ឬក៏យ៉ាងណា? សំណួរគឺសួរថា តើអ្វីកើតមានចំពោះលោក ប្រសិនណាជាលោកសួរទៅការងាររបស់គាត់នោះ។ ឥឡូវខ្ញុំសូមកែសម្រួលសំណួរវិញ។ បើសិនណាជាគាត់បង្ហាញព័ត៌មាន មកឲ្យលោកវិញ ដែលលោកមិនត្រូវមានសិទ្ធិដឹងនោះ តើគេអនុញ្ញាតឲ្យគាត់ប្រាប់ព័ត៌មានមកលោកទេ?

**ប្រធានអង្គជំនុំ៖**

គ្មានសំណួរ ប្រសិនបើទេ។ មិនអនុញ្ញាតឲ្យឆ្លើយទៅនឹងសំណួរឧបមានវិធីបែបនេះទេ។

**លោក ម៉ៃខល កាណាវាស៖**

**ស៖** ថាតើគោលការណ៍ហ្នឹង អនុវត្តចំពោះអ្នកដទៃទៀតទេ មិនត្រឹមតែសួរព័ត៌មានពីអ្នកដទៃ មានន័យថា ផ្តល់ព័ត៌មានទៅដល់អ្នកដទៃវិញម្តង។ តើគោលកាណ៍អនុវត្តតាំងពីអី តាមបទពិសោធន៍ ការងារផ្ទាល់របស់លោក? សូមលោកជម្រាបតុលាការផង។

[១១:៤៦:៥៧]

**លោក សួង ស៊ីគឿន៖**

**ឆ៖** អាហ្នឹងអនុវត្តចំពោះគ្រប់គ្នាបាទ។ យើងមិនចង់ដឹងព័ត៌មានពីគេ ហើយគេក៏មិនមានសិទ្ធិ អី មិនមានការចាំបាច់អី ផ្តល់ព័ត៌មានដល់យើងក្រៅក្របខ័ណ្ឌនៃភារកិច្ចដែលយើងបំពេញទេបាទ។

**ស៖** ចុះបើសិនណាជាលោកត្រូវបង្ហាញព័ត៌មានដែលជាព័ត៌មានសម្ងាត់ ព័ត៌មានលាក់ការណ៍ ដែលលោកធ្វើលើកិច្ចការហ្នឹង ថាតើវាត្រូវមានការប្រុងប្រយ័ត្នអីដែលទេ ដែលត្រូវមានការប្រុងប្រយ័ត្ន មុនហ្នឹងផ្តល់ ឬក៏យ៉ាងណានោះទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន គឺថាសំណួរដដែលទេ សួរថាប្រសិន បើសិនផ្តល់ព័ត៌មាននោះ គឺថា សំណួរ ឧបមានវិធីទៀតហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ត្រឹមត្រូវ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ។

[១១:៤៨:១៩]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹង -- សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបង្ហាញជូន -- រវល់ពេលដែលសហព្រះរាជអាជ្ញា ឡើងជំទាស់មកខ្ញុំ បើមិនទេយើងមិនអាចបានចម្លើយពីសាក្សីណាមួយទេ។ នេះគឺដោយសារថា សំណួរ ចាប់ផ្តើម ជាមួយនឹង “ប្រសិនបើ” មិនមែនមានន័យថា ស្មានទេ គឺ-- ខ្ញុំមិនដឹងទេជាភាសាបរទេសដទៃ

ទៀត តែភាសាអង់គ្លេស គឺនិយាយអំពីរបៀបរបបធ្វើការ នីតិវិធីធ្វើការ ការណែនាំ គាត់អ្នកធ្វើការនៅខាងក្នុង ដូច្នេះ គាត់អាចដឹង។ ចុះថាបើសិនណាជាគាត់សួរសំណួរបែបហ្នឹង មានអ្វីកើតឡើងចំពោះគាត់ បើគាត់ផ្តល់ព័ត៌មានសម្ងាត់ណាមួយទៅឱ្យអ្នកដទៃ ដោយយោងទៅលើបទពិសោធន៍ការងារ និងចំណេះដឹងរបស់គាត់នោះ។ ខ្ញុំសម្រេចទទួលយកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ខ្ញុំយល់ស្រប។ ខ្ញុំសូមគោរព។ សូមអរគុណលោកប្រធាន។

[១១:៤៩:១៧]

**សួរដោយលោក ម៉ៃខល ការណាវាស៖**

**ស៖** ឥឡូវនេះខ្ញុំសូមទៅសក្ខីកម្មមួយផ្នែកទៀតរបស់លោកដែលមាន ERN 00832171 ទៅ 72, ជាភាសាបារាំង 00833119, ជាភាសាអង់គ្លេស 00833238 ដល់ 39។ គឺប្រតិចារឹកចុះខែសីហា ថ្ងៃទី០៦ គឺគេបានសួរទៅលោកថា នៅពេលដែលមានសំណួរតាំងមករកលោក លោកបានឆ្លើយទៅនឹងព្រឹត្តិការណ៍សំខាន់ៗថា៖ “នៅពេលមានព្រឹត្តិការណ៍សំខាន់ៗ ពួកគេអាចចែកព័ត៌មានគ្នានៅក្នុងកិច្ចប្រជុំ ហើយនៅបន្តនិយាយតទៅទៀត ចំពោះសំណួរបន្ទាប់ថា “ខ្ញុំមិនបានចាំថានោះទេ វាពាក់ព័ន្ធទៅនឹងការរក្សាការសម្ងាត់របស់គណៈមជ្ឈិមបក្ស។ ប៉ុន្តែលោកនិយាយថា វាជាសេចក្តីសម្រេចរបស់គណៈមជ្ឈិម”។ ប៉ុន្តែលោកបែរជានិយាយថា “វាជាសេចក្តីសម្រេចរបស់មជ្ឈិម ជាសេចក្តីសម្រេចរួមរបស់បក្ស”។ ដូច្នេះដោយលើកឡើងនៅចំណុចទាំងនេះ ហើយឧបមាថា គេប្រើពាក្យ ឧបមាថា តើលោកអាចជម្រាបបានទេ ថាតើ ថានេះគឺជាសេចក្តីសម្រេចរួម នៅពេលដែលលោកបាន គឺថាយោងតាមសំណួររបស់សហព្រះរាជអាជ្ញាថា លោកមិនដែលបានចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ម្តងណាទេ។ តើលោកមិនស្មានទេនៅពេលដែលលោកនិយាយថា នេះគឺជាសេចក្តីសម្រេចរួម? តើនេះលោកមិនស្មានទេឬ?

[១១:៥១:២៩]

**លោក ស្វង ស៊ីគៀន៖**

បាទ លោកប្រធាន ខ្ញុំមិនយល់ន័យរបស់ពាក្យ “ស្មាន” ហ្នឹងបាទ។ ហើយបកប្រែថា ស្មាន។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីតាំងសំណួរសាជាថ្មី ពីព្រោះមានពាក្យ “ស្មាន” ផង។ មានពាក្យ “ឧបមា” នៅក្នុងនោះផង។ ឧបមា, ឧបមាណវិធីក្នុងការតាំងសំណួរ អង្គជំនុំជម្រះមិនឱ្យឆ្លើយទេ។ មិនឱ្យសាក្សី

ឆ្លើយតបនឹងសំណួរបែបឧបមាណវិធីទេ។ សំណួរអំមិញនេះ ជាភាសាខ្មែរមានទាំងឧបមា។ ឥឡូវនេះ សាក្សីមានពាក្យថា "ស្មាន" ទៀត ដែលគាត់មិនយល់។ សូមលោករៀបចំសំណួរឡើងវិញ។ តាំងសំណួរ គប្បីសម្រួលធ្វើយ៉ាងណាឲ្យច្បាស់ ខ្លី ហើយគោលដៅដែលទទួលសំណួរនោះ អាចយល់ខ្លឹមសារបាន ហើយនឹងអាចឆ្លើយតបបាន។ មិនមែនពូកែសួរ ដោយសារសួរទៅ ឲ្យគោលដៅដែលឆ្លើយហ្នឹងឆ្លើយមិនរួច មានន័យថាពូកែសួរនោះទេ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវយើងចាប់ផ្តើមមួយជំហានម្តងៗបន្តទៅទៀត។ សហព្រះរាជអាជ្ញាសួរថា "តើលោកធ្លាប់បានចូលក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍អ៊ីចឹងឬទេ? ឬក៏ថាគឺគេបានផ្តល់ព័ត៌មានបែបនេះអំពីកិច្ចប្រជុំនេះទេ?" ហើយចម្លើយដែលលោកឆ្លើយគឺថា "អត់ទេ អត់ដែលបានចូលប្រជុំទេ"។ តើលោកប្រកាន់យកចម្លើយនេះទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំប្រកាន់យកចម្លើយ។

[១១:៥៣:៣៥]

**ស៖** ហើយដើម្បីជាប្រតិចារឹក ខ្ញុំសូមមើលទៅលើឯកសារ 00832200, ជាភាសាបារាំង 00833162, ជាអង់គ្លេស 00833274។ ឥឡូវសូមចូលទៅមើលចម្លើយរបស់លោកនៅត្រង់ផ្នែកនេះ នៅពេលដែលគេសួរមកលោកអំពីបញ្ហាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ គឺសួរព័ត៌មានពីបញ្ហាកិច្ចប្រជុំនៃ -- សំណួរថា "តើលោកអាចចាំបានទេថា ពីពេលមួយទៅពេលមួយ លោក អៀង សារី នោះនិយាយអំពីសេចក្តីសម្រេចដែលបានសម្រេចឡើងដោយគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា?" នេះគឺជាសំណួរដែលបានសួរទៅលោក។ ហើយចម្លើយរបស់លោកនោះគឺ "ខ្ញុំមិនចាំមិនច្បាស់ទេ។ ប៉ុន្តែគឺគាត់មិនបានប្រាប់ខ្ញុំអ៊ីចឹងច្រើនដងយូរទេ យូរៗម្តង ហើយសេចក្តីសម្រេចអ៊ីចឹង។ ប៉ុន្តែគាត់មិនដែលថាសេចក្តីសម្រេចគណៈអចិន្ត្រៃយ៍អ៊ីចឹងទេ។ គឺច្រើននិយាយអំពីសេចក្តីសម្រេចរបស់បក្សនិយាយជាបក្សរួមតែម្តង។ ដូច្នេះ នេះគឺជាសេចក្តីសម្រេចជាសមូហភាពដោយបក្សតែម្តង"។ អ៊ីចឹងអ្វីដែលខ្ញុំចង់ផ្តោតនោះ គឺទៅលើចំណុចចុងក្រោយ លោកថា "ដូច្នេះ វាគឺសេចក្តីសម្រេច ជាសេចក្តីសម្រេចរួម

របស់បក្សតែម្តង”។ បើលោកមិនដែលបានចូលប្រជុំក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ម្តងណាផងនោះ ថាតើធ្វើម៉េចបានជាលោកដឹងថា នេះជាសម្រេចជារួម ជាសមូហភាពតែម្តងនោះ?

**ឆ៖** ទេ ខ្ញុំបានឆ្លើយថា លោក អៀង សារី មិនប្រាប់ខ្ញុំ -- មិនបានប្រាប់ខ្ញុំថាជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទេ។ ហើយខ្ញុំថា ដូចថាមិនចាំច្បាស់ទេ គឺគ្រាន់ថាអានេះជា ដែលគាត់និយាយនោះ គឺជាសេចក្តីសម្រេចរួមរបស់បក្សតែម្តង។ ត្រង់ថា បក្សរួមជាអ្នកណានោះ ខ្ញុំក៏មិនបានដឹងដែរ ប៉ុន្តែគ្រាន់តែតាមទម្លាប់ តែសេចក្តីសម្រេចរបស់ ប៉ុល ពត ខ្លួនឯងផ្ទាល់ ខ្លួនលោកតែម្នាក់ឯង ក៏ជាសេចក្តីសម្រេចរបស់បក្សដែរបាទ។ ហើយអ្នកឯទៀត ដែលសមាជិកឯទៀត ក៏ឯកភាពចំពោះសេចក្តីសម្រេចនេះដែរ បាទ។

[១១:៥៦:២៧]

**ស៖** ខ្ញុំសូមត្រឡប់ថយទៅក្រោយបន្តិច ថ្ងៃនេះ លោកផ្តល់សក្ខីកម្មថា ប៉ុល ពត គឺធ្វើសេចក្តីសម្រេចដោយខ្លួនឯងតែម្តង តើលោកនៅចាំថា លោកបាននិយាយថាអ៊ីចឹងទេ?

**ឆ៖** បាទ គឺថាពេលខ្លះ គាត់មានសិទ្ធិធ្វើសេចក្តីសម្រេចខ្លួនគាត់ផ្ទាល់ ក្នុងឋានៈជាលេខារបស់បក្ស ហើយត្រង់ថា គាត់ប្រជុំ ឬមិនប្រជុំ អាហ្នឹង ខ្ញុំមិនដឹងបានទេ។

**ស៖** អ្វីដែលលោកកំពុងនិយាយនេះ គឺមានឱកាសទាំងនោះទេ ដែលថា ប៉ុល ពត បានធ្វើសេចក្តីសម្រេចដោយខ្លួនឯងតែម្តង។ នេះគឺជាសក្ខីកម្មដែលលោកបានឆ្លើយ ដោយសារលោកជាសាក្សីបានធ្វើសម្បថហើយ។

**ឆ៖** អាហ្នឹង ខ្ញុំមិនបានដឹងអីច្បាស់ទេ ប៉ុន្តែតាមៗឧទាហរណ៍ជាក់ស្តែងខ្លះ គាត់មិនបានប្រជុំជាមួយអ្នកដទៃទេ គឺថាគាត់សម្រេចតែម្តង តែម្នាក់គាត់តែម្តង។ ឃើញណេះ អ្នកឯទៀត យកទៅអនុវត្តទៅ។ ដូច្នោះ ខ្ញុំដែលតាមខ្ញុំដឹង ខ្ញុំនិយាយប៉ុណ្ណឹង ហើយត្រង់ថា ខ្ញុំស្បថហើយ ខ្ញុំមិនគោរពការសម្បថហ្នឹង លោកមេធាវីនិយាយម្តងជាពីរដងហើយ អាហ្នឹង ដូចខោកក្បាលខ្ញុំដែរ។

[១១:៥៨:១៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោករៀបចំនូវការតាំងសំណួររបស់លោក ឲ្យសមស្រប ធ្វើយ៉ាងឲ្យចៀសវាង ធ្វើឲ្យប៉ះពាល់សតិអារម្មណ៍របស់សាក្សី។ ធ្វើឲ្យសាក្សីបាត់ជំនឿចិត្តក្នុងការផ្តល់សក្ខីកម្ម។ ស្បថនេះ ដឹងហើយទាំងអស់គ្នា ហើយអង្គជំនុំជម្រះបានតាំងសំណួរតាំងពីដំបូង ហើយនៅក្នុងកំណត់ហេតុ

សួរចម្លើយរបស់គាត់ទាំងប៉ុន្មានលើក ទាំងលាយលក្ខណ៍អក្សរសុទ្ធតែមានខ្លឹមសារនៃសម្បថដែលបានធ្វើ។

[១១:៥៨:៥១]

ឥឡូវនេះ យើងបានធ្វើសម្បថឲ្យនីតិវិធីកាន់តែជាក់ច្បាស់ទៀត ដើម្បីឲ្យប្រាកដថា នីតិវិធីធ្វើសម្បថហ្នឹង គឺបានត្រឹមត្រូវ ហើយនៅពេលណា ចំពោះមុខអ្នកតាដំបងដែក យើងបាននិយាយច្បាស់លាស់ហើយ។

**លោក ម៉ៃខល កាណាវ៉ាស៖**

ប្រសិនណាយើងចូលទៅ ERN ភាសាខ្មែរ 00832172, ជាភាសាបារាំង 0083121 សូមកែតម្រូវ ដល់ 21, និងភាសាអង់គ្លេស 0083--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យ លោកប្រធាន ERN ដែលគាត់ហៅ ញាប់ពេក បាត់ដល់ទៅពីរខ្ទង់ លោកប្រធាន។

[១១:៥៩:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអានឡើងវិញ នូវឯកសារអម្បាញ់មិញនេះ ព្រោះញាប់ពេក លេខ ERN ជាភាសាខ្មែរហ្នឹង ខ្មែរបកប្រែមិនបានទេ។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** ជាភាសាខ្មែរ 00832172 ដល់ 73, ជាភាសាបារាំង 00833120 ទៅដល់ 21, ជាភាសាអង់គ្លេស 00833240 ជាប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ដែលនៅត្រង់នេះគឺលោកនិយាយថា "មានសាខាពីររបស់បក្ស។ ទី១ គឺសាខាបក្សដែលនៅក្រោមក្រសួងផ្ទាល់តែម្តង និងមួយទៀតជាសាខារបស់បក្ស ហើយផ្នែកសាខារបស់បក្សនោះគឺមាន តូច ខាំឌឿន, មាន គាត ឈន់, ជួន ប្រាសិទ្ធ, សួ ផន"។ ហើយលោកនិយាយថា "សួ ផន គឺជាលេខារបស់គាត់ផ្ទាល់"។ ខ្ញុំសូមសួរថាតើនៅក្នុងកិច្ចប្រជុំរបស់សាខាបក្សហ្នឹង គេមាននិយាយអំពីអ្វីខ្លះ? ហើយម៉េចបានលោកដឹងថា មានវត្តមានលោក គាត ឈន់, ជួន ប្រាសិទ្ធ ហើយដែលអ្នកទាំងនេះគឺថា នៅរស់នៅឡើយទេ។ តើពួកគាត់ទាំងនេះមានព័ត៌មានដែលថាមានអ្វីកើតឡើងនៅក្នុងកិច្ចប្រជុំនោះទេ ទាក់ទងទៅនឹង អៀង សារី?

[១២:០១:៤៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ គឺថាមានពីរចំណុច ទី១ គឺថាសម្រង់ គឺជាសម្រង់តែមួយផ្នែកទេ។ អ៊ីចឹង ខ្ញុំសូមទាញចំណាប់អារម្មណ៍តុលាការលើចំណុចនេះ គឺថាមានឃ្លាមួយដែលការពារក្ដីមិនបានដកស្រង់ គឺថា "អៀង សារី ជាអ្នកគ្រប់គ្រងលើសាខាបក្សទាំងពីរនេះ"។ ចំណុចទី២ ដែលខ្ញុំចង់និយាយគឺថា គាត់ឲ្យសាក្សីស្មានៗថា មានមនុស្សផ្សេងទៀត ដែលអាចនឹងអំពីខ្លឹមសារកិច្ចប្រជុំនេះ។ នេះមិនមែនជាតួនាទីរបស់សាក្សីនោះទេ អ៊ីចឹងសូមអង្គជំនុំជម្រះមេត្តាគិតពីបញ្ហានេះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយ។ ជាបឋម គឺសហព្រះរាជអាជ្ញា គឺលើកឡើងតែពីថាខុសប្រធានបទ។ ដូច្នេះ ខ្ញុំមិនអាចធ្វើអ្វីទេ បើសិនជាជំទាស់រាល់ពេល ហើយនៅក្នុងនេះប្រតិចារឹកនិយាយពីតែ អៀង សារី ហើយថាតើអ្នកណាខ្លះជាសមាជិកនៅពេលនោះ។ ឥឡូវនេះ ខ្ញុំទុកចោលផ្នែកមួយខាងក្រោយ ហើយប្រសិន -- តើបុគ្គលពីរនាក់ ដែលថា គាត ឈន់ ហើយនិង ជួន ប្រាសិទ្ធ ជាសមាជិក ហើយស្ថិតនៅក្នុងកិច្ចប្រជុំតែមួយ ដូចដែលសាក្សីនេះចូលរួមដែរនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៤:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស សូមលោកបញ្ជាក់ឡើងវិញ អំពីសំណួរពីព្រោះលោកបានបោះចោល -- លោកស្រង់ផ្នែកខ្លះ ប៉ុន្តែមិនយកផ្នែកផ្សេងទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអភ័យទោស។ ដោយសាមញ្ញនោះ តើលោកប្រកាន់សក្ខីកម្មរបស់លោក ដែលថា

ទាំងអស់នេះជាសមាជិករបស់សាខាបក្សទេលោកសាក្សី? ហើយពួកគាត់បានចូលរួមអង្គប្រជុំជាមួយលោក?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ដោយសារខ្ញុំដឹងថា គាត់បានចូលរួមព្រោះខ្ញុំជាសមាជិកសាខានេះដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ ហើយឥឡូវដល់ពេលសមល្មមសម្រាកហើយ។ មុននឹងសម្រាកអង្គជំនុំជម្រះសូមសួរទៅលោកក្រុមមេធាវីការពារក្តីលោក អៀង សារី តើលោកត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោស ខ្ញុំនឹងត្រូវការពេលដែលខ្ញុំនៅសល់ គឺថា ពីរថ្ងៃសម្រាប់មេធាវីការពារក្តី ហើយនិងខ្ញុំត្រូវការមួយព្រឹកថ្ងៃចន្ទ ទៀតសម្រាប់សាក្សីរូបនេះ។ ហើយខ្ញុំសូមជម្រាបថា ខ្ញុំនឹង -- ខ្ញុំមើលឯកសារដែលខ្ញុំរៀបចំនេះ ខ្ញុំនឹងស្រង់ពិនិត្យឡើងវិញ ហើយខ្ញុំជឿថា វាមានសម្រាំងឡើងវិញ ខ្ញុំនឹង -- ហើយតាមការប្រុងប្រយ័ត្នហើយដើម្បីព្យាយាមឲ្យបាន សង្ខេបឲ្យបានខ្លីតាមដែលអាចធ្វើទៅបាន ប៉ុន្តែខ្ញុំមិនចង់ -- ឲ្យអង្គជំនុំជម្រះយល់ច្រឡំទេ។ ខ្ញុំព្យាយាមបញ្ចប់មួយព្រឹកថ្ងៃចន្ទ។ ប៉ុន្តែមានលទ្ធភាព ឬក៏ខ្ញុំអាចចប់មុនហ្នឹង។ សូមអរគុណបាទ។

[១២:០៦:៣៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៧:៣៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ប្រសិនបើជាសាក្សីគាត់មានបំណងផ្តល់សក្ខីកម្មនៅរសៀលនេះ តែម្តងដើម្បីឲ្យចប់នៅភារកិច្ចរបស់គាត់ក្នុងការផ្តល់សក្ខីកម្មនៅ អ.វ.ត.ក នេះ តើលោកមានមតិយោបល់យ៉ាងម៉េចដែរ? ដោយយើងបានទទួលព័ត៌មានមួយបឋមហ្នឹង ពីគាត់ហ្នឹងថា គាត់មានបំណង ប្រសិនបើអាចចប់នៅរសៀលនេះ គាត់នឹងខិតខំប្រឹងប្រែងដើម្បីបន្តការផ្តល់សក្ខីកម្មរហូតដល់ចប់ ដើម្បីគាត់បានវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ពីព្រោះគាត់បានមករង់ចាំហ្នឹងបម្រុងទុកហ្នឹងច្រើនថ្ងៃហើយ មុននឹងចូលផ្តល់សក្ខីកម្ម។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំគិតថា អាចនឹងសម្រេចបាន គឺមួយល្ងាចពេញថ្ងៃនេះបាទ។ ខ្ញុំនឹងចំណាយពេលពិសាអាហារថ្ងៃត្រង់នេះ ដើម្បីពិនិត្យមើលការត្រៀមរៀបចំរបស់ខ្ញុំ ហើយដែលខ្ញុំស្នើថាថ្ងៃចន្ទ កន្លះព្រឹកហ្នឹងដោយថា ថ្ងៃមិនសវនាការ តទេល្ងាចនោះបាទ។

[១២:០៨:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

លោក សួង ស៊ីគឿន យ៉ាងម៉េចដែរ? លោកសួង ស៊ីគឿន យ៉ាងម៉េចដែរ ឥឡូវនេះនៅពេលមួយរសៀលទៀត តើលោកប៉ាន់ស្មានសុខភាពរបស់លោកហ្នឹង តើលោកអាចបន្តផ្តល់សក្ខីកម្មនៅរសៀលនេះទេ ដើម្បីបញ្ចប់នៅការផ្តល់សក្ខីកម្មរបស់លោកនៅក្នុងសំណុំរឿង០០២ នេះចំពោះមុខអង្គជំនុំជម្រះនោះ?

**លោក សួង ស៊ីគឿន៖**

ខ្ញុំខំប្រឹងណាស់ដែរ ប៉ុនតាមមើលទៅបើសិនជាខ្ញុំបន្តទៀត ខ្ញុំទៅមិនរួចទេបាទ។ ខ្ញុំដូច្នោះ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំសម្រាកពីរបីថ្ងៃ ព្រោះតាមពិសោធខ្ញុំ ខ្ញុំចាស់ហើយជាការសម្រាកពីរបីថ្ងៃតែខ្ញុំហត់ពេកវាជាន់ខ្ញុំទៅតែម្តង គឺអត់ទៅរួចទេបាទ។ អ៊ីចឹងខ្ញុំសូមឲ្យថា មើលទៅតាមសំណួរលោកមេធាវី ខ្ញុំមិនអាចនឹងឆ្លើយបានពេញសមត្ថភាពរបស់ខ្ញុំ ដោយសារសុខភាពហ្នឹងបាទ។ ដូច្នោះ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំត្រឡប់មកព្រឹកថ្ងៃចន្ទ វិញ។ ហ្នឹង អាចខ្ញុំសម្រាកទៅខ្ញុំបានបំពេញកម្លាំងខ្ញុំវិញ ហើយខ្ញុំមានសមត្ថភាពឆ្លើយនឹងសំណួរពេញលេញ បានគ្រប់ជ្រុងជ្រោយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន មិនបញ្ហាអីទេ។ អ៊ីចឹងគឺសម្រេចតាមសំណើសុំរបស់លោកទៅចុះ គឺសវនាការបន្តពិភាក្សាដេញដោលស្តាប់សក្ខីកម្មរបស់លោក ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី បញ្ចប់នោះ គឺធ្វើនៅព្រឹកថ្ងៃចន្ទ ទី២០ ខែសីហា ឆ្នាំ២០១២។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មដូចថ្ងៃបានកំណត់អម្បាញ់មិញនេះ ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នា សូមអញ្ជើញមកជាមួយនឹងសាក្សី ដើម្បីអង្គុយត្រៀមខ្លួនប្រឹក្សាយោបល់ជាមួយនឹងសាក្សី នៅក្នុងអំឡុងពេលគាត់ផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយ។

[១២:១១:០៧]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅព្រឹកថ្ងៃចន្ទ ទី២០ ខែសីហា ខាងមុខ គឺសប្តាហ៍ក្រោយ នៅវេលាម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ នួន ជា សូមអនុញ្ញាតទៅតាមដាននីតិវិធីល្ងាចនេះនៅបន្ទប់ខាងក្រោម ដោយគាត់ឈឺក្បាល ហើយឈឺខ្នង ហើយនិងគាត់ពិបាកផ្តង់អារម្មណ៍ ហើយខ្ញុំបាទនឹងរៀបចំលិខិតបោះបង់សិទ្ធិជូនតុលាការតាមនីតិវិធីបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់។ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយមូលហេតុមានបញ្ហាខាងសុខភាព។ ហើយលោកមេធាវីបានសន្យាថា នឹងផ្តល់នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា មកឲ្យអង្គជំនុំជម្រះ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាម -- និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការនៅពេញមួយរសៀលនេះ។ ហើយដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:១២:៥៥]

ហើយមេធាវីការពារក្តី ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការ

នេះ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ដោយរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

[១២:១៣:៤៩]

ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា កិច្ចដំណើរការសវនាការនៅរសៀលនេះ អង្គជំនុំ-ជម្រះ នឹងបន្តស្តាប់សក្ខីកម្មសាក្សី ស សៀក ដោយតំណាងសហព្រះរាជអាជ្ញា។

បាទ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលចូលវិញ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១២:១៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅថ្ងៃនេះការតាំងសំណួរដេញដោលចំពោះសាក្សី ស សៀក នឹងបន្តដោយតំណាងសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស សៀក។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម មេធាវីការពារក្តី សូមគោរព

លោកស្រីសាក្សី ស សៀក។

[១៣:៣៤:១៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងនឹងចាប់ផ្តើមចំណុចដដែល ដែលយើងបានផ្អាកពីម្សិលមិញ កកស្ទះពីម្សិលមិញនោះ។ នៅពេលដែលលោកស្រីប្រាប់ខ្ញុំអំពីការងាររបស់លោកស្រីនៅរោងពុម្ព។ លោកស្រីបានរៀបរាប់ជូនយើងខ្ញុំថា សៀវភៅខ្លះដែលបានបោះពុម្ពនៅទីនោះៗ ហើយនៅពេលដែលលោកស្រីនិយាយអំពីខ្លឹមសារនៃសៀវភៅទាំងនោះ លោកស្រីបាននិយាយថា សៀវភៅខ្លះអាចមានរូបថតស្រែអំបិល ឬក៏នារីៗធ្វើការនៅស្រែអំបិល ឬក៏នារីៗធ្វើការនៅស្រែអំបិល និងដែលមានចំណងជើងថា -- ហើយជាពិសេសហ្នឹងសំខាន់បំផុតគឺនិយាយអំពីការងារនៅស្រែអំបិលនោះ។ អ៊ីចឹងនៅពេលនេះ ខ្ញុំសូមបង្ហាញឯកសារមួយដែលមានរូបថតដូចលោកស្រីរៀបរាប់ ចង់ដឹងថាតើលោកស្រីនៅចាំពីឯកសារនេះទេ? នេះគឺជាឯកសារ E3/752 វាជាទង់យុវជនយុវនារីកម្ពុជា។

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ ខ្ញុំមានឯកសារជាក្រដាសជូនសាក្សីផង ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះអាននូវផ្នែក ERN ពាក់ព័ន្ធ ដើម្បីសួរទៅសាក្សីថា តើសាក្សីនៅចាំឯកសារនេះឬក៏អត់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ អម្បាញ់មិញ ខ្ញុំបានស្តាប់តំណាងអយ្យការ គាត់បានធ្វើសេចក្តីសន្និដ្ឋានមួយ បញ្ជាក់ទៅលើចម្លើយរបស់សាក្សីថា រូបថតដែលគាត់នឹងបង្ហាញនេះជារូបថតដែលដូចហ្នឹងអ្វី ដែលសាក្សីបានរៀបរាប់។ ខ្ញុំសូមឲ្យលោកបញ្ជាក់ អាចបើអាចធ្វើសាជាថ្មីថា តើជារូប -- ជាការសន្និដ្ឋានរបស់លោកថា ដូច ឬមួយក៏វាស្រដៀង ឬក៏ប្រហាក់ប្រហែលលក្ខខណ្ឌណានោះ បាទ។ សូមអរគុណ។

[១៣:៣៦:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោក លោកស្រីចៅក្រម ខ្ញុំជឿថាសហការីរបស់ខ្ញុំគាត់យកពាក្យពេញ ពេលដែលខ្ញុំរៀបរាប់រូបថតដែលខ្ញុំនឹងត្រូវបង្ហាញជូនសាក្សី ដែលមានការអនុញ្ញាតពីអង្គជំនុំជម្រះនោះ គឺបង្ហាញខ្លីទេ។ ខ្ញុំអត់ថាតើគោលបំណងនៃការបកស្រាយនេះមិនដឹងជាមានបំណងចង់ថាម៉េច?

[១៣:៣៧:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកស្រី ស សៀក នៅពេលលោកស្រីមើលទៅឯកសារនេះ ខ្ញុំសូមអានលេខ ERN នេះជូនជាភាសាខ្មែរ 0006368 (ស៊ីក), ជាបារាំង 00525897, ហើយជាអង់គ្លេស 00593566។ លោកស្រី ស សៀក មើលទៅរូបភាពនេះទៅ តើជារូបភាពដែលលោកស្រីបានរៀបរាប់កាលពីម្សិលមិញ ឬក៏យ៉ាងណាដែរ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមមានមតិ។ សូមគោរពលោកប្រធាន។ សូមឆ្លើយបន្ត។ ចាស ជារូបភាពនេះគឺនាងខ្ញុំមើលទៅប្រហាក់ប្រហែលនឹងសៀវភៅដែលខាងនាងខ្ញុំបានបោះពុម្ព ប៉ុន្តែគ្រាន់ថាមិនមានចំណងជើងអី នាងខ្ញុំមិនបានចាំទេ។ ប៉ុន្តែគ្រាន់ថានេះពីសម័យដែលយើងរំដោះហើយ រូបភាពស្រែអំបិលនេះ។ ចាស សូមអស់យោបល់។

[១៣:៣៩:១៨]

**ស៖** ហើយប្រសិនជាលោកស្រីមើលទៅទំព័រទី១ នៃឯកសារនេះ ហើយមើលចំណងជើងត្រង់ទំព័រនេះ។ ចំណងជើងនៃឯកសារនេះគឺ "យុវជន និងយុវនារីបដិវត្តន៍"។ តើចំណងជើងនៃឯកសារនេះវាស្រដៀងគ្នាទៅនឹងចំណងជើងសៀវភៅដែលលោកស្រីបានបោះពុម្ពនៅឯរោងពុម្ពនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ចម្លើយមុនអម្បាញ់មិញនេះ សាក្សីបានបញ្ជាក់ហើយថា គាត់អត់

បានអានចំណងជើង ហើយក៏បានអត់បានចាំ អត់ដឹងថាអ្វីដែរ។ ហើយបើសិនជាលោកសហព្រះរាជអាជ្ញាសួរសំណួរនេះតទៀត វាមានន័យថាសួរច្រំដែលសាឡើងវិញនូវអ្វីដែលសាក្សីបានបញ្ជាក់រួចហើយ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

បញ្ហានេះប្រហែលជាអាចជាបញ្ហាដោយការបកប្រែហើយ។ ខ្ញុំមិនបានសួរអំពីចំណងនៅរូបថតទេ គឺចំណងជើងនៃឯកសារនេះតែម្តង នៃទស្សនាវដ្តីនេះតែម្តង ថាតើសាក្សីគាត់អាចចាំឬក៏យ៉ាងណានោះ?

[១៣:៤០:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងមូលហេតុជំទាស់មិនសមស្របទេ។ សាក្សីពិនិត្យមើល ហើយអាចឆ្លើយតបទៅនឹងសំណួរដែលសួរនេះ។

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ និងឆ្លើយនូវសំណួរនេះ បានន័យថារាងប្រហាក់ប្រហែលដែលនាងខ្ញុំបានឃើញ និងធ្លាប់អាន -- ធ្វើនូវសៀវភៅ ប៉ុន្តែដូចថាចំណងជើងអីនាងខ្ញុំមិនបានចាំទេ ភ្លេចអស់ហើយ។ ប៉ុន្តែគ្រាន់តែឃើញរូបភាពហ្នឹង ទោះបីនាងខ្ញុំបាននៅកន្លែងនុំងមើលបងៗធ្វើពីមុនមក គឺថាវាមានដែរជារូបភាពអ៊ីចឹង។ ចាស សូមអស់យោបល់។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំនឹងបង្ហាញឯកសារស្រដៀងនេះមួយទៀតទៅលោកស្រី ថាតើលោកស្រីអាចស្គាល់ឯកសារ ស្គាល់ទម្រង់នៃឯកសារនេះដែរឬក៏អត់? ឯកសារនេះ គឺ E3/11 ចុះខែកញ្ញា ឆ្នាំ១៩៧៧ វាខុសគ្នាពីនឹងទស្សនាវដ្តីដែលបង្ហាញមុននេះបន្តិច។

[១៣:៤២:២៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

ប្រសិនមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមៗបង្ហាញជូនសាក្សីនូវឯកសារនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកស្រី ស សៀក លោកស្រីបានប្រាប់មកយើងខ្ញុំថា លោកស្រីធ្វើការនៅរោងពុម្ពនៅឆ្នាំ១៩៧៧ ហើយឯកសារនេះគឺជាឯកសារចេញផ្សាយនៅឆ្នាំ១៩៧៧។ ចំណងជើងជា ចំណងជើងនៃឯកសារនេះគឺ "ទង់បដិវត្តលេខពិសេស ចុះខែកញ្ញា ១៩៧៧"។ តើនេះជាឯកសារមួយដែលលោកស្រីទទួលខុសត្រូវក្នុងការជួយរៀបចំទស្សនាវដ្តីនេះដែរ ឬក៏យ៉ាងណា?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស សូមឆ្លើយនូវសំណួរនេះ ឆ្នាំ១៩៧៧ ហ្នឹង នាងខ្ញុំចេញពីឃោសនាការទៅហ្នឹងចុងឆ្នាំមែនទែនហើយ ដូច្នេះឯកសារនេះអាចនាងខ្ញុំមិនបានស្គាល់ ហើយក៏មិនបានធ្វើ ក្នុងការធ្វើមានវេនគ្នាអ៊ីចឹងលោក។ ផ្លាស់វេនគ្នាអ៊ីចឹង ចុះកម្មករវាច្រើន ថ្ងៃណាផ្ទៀងទំព័រអ៊ីចឹង វេននាងខ្ញុំទៅផ្ទៀងទៅ ថ្ងៃអត់ៗទៅ។ ការពិត ខ្ញុំអត់បានចាំ។

[១៣:៤៣:៥៨]

**ស៖** សូមអរគុណ។ ហើយសំណួរមួយទៀត សួរសំណួរតែមួយទៀតទេទៅលើឈ្មោះរបស់ឯកសារនេះ។ លោកស្រីចាប់ផ្តើមធ្វើការងារនៅទីនោះនៅចុងឆ្នាំ១៩៧៧ គឺជិតដាច់ឆ្នាំ១៩៧៧។ តើលោកស្រីនៅចាំទេ ថា លោកចាំចំណងជើង "ទង់បដិវត្ត" ដែលជាឯកសារលោកស្រីជួយរៀបចំបោះពុម្ពដែរឬក៏យ៉ាងណា ក្រោយពីលោកស្រីចូលធ្វើការនៅក្នុងរោងពុម្ពនោះ?

**ឆ៖** ភ្លេចហើយលោកប្រធាន ដូចមិនបានចាំជាក់លាក់ទេ។

[១៣:៤៤:៥០]

**ស៖** ខ្ញុំចូលទៅការងាររបស់លោកស្រីនៅក្រសួងឃោសនាការវិញម្តង។ ពីម្សិលមិញលោកស្រីផ្តល់សក្ខីកម្មថា នៅក្នុងខែមេសា ១៩៧៥ នៅពេលលោកស្រីមកដល់ទីក្រុងភ្នំពេញ ការទទួលខុសត្រូវរបស់លោកស្រីនៅពេលនេះ គឺធ្វើការនៅក្រុម ជាមួយនឹងក្រុមសិល្បៈ។ តើការទទួលខុសត្រូវនេះមានការប្រែប្រួលទេ ចន្លោះពីខែមេសា ៧៥ ទៅដល់ចុងឆ្នាំ១៩៧៧នៅពេលលោកស្រីទៅធ្វើការនៅរោងពុម្ពនោះ?

**ឆ៖** លោកផ្តល់សំណួរម្តងទៀត!

**ស៖** បាទបាន។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ តើលោកស្រីទទួលខុសត្រូវធ្វើអីនៅក្រសួងឃោសនានោះ មុននឹងលោកស្រីទៅធ្វើការនៅរោងពុម្ព?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ នៅក្រុមសិល្បៈសម្រាប់ច្រៀង ហើយនិងសម្ដែងជារូបភាព។ ប៉ុណ្ណឹងលោក។

[១៣:៤៦:២៥]

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ ក្រៅពីច្រៀងនិងរាំ លោកស្រីបានជម្រាបមកយើងខ្ញុំថាលោកស្រីមិនមានការទទួលខុសត្រូវអ្វីផ្សេងទៀតទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ក្រៅពីការច្រៀង ហើយនិងរាំហាត់សិល្បៈហ្នឹង នាងខ្ញុំជាបុគ្គលិកនៅក្នុងហ្នឹងបានជួយវ៉ៃជាអង្គុលីលេខស្រង់ពីវិទ្យុខ្លះៗ។ ប៉ុណ្ណឹងលោក។

**ស៖** តើលោកស្រីជួយវាយអង្គុលីលេខសម្រាប់ការផ្សាយវិទ្យុមួយណាដែរ?

**ឆ៖** ចាស វ៉ៃអង្គុលីលេខនេះមិនមែននេះទេ គ្រាន់ថាវិទ្យុស្រង់ពីទូរពុម្ព បកស្រាយជាភាសាខ្មែរគឺថាដូចថា ដំណឹងនៅក្នុងប្រទេសមួយៗដូចថា ប្រទេសណាដែលមានដីរញ្ជួយអ៊ីចឹងទៅ ខ្ញុំមិនបានចាំថាប្រទេសណាៗ ហើយជាដំណឹងទាក់ទងនឹងគណៈប្រតិភូអី។ អានេះជាដំណឹង មើលទៅជាដំណឹងអន្តរ-ជាតិ លោក។ ប៉ុន្តែវ៉ៃបកជាភាសាខ្មែរប៉ុណ្ណឹង ចាស។

**ស៖** នៅពេលនោះ -- ខ្ញុំសូមរៀបសំណួរឡើងវិញ។ តើអ្នកណាជាមេផ្ទាល់របស់លោកស្រីនៅពេលនុ៎ង អ្នកណាជាប្រធាននៃផ្នែករបស់លោកស្រីនៅពេលនោះ?

**ឆ៖** ចាស ផ្នែកសិល្បៈ ប្រធាននាងខ្ញុំឈ្មោះ សៅ ។ ប្រុស។

**ស៖** ចុះអង្គភាព ឬក៏ផ្នែកដែលធ្វើការដកស្រង់ និងវាយអង្គុលីលេខដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានហ្នឹងជាផ្នែកអ្វីដែរ?

**ឆ៖** ខ្ញុំមិនស្គាល់ផ្នែកទេ ប៉ុន្តែគ្រាន់ថាស្គាល់ឈ្មោះ ដែលគាត់ចេះបកជាភាសាខ្មែរ មានឈ្មោះពូផែន។

[១៣:៤៩:២៧]

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅពេលលោកស្រីជួយវាយអក្សរដើម្បីធ្វើការផ្សព្វផ្សាយហ្នឹង តើលោកស្រីម្នាក់វាយហើយហ្នឹងឲ្យទៅអ្នកណា? បញ្ជូនទៅឲ្យអ្នកណា?

**ឆ៖** ចាស នាងខ្ញុំឲ្យទៅម្ចាស់ដើមដែលបកជាភាសាខ្មែរហ្នឹងវិញ។ ឲ្យទៅគាត់ តែមិនដឹងគាត់

ទាក់ទងចែកចាយទៅម៉ុំណា ឬមួយក៏យកទៅផ្សាយ ឬមួយក៏យកទុកជាឯកសារ។ ខ្ញុំអត់បានដឹងដែរ។ សូមអស់យោបល់។

**ស៖** តើការដកស្រង់ ហើយយកមកជួយវាយជាអង្គុលីលេខនេះ គឺញឹកញាប់ប៉ុនណាដែរ? លោកស្រីជួយវាយឡើងវិញហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចាសម្ដងម្កាល។ ចង់និយាយថា ជួនកាលទៅមួយអាទិត្យមានម្ដង ឬពីរដងលោក។

[១៣:៥០:៤៩]

**ស៖** បើសិនជាមិនស្គាល់ លោកស្រីប្រាប់ថាមិនស្គាល់ ថាតើអ្នកណាជាអ្នកសម្រេចថា ការដកស្រង់មួយណា ឬក៏ឯកសារត្រូវផ្សព្វផ្សាយមួយណា ដែលត្រូវយកមកវាយឡើងវិញនោះ?

**ឆ៖** ខ្ញុំមិនបានចាំទេលោក។

**ស៖** តើជាបុគ្គលខុសពី កៅ ឬក៏ឈ្មោះ ផែន នេះ តើជាមនុស្សក្រៅពីពីរនាក់នេះ ឬក៏មិនមែនទេ?

**ឆ៖** លោកផ្ដល់សំណួរម្ដង។

**ស៖** ដោយសារតែពេលវេលា សូមបន្តទៅមុខទៀតចុះ។ តើដែលពេលណាមួយលោកស្រីត្រូវបានគេជ្រើសរើស នាយកដ្ឋានមួយណា ឬក៏ផ្នែកមួយណា ដែលជាផ្នែកនៃក្រសួងឃោសនាការហ្នឹង ទោះជានៅក្នុងប្រទេសកម្ពុជាក្ដី នៅក្រៅក្ដី គេធ្លាប់បានបញ្ជូនចាត់តាំងលោកស្រីទៅធ្វើនៅកន្លែងណាមួយទេ?

**ឆ៖** ធ្វើការងារអីផង។

**ស៖** សំណួរខ្ញុំនេះគឺវាខុសបន្តិច ខ្ញុំសួរថាតើលោកស្រីហ្នឹង ដែលត្រូវបានគេចាត់តាំងឲ្យទៅធ្វើនៅផ្នែកណាផ្សេងទៀតទេ?

**ឆ៖** ធ្វើការងារនៅក្នុងស្រុក ឬមួយក៏យ៉ាងម៉េចលោក? ស្ដាប់អត់សូវបាន។

[១៣:៥២:៥៩]

**ស៖** បាទដោយសារតែពេលវេលា ខ្ញុំសូមអានខ្លីទេ អានសារមួយ គឺឯកសារ E3/379, ERN ជាភាសាខ្មែរ 00294810, ERN ជាភាសាបារាំង 00385286, ERN ជាភាសាអង់គ្លេស 00323334។ សំណួរ និងចម្លើយជាសង្ខេបទេ លោកស្រីបានឆ្លើយថា "មានស្ថានីយផ្សាយសំឡេងមួយទៀតនៅប្រទេសចិន ហើយលោកស្រីត្រូវបានគេជ្រើសរើសឲ្យទៅធ្វើការនៅទីនោះ"។ ហើយសំណួរ

សួរថា "លោកស្រីម៉េចបានដឹងថាមានស្ថានីយហ្នឹង?" លោកស្រីថា "ដោយសារខ្ញុំគេចាត់តាំងឈ្មោះឲ្យខ្ញុំទៅទីនោះ ហើយខ្ញុំបានជួបជាមួយពួខ្ញុំ (ប្ដីរបស់ខ្ញុំ)។ ដូច្នេះ ខ្ញុំក៏មិនបានទៅៗ"។ តើនេះគឺជាចម្លើយសង្ខេបរបស់លោកស្រីដែរ ឬក៏មិនមែនទេ នៅពេលដែលលោកស្រីនិយាយអំពីថា គេចាត់តាំងឈ្មោះលោកស្រីឲ្យទៅទីនោះ ប៉ុន្តែលោកស្រីជួបប្ដីលោកស្រីក៏អត់បានទៅវិញទៅ?

**ឆ៖** ចាសលោកសំណួរនេះ ខ្ញុំពីមុនមកខ្ញុំស្ដាប់អត់បាន តែឥឡូវនេះ ខ្ញុំស្ដាប់បានហើយ។ នេះជារយៈកាលឆ្នាំ៧៩ហើយទេ នៅឆ្នាំ៨៣លោក មិនមែនជារយៈកាលឆ្នាំមុនទេនេះនោះ។ តែគ្រាន់ថាសេចក្ដីសម្ភាស ហើយនិងនិយាយ ដូចថា សំណេះសំណាលគ្នាទៅវាអាចចូលនៅក្នុងសំណួរហ្នឹង។

[១៣:៥៥:០០]

**ស៖** សូមអរគុណ។ ការបញ្ជាក់នេះមិនជាសំខាន់អីទេ។ ដើម្បីឲ្យយើងខ្ញុំយល់បានពេញលេញ តើលោកស្រីជួបស្វាមីរបស់លោកស្រី ឬក៏រៀបការជាមួយស្វាមីលោកស្រីនៅពេលណាដែរ?

**ឆ៖** ចាស នៅឆ្នាំ៨៣។

**ស៖** សូមអរគុណ។ ត្រឡប់ទៅការងាររបស់លោកស្រី នៅក្រសួងឃោសនាការវិញម្ដងចន្លោះពី៧៥ ដល់៧៩ -- ៧៥ ទៅ ៧៧ (សូមកែប្រែ) តើលោក ហ៊ូ នឹម នោះ ដែលទៅធ្វើការនៅក្រសួងក្នុងឋានៈជាមេក្រសួង ជារដ្ឋមន្ត្រីនៃក្រសួងឃោសនាការហ្នឹងដែរឬទេ ចន្លោះពី៧៥ ទៅ៧៧នោះ?

[១៣:៥៦:០០]

**ឆ៖** ចាស ពី៧៥ ទៅ៧៧ ចាស គាត់នៅក្នុងឆ្នាំ៧៦លោក។ តែក្រោយពី៧៦មក គាត់អាចដកហូតទៅបម្រើការងារខាងណា ខ្ញុំក៏អត់បានដឹងដែរ។ គាត់ចេញពីក្រសួងហ្នឹងឆ្នាំ ចុងឆ្នាំ៧៦។

**ស៖** ពីម្សិលមិញ លោកបានជម្រាបមកយើងខ្ញុំថា ទីវ អុល គឺជាជំនួយការរបស់លោក ហ៊ូ នឹម។ តើនៅពេលហ្នឹង លោកស្រីនៅតែបន្តធ្វើការជាមួយនឹងក្រសួងឃោសនាការនេះដដែល ឬក៏អី? ថាតើលោក ទីវ អុល នេះនៅបន្តធ្វើការតាំងពីឆ្នាំ ក្រោយឆ្នាំ៧៥ តទៅទៀត ឬក៏អត់ទេ?

**ឆ៖** ចាស អត់។ គាត់ទាំងពីរនាក់ ចេញទាំងអស់គ្នា។

**ស៖** យើងនឹងចូលទៅព្រឹត្តិការណ៍ពាក់ព័ន្ធនឹងលោក ហ៊ូ នឹម។ នៅពេលដែលនិយាយអំពីក្រសួងនេះ ខ្ញុំចង់លើកឡើងអំពីការផ្សព្វផ្សាយ ដោយក្រសួងនេះនៅឆ្នាំមួយពាន់ប្រាំបួនរយ -- ពីឆ្នាំ ១៩៧៥ ដល់ ៧៩។ ពីម្សិលមិញ លោកស្រីបានលើកឡើងថា ឆ្លើយតបទៅនឹងសំណួររបស់សហ

ព្រះរាជអាជ្ញាជាតិ គឺការផ្សព្វផ្សាយខ្លះ និយាយអំពីការបង្កបង្កើនផល ការកើនឡើងនៃផលិតផលស្រូវ ហើយនិង -- តើលោកស្រីអាចរៀបរាប់បានទេ អំពីការផ្សព្វផ្សាយព័ត៌មាន ជាពិសេសពាក់ព័ន្ធទៅនឹងការបង្កបង្កើនផល? តើគេនិយាយអ្វីខ្លះអំពីការបង្កបង្កើនផលនេះនៅតាម -- នៅលើវិទ្យុនេះ?

**ឆ៖** ចាស លោកខ្ញុំសូមឆ្លើយនៅលើសំណួរហ្នឹង។ ការផ្សព្វផ្សាយជំរុញប្រជាជន ដើម្បីឲ្យធ្វើស្រែ ដើម្បីយកផលឧបត្ថម្ភខ្លួន ហើយក្នុងមួយហិកតា ឲ្យបានពី ពីរតោន ទៅបីតោនអីហ្នឹង គឺមាន។ ចាស ដើម្បីម្ចាស់ការឧបត្ថម្ភខ្លួន។

[១៣:៥៩:១២]

**ស៖** តើមានការផ្សព្វផ្សាយអំពីគោលមាគ៌ា របស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ចាស នៅក្នុងចំណុចនេះ នាងខ្ញុំដូចមិនបានចាប់អារម្មណ៍ ឬមួយក៏ភ្លាំងភ្លេចហើយលោក។ ច្រើនពេកក្តាប់មិនបាន។

**ស៖** ឥឡូវ សូមចូលទៅមើលកិច្ចសម្ភាសន៍ របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/379 ERN ជាភាសាខ្មែរ 00294806, ERN ជាភាសបារាំង 00385203, ហើយ ERN ជាភាសាអង់គ្លេស 0032330 (ស៊ុក)។ "សំណួរ៖ បើសិនណា ជាមានការផ្សព្វផ្សាយ តើលោកស្រីអាច -- តើវិទ្យុមានផ្សព្វផ្សាយអំពីមាគ៌ាបក្សដែរឬទេ? មានដូចជាការផ្សាយពីមាគ៌ាបក្ស គឺការកសាងកម្លាំង បើកម្លាំងថ្នាក់ក្រោមរឹងមាំ ខាងលើរង្គើដែរ។ និយាយពីការកសាងប្រឡាយ ការលើកទឹកចិត្តប្រជាជន ប៉ុន្តែមិននិយាយអំពីកង្វះខាតទេ"។ សំណួរចុងក្រោយ "ថាតើវិទ្យុបានផ្សព្វផ្សាយអំពីបញ្ហាសន្តិសុខផ្ទៃក្នុងដូចម្តេចដែរ? ឆ្លើយ៖ បានផ្សព្វផ្សាយអំពីការការពារប្រទេស"។ តើលោក្រសីចាំទេថា លោកស្រីបានជម្រាបបែបនេះ ជូនទៅសហចៅក្រមស៊ើបអង្កេត ជាពិសេស បើការ -- ពេលដែលនិយាយអំពីមាគ៌ាបក្សនោះ និងនិយាយអំពីការកសាងកម្លាំង?

[១៤:០១:៣២]

**ឆ៖** ចាស លោកដូចថាការសម្ភាសពីមុនមកវារយៈយូរឆ្នាំដែរ ដូច្នេះនាងខ្ញុំភ្លេច។ ដល់ឃើញជាឯកសារផ្ទាល់បាននាងខ្ញុំនឹកឃើញ ចាស បាននិយាយ បានផ្សាយ ដូចហ្នឹងមែន។ ភ្លេច យូរពេក។

**ស៖** ផ្អែកតាមការងាររបស់លោកស្រីកាលនោះ តើលោកស្រីយល់ដូចម្តេចអំពីថា កម្លាំង -- កសាងកម្លាំងឲ្យខ្លាំង ដើម្បីកុំឲ្យកម្លាំងខាងលើមានការរង្គោះរង្គើនោះ?

**ឆ៖** ចាស នាងខ្ញុំយល់ថា--

**លោក គង់ សំអុន៖**

លោកប្រធាន សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញ!

[១៤:០២:១៩]

**លោក គង់ សំអុន៖**

អរគុណលោកប្រធាន។ សូមជំទាស់ចំពោះសំណួរនេះ ពីព្រោះថាតំណាងសហព្រះរាជអាជ្ញា កំពុងតែបង្ហាញឲ្យសាក្សីយល់ពីគំនិតផ្ទាល់ខ្លួនរបស់អ្នកស្រី។ ដូច្នេះសំណួរបែបនេះមិនត្រូវបានអនុញ្ញាត ឲ្យសួរនៅក្នុងតុលាការនេះទេ។ បាទ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ព័ត៌មានដែលខ្ញុំសួរឲ្យសាក្សីបង្ហាញនោះ គឺថាជាការយល់ដឹងរបស់គាត់ ជាការផ្សព្វផ្សាយដែលគាត់បានឮ ហើយគាត់បានរៀបរាប់ ហើយខ្ញុំគ្រាន់តែសួរគាត់ថា តើគាត់យល់ពីខ្លឹមសារហ្នឹងដូចម្ដេច? ហើយខ្ញុំមិនសួរឲ្យគាត់បញ្ចេញយោបល់ទេ។ ហើយសូមឲ្យគាត់ពន្យល់ថា តើគាត់យល់ខ្លឹមសារហ្នឹងដូចម្ដេច នៅពេលដែលគាត់បានធ្វើការ នៅក្នុងក្រសួងឃោសនាការនៅកាលនោះបាទ។

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នៅពេលនុ៎ង នាងខ្ញុំយល់ថា--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន!

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:០២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនសមស្រប។ អង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ប្រសិនបើនៅចងចាំ ប្រសិនបើមិនចាំទេ សូមតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្ដងទៀត។

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នៅសំណួរលោកបានសួរនេះ នៅក្នុងខ្លឹមសារដែលនាងខ្ញុំបានឆ្លើយនៅលើការសម្ភាសនេះ ហើយសួរថា យល់យ៉ាងម៉េចនៅលើសំណួរនេះ? នាងខ្ញុំថា ពីសម័យនោះ គឺនាងខ្ញុំថា បើអប់រំទៅលើបញ្ហាហ្នឹង ខ្ញុំថាល្អ មានការជំរុញ កសាងប្រជាជន កសាងកម្លាំងនៅតាមជួរ។ ចាស នាងខ្ញុំយល់ថាអ៊ីចឹង។

[១៤:០៥:០៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅដល់ បាទ ការផ្សព្វផ្សាយជាក់លាក់មួយ ដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញលោកស្រី ពេលដែលគេសម្ភាស។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម លោកប្រធាន គឺឯកសារលេខ D200/6.3។ នេះជាសេចក្តីប្រកាសព័ត៌មានរបស់កម្មវិធីផ្សាយព័ត៌មានអន្តរជាតិរបស់វិទ្យុ គឺថ្ងៃទី១០ ឧសភា ឆ្នាំ១៩៧៨ ហើយគាត់បានពិភាក្សា -- សាក្សីបានពិភាក្សានៅពេលដែលគាត់ផ្តល់សម្ភាសទៅសហចៅក្រមស៊ើបអង្កេត។ សូមការអនុញ្ញាតដើម្បីបញ្ជូនឯកសារលើក្រដាសជូនទៅសាក្សី មុននឹងខ្ញុំសួរសំណួរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:០៧:៤៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកស្រី ស សៀក នេះជាឯកសារមួយក្នុងចំណោមឯកសារ ដែលលោកស្រីបានពិភាក្សាជាមួយ -- ហើយគេបាន អ្នកស៊ើបអង្កេតបានអានជូនលោកស្រីស្តាប់តាមខ្សែអាត់សំឡេង គឺផ្នែកដែលពាក់ព័ន្ធ ERN មិនមានជាភាសាបារាំងទេ រួចខ្មែរ 00340543 ហើយជាភាសាអង់គ្លេស 00294785។ មានចំណងជើងថា "កម្មវិធីអប់រំកម្ពុជា ស្ថានភាពការពារប្រទេសកម្ពុជាប្រជាធិបតេយ្យចាប់ពីមេ -- ខែមេសា ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៨"។ មានកថាខណ្ឌមួយក្នុងឯកសារនេះ ដែល

អ្នកស៊ើបអង្កេតបានអានជូនលោកស្រីស្តាប់ ដែលខ្ញុំចង់ពិភាក្សាជាមួយលោកស្រីនៅពេលនេះដោយសង្ខេប។ ខ្លឹមសារនេះគឺនៅខ្មែរ ERN 00340547, អង់គ្លេស ERN 00294786។ ចំពោះអ្នកដែលមានមើលភាសាអង់គ្លេសនោះកថាខណ្ឌ គឺកថាខណ្ឌលេខ៥។

[១៤:០៩:៤៧]

ខ្ញុំនឹងអានជូនលោកស្រីស្តាប់ផ្នែកនៃខ្លឹមសារនេះ។ "យើងព្យាយាមកម្ទេចខ្មាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយដើម្បីរក្សាកងកម្លាំងរបស់យើងឲ្យបានជាអតិបរមា យើងមានចំនួនតិចហើយយើងត្រូវវាយកម្លាំងដែលច្រើនជាង។ ដូច្នេះយើងត្រូវតែរក្សាកម្លាំងរបស់យើងឲ្យបានជាអតិបរមា និងព្យាយាមសម្លាប់ខ្មាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ នេះគឺជាពាក្យស្លោករបស់យើង គិតតាមចំនួនយើងម្នាក់ត្រូវសម្លាប់វៀតណាម ៣០នាក់។ បើសិនជាយើងអាចអនុវត្តផែនការនោះបាន យើងពិតជាឈ្នះ"។ លោកស្រី ស សៀក តើលោកស្រីនៅចាំដែរឬទេ តើធ្លាប់បានឮការប្រកាសបែបនេះទេ តាមវិទ្យុនោះ ដែលថាខ្មែរម្នាក់ត្រូវ -- អាចនឹងសម្លាប់វៀតណាមបាន ៣០នាក់នោះ?

**ឆ៖** ចាស នៅក្នុងសំណួរនេះនាងខ្ញុំដូចស្រពេចស្រពិល ហើយក៏ចាំមិនបានលោក។

[១៤:១១:១០]

**ស៖** អ៊ីចឹង យើងមើលចម្លើយរបស់លោកស្រីម្តងទៀតនៅក្នុងកំណត់ហេតុនោះ។ ឯកសារ E3/379 ខ្មែរ ERN គឺ 00294813, បារាំង ERN 00385290, អង់គ្លេស ERN 00323336។ ដោយបានអានកថាខណ្ឌមួយនោះ មានសំណួរសួរទៅលោកគឺសហចៅ -- គឺអ្នកស៊ើបអង្កេតបានសួរទៅលោកស្រី៖ "តើកថាខណ្ឌនេះជាមាគ៌ាបក្សទេ? ឆ្លើយ៖ ពិតហើយជាមាគ៌ា។ តាមអ្វីដែលខ្ញុំយល់ ពាក្យថា យើង យោងទៅរកមេដឹកនាំជាន់ខ្ពស់នៅក្នុងនោះគឺថាមាន ប៉ុល ពត ហើយនិងអនុរបស់គាត់។ សំណួរ៖ តើពាក្យថា កម្ទេច មានន័យថាដូចម្តេច? តាមទស្សនៈរបស់លោកស្រី តើពាក្យឃោសនាបែបនេះមានន័យដូចម្តេច? ឆ្លើយ៖ ពាក្យថា កម្ទេច គឺចំពោះមនុស្ស គឺមានន័យថា សម្លាប់ បើចំពោះសម្ភារៈ គឺ ការបំផ្លាញ"។ តើនេះជាចម្លើយត្រឹមត្រូវដែលលោកស្រីបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ ចំពោះកថាខណ្ឌដែលទើបដែលបានអានអម្បាញ់មិញនេះ?

[១៤:១២:៤៣]

**ឆ៖** ចាស នៅលើសំណួរនេះនាងខ្ញុំបានផ្តល់យោបល់ ប៉ុន្តែគ្រាន់ថាពេលនោះក្នុងការស្រពេចស្រពិលខ្លះ ប៉ុន្តែដោយមានការពិភាក្សាទៅក៏អាចបញ្ជាក់ទៅក្នុងត្រង់ហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានសូមអរគុណដែលបានឲ្យខ្ញុំមានយោបល់។ ខ្ញុំសោកស្ដាយណាស់ដែលបានកាត់ផ្ដាច់លោកសហព្រះរាជអាជ្ញា។ សម្រាប់យុត្តិធម៌ដល់សាក្សីនេះ ខ្ញុំសូមឲ្យរំឭកពីឃ្លាមុនមកមុន គឺឃ្លាដែលសហព្រះរាជអាជ្ញាទើបតែលើកឡើងអម្បាញ់មិញនេះ ពីព្រោះថានៅចំពោះមុខសហព្រះរាជអាជ្ញាគាត់ សូមទោស សហចៅក្រមស៊ើបអង្កេត គាត់និយាយច្បាស់ណាស់ គឺនៅទំព័រជាភាសាបារាំង ERN 00385209 គឺ -- ហើយនៅថ្ងៃនេះគឺគេអត់អានទេឃ្លានេះ។ ដូច្នេះ សូមឲ្យបញ្ជាក់ឃ្លានេះឡើងវិញឲ្យបានច្បាស់លោកសហព្រះរាជអាជ្ញា។

[១៤:១៤:១៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនគិតថានេះគឺជាការជំទាស់ត្រឹមត្រូវទេ មេធាវីគឺអាចនឹងលើកឡើងពីបញ្ហានេះនៅពេលដែលគាត់សួរសំណួរសាក្សី។ ហើយចម្លើយនេះគឺវែង ហើយខ្ញុំស្រង់យកតែពាក្យដែលសាក្សីដែលអាចគាត់បញ្ជាក់បាន។ រីឯខ្លឹមសារផ្សេងទៀតដែលមេធាវីបានយោងទៅនោះគឺថា នៅកន្លែងផ្សេងគាត់អាចប្រើផ្នែកនេះសម្រាប់ការសួររបស់គាត់ពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាបន្ត -- តំណាងសហព្រះរាជអាជ្ញាបន្តសំណួរទៅមុខទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវផ្នែកនេះ ពិភាក្សាអំពីជម្លោះជាមួយវៀតណាម ហើយមានទិដ្ឋភាពផ្សេងទៀតនិយាយនៅក្នុងការផ្សាយវិទ្យុហ្នឹង គឺទាក់ទងទៅនឹងវៀតណាមដែរ លោកស្រីបានពិភាក្សា ជាមួយសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងការផ្សព្វផ្សាយចម្លើយសារភាពរបស់អ្នកទោសវៀតណាម។ លោកស្រី ស សៀក តើលោកស្រីចាំទេ អំពីការផ្សព្វផ្សាយទាំងនោះ ដែលនិយាយអំពីចម្លើយសារភាពរបស់

អ្នកទោសវៀតណាមនោះ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកខ្ញុំសូមឆ្លើយនឹងសំណួរហ្នឹង គឺថា នាងខ្ញុំបាននៅចាំខ្លះ ឧទាហរណ៍ថានៅសមរភូមិមួយៗ ដែលក្រោយពីការវ៉ៃតប់គ្នាហើយនេះ យើងចាប់បានជាឈ្លើយ យើងថាឈ្លើយចុះ ឬមួយក៏កងទ័ពវៀតណាមសារភាពអីហ្នឹង គឺយើងបានសម្ភាសហើយយកមកចាក់ផ្សាយជាសំឡេងដើមរបស់ជននោះ។

**ស៖** តើៗគេយកចម្លើយសារភាពនេះទៅប្រកាសញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចាស មិនមែនចេះតែមានរាល់ថ្ងៃទេ ឧទាហរណ៍ថា សមរភូមិណាដែលយើងធ្វើការវ៉ៃតប់គ្នាទៅ ហើយបានម្តងម្កាលអីចឹង។ ការចាប់ខ្លួនបានហ្នឹង សម្ភាសក៏សម្ភាសនៅតាមសមរភូមិដែរ ហើយយកខ្សែអាត់នោះចាក់ដើម្បីផ្សព្វផ្សាយ ហើយក្នុងខ្លឹមសារដែលសម្ភាសហ្នឹង ឧទាហរណ៍ដាក់ស្តែងថា ជននោះឈ្មោះអី? កើតនៅថ្ងៃណា ឆ្នាំណា ខែណា? ស្រុកកំណើតនៅឯណា? ហើយមកសមរភូមិនោះប៉ុន្មានដងហើយ? ចាស មានប៉ុណ្ណឹង សង្ខេបលោក។

[១៤:១៧:២៣]

**ស៖** នៅក្នុងការផ្សាយតាមវិទ្យុនេះ បាទខ្ញុំសូមទោស ខ្ញុំសូមថយមួយជំហានទៅក្រោយវិញ។ តើលោកស្រីដឹងទេ អ្នកណាជាអ្នកសម្រេចថាត្រូវយកចម្លើយសារភាពនេះទៅចាក់ផ្សាយតាមវិទ្យុនោះ?

**ឆ៖** ចាស ខ្ញុំអត់ដឹងដែរ។

**ស៖** តើការផ្សព្វផ្សាយនេះ គេធ្លាប់បានពិភាក្សានៅក្នុងក្រសួងឃោសនាការទេ មុននឹងគេចាក់ផ្សាយទាក់ទងទៅនឹងការងារប្រចាំថ្ងៃរបស់គេនោះ?

**ឆ៖** ចាស នាងខ្ញុំក៏អត់ដឹងដែរនៅក្នុងខ្លឹមសារទាំងនេះ។ ពីព្រោះផ្នែកទៅលើនាងខ្ញុំមានការងារផ្សេង។ គ្រាន់តែដឹង ឮ ហើយនិងស្គាល់ការងារហ្នឹងខ្លះៗនៅក្នុងមន្ទីរនោះ។

**ស៖** តើលោកស្រីដឹងអំពីគោលបំណងនៃការចាក់ផ្សាយចម្លើយសារភាពហ្នឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំមិនយល់ដែរ។

[១៤:១៩:០៥]

**ស៖** ឥឡូវនេះត្រឡប់ទៅរកឯកសារ E3/379 ជាចម្លើយរបស់លោកស្រី ទៅសហចៅក្រមស៊ើបអង្កេត ERN ដែលពាក់ព័ន្ធគឺ ខ្មែរ 00294813, បារាំង 00385210, ហើយអង់គ្លេស

00323337។ សំណួរ៖ នៅក្នុងវង់ក្រចក "អ្នកស៊ើបអង្កេតឃោបល់សាក្សី -- យើងបានជូនសាក្សីពិនិត្យមើលចម្លើយសារភាព គឺរបាយការណ៍ ចម្លើយសារភាពរបស់ ជូលី ជាភ្នាក់ងារសម្ងាត់ដែលផ្សាយនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ហើយចម្លើយសារភាពរបស់អនុសេនីទោអតីតវៀតណាមខាងត្បូង ថាច់ វ៉ាន់ដុង ដែលត្រូវបានចាប់ខ្លួននៅខេត្តព្រៃវែងថ្ងៃទី១៤ ខែកុម្ភៈ ផ្សព្វផ្សាយនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨"។ ពេលនោះ គេសួរថា "តើនេះជាឧទាហរណ៍ដែលលោកស្រីបានលើកឡើងនៅក្នុងពីមុនមកមែនឬទេក្នុងចម្លើយសារភាព?" ចម្លើយ៖ "ចាស គេធ្វើបែបនេះមែនដើម្បីឲ្យប្រជាជនដឹងថា ទាហានវៀតណាមពិតជាត្រូវបានគេចាប់ខ្លួនមែន"។ តើលោកស្រីចាំទេថាបានឆ្លើយបែបនេះទៅអ្នកស៊ើបអង្កេតថា គោលបំណងនៃចាក់ផ្សាយនេះគឺដើម្បីឲ្យអ្នកដទៃដឹងថា គេពិតជាចាប់បានទាហានវៀតណាមនោះមែន?

[១៤:២០:៥៩]

**ស៖** ចាស ក្នុងខ្លឹមសារហ្នឹងខ្ញុំភ្លេចហើយ ប្រហែលជាថៅ -- អ្នកសង្កេតការអាចអាននៅលើខ្លឹមសារហ្នឹងឲ្យនាងខ្ញុំស្តាប់ ឬមួយយ៉ាងម៉េចទេ ក៏ប៉ុន្តែគ្រាន់ក្នុងនេះនាងខ្ញុំបានបញ្ជាក់ថា អ៊ីចឹងមែនក្នុងការចាប់បានឈ្លើយសឹកយួនអ៊ីចឹងមក យើងនឹងសម្ភាស និងចាក់ផ្សាយ។

**ស៖** សូមអរគុណ។ ឥឡូវនេះនៅពេលដែលគេចាក់ផ្សាយនោះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ថាដែលយើងអាចឮសំឡេងដើមរបស់អ្នកឈ្លើយសឹក ឬក៏អ្នកជនរងគ្រោះនោះនិយាយនោះ?

**ឆ៖** សូមម្តងទៀតលោក។

**ស៖** តើយើងអាចស្តាប់ឮសំឡេងរបស់អ្នកទោសដែលអ្នកនោះសារភាព ប្រហែលជាគេអាចស្តាប់ឮសំឡេងអ្នកសារភាពជាភាសាវៀតណាមហ្នឹងដែរឬទេ?

**ឆ៖** ចាស នៅក្នុងសំណួរនេះបើសិនជាថាបងប្អូនណាដែលបានស្តាប់វិទ្យុ ក៏អាចនឹងឮ ពេលដែលបានសម្ភាស តែគ្រាន់ថាស្តាប់ជាភាសា -- បានស្តាប់បានចាស ហើយសំឡេងដើមមែន។

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកស្រីបំភ្លឺបញ្ហាមួយ។ ថាតើគេរៀបចំខ្សែអាត់សំឡេងហ្នឹងដូចម្តេច? ពីព្រោះខ្ញុំគិតថាមិនសូវច្បាស់នៅក្នុងចម្លើយ ដែលលោកស្រីឆ្លើយកាលពីមុនទៅអ្នកស៊ើបអង្កេតនោះ។ តើលោកស្រីអាចបញ្ជាក់បានទេថា តើអ្នកណាជាអ្នកថតខ្សែអាត់សំឡេងហ្នឹងមុននឹងបញ្ជូនទៅឲ្យក្រសួងការ -- ក្រសួងឃោសនាការដើម្បីផ្សាយហ្នឹង?

[១៤:២៣:៤០]

**ឆ៖** ចាស តាមនាងខ្ញុំនៅចងចាំ ហើយនិងបានដឹងខ្លះៗថាឧទាហរណ៍ថា នៅសមរភូមិ ក ឬខ អ៊ីចឹង យើងចាប់បានឆ្លើយសឹកអ៊ីចឹង គេមានក្រុមម្នាក់ពីរនាក់ដើម្បីចុះទៅសម្ភាស ហើយនិងថតយកសំឡេងដើមហ្នឹងមក។ តែគ្រាន់ថាខ្ញុំមិនបានស្គាល់ នេះគ្រាន់ជាដឹង ជាទម្រង់អ៊ីចឹង។

**ស៖** តាមដែលលោកស្រីចាំ តើមានអ្នកណាម្នាក់នៅក្រសួងឃោសនាការទៅជួយក្នុងការថតខ្សែអាត់សំឡេងនៃការសម្ភាសន៍នុងដែរឬទេ?

**ឆ៖** ចាស អត់បានចាំឈ្មោះផងលោក។

**ស៖** ក្រៅពីឈ្មោះ តើមានអ្នកណាម្នាក់ពីក្រសួងឃោសនាការទៅធ្វើការងារនោះដែរឬទេ?

**ឆ៖** ចាស នៅក្នុងសំណួរនេះ ឧទាហរណ៍ថា មានមិនបានបកជាភាសាខ្មែរ បើមានចម្លើយឆ្លើយមកជាភាសាវៀតណាមអ៊ីចឹង មានថីបក មានឈ្មោះ អ៊ំវៃ តែគាត់ស្លាប់បាត់ហើយ ប្រុស។

**ស៖** តើលោកស្រីបានពិភាក្សាជាមួយគាត់ ឬជាមួយអ្នកបកប្រែផ្សេងទៀតទេនៅពេលដែលពួកគាត់ទៅ។ ទៅជួយក្នុងការសម្ភាស ឬសួរចម្លើយនោះ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ ពីព្រោះអីការងារខុសគ្នា។

**ស៖** តើលោកស្រីដឹងទេ តើទាហានទាំងអស់នោះ ដែលគេ ក្រោយពីគេផ្តល់ចម្លើយថតខ្សែអាត់រួចហើយ គេយកទៅធ្វើអ្វី ឬក៏អ្នកនោះជួបវាសនាដូចម្តេចដែរ?

**ឆ៖** ចាសនៅក្នុងចំណុចនេះ នាងខ្ញុំមិនសន្និដ្ឋានថាម៉េចទេ ក៏ប៉ុន្តែគ្រាន់ថា បើនិយាយពីការរើតប់គឺចង់ឈ្នះរៀងខ្លួន។ តែគ្រាន់ថា ខ្ញុំបានសម្ភាស និងនិយាយជាមួយនឹងខាងសង្កេតការណ៍ថា ដូចជាមិនអាចបញ្ជូនទៅស្រុកវិញទេ។ ចង់និយាយថា មិនដឹងយ៉ាងម៉េច អត់ដឹងដែរ។

[១៤:២៦:៤៣]

**ស៖** សូមអរគុណ។ ឥឡូវនេះចូលទៅដល់ប្រធានបទមួយទៀត នៅពេលដែល ៗសហព្រះរាជអាជ្ញាជាតិសួរទៅលោកស្រីម្សិលមិញទាក់ទងទៅនឹងការផ្សព្វផ្សាយ ហើយលោកស្រីបាននិយាយថា គេសុំ -- គេប្រាប់ថា ឲ្យមានការប្រុងប្រយ័ត្ន ឲ្យប្រជាជនប្រុងប្រយ័ត្នអំពីការផ្សព្វផ្សាយនេះ ថាតើលោកស្រីយល់ដូចម្តេច ដែលថាគេប្រកាសឲ្យមានការប្រុងប្រយ័ត្ននោះ?

**ឆ៖** ចាស នៅត្រង់នេះ នាងខ្ញុំភ្លេចបាត់ហើយ មិនដឹងជាប្រុងប្រយ័ត្ននៅលើចំណុចអី។

**ស៖** គឺពាក្យដែលលោកស្រីបានប្រើម្សិលមិញ ខ្ញុំអាចមើលឃ្លានៅក្នុងប្រតិចារឹក គឺថាក្នុងអង់គ្លេស គឺថា គឺគេសុំឲ្យប្រជាជន ឬក៏មនុស្សម្នានោះ គឺថាមានការប្រុងប្រយ័ត្ន។ តើលោកស្រីនៅចាំទេ

ពាក្យនេះ?

**ឆ៖** ដូចមិនបានចាំទេលោក។ ភ្លេចអស់។

**ស៖** ដោយសារពេលខ្ញុំខ្លី ខ្ញុំនឹងតទៅមុខទៀត។ ខ្ញុំសូមអនុញ្ញាតពិភាក្សាជាមួយលោកស្រីការផ្សាយមួយ។ ឥឡូវនេះ លោកស្រីបាននិយាយថា បើសិនជាខ្ញុំសង្ខេបភស្តុតាងលោកស្រីមិនត្រូវកែខ្ញុំផង “លោក ហ៊ូ នឹម ធ្វើដំណើរជាមួយ ទីវ អុល ទៅភ្នំពេញ គឺប្រហាក់ប្រហែលជាមួយក្រុមលោកស្រីដែរ។ ហើយថាក្នុងពេលនោះ ដើម្បីដំណើរហ្នឹងគឺថា ពេលនោះក៏មានវិទ្យុផ្សាយចល័តហ្នឹង ក៏ផ្សាយដែរ”។ លោកស្រីក៏បាននិយាយដែលថា “លោក ហ៊ូ នឹម បន្តធ្វើការជាប្រធាន ចាប់ពីពេលនោះមកគឺពេលឆ្នាំ១៩៧៥ រហូតមកដល់ពេលមួយក្នុងឆ្នាំ១៩៧៦”។ តើខ្ញុំចាំ ឬក៏ខ្ញុំសង្ខេបបែបហ្នឹង ត្រឹមត្រូវតាមចម្លើយរបស់លោកស្រីដែរឬទេ? ត្រង់រឿងហេតុត្រង់នេះ?

**ឆ៖** ចាស ពិតមែនលោក។ ព្រោះអី ចូលភ្នំពេញហើយ លោក ហ៊ូ នឹម ក៏គាត់នៅគ្រប់គ្រងនៅនឹងក្រសួងហ្នឹងរហូតទាល់ឆ្នាំ៧៦ បានគាត់ចេញពីអង្គភាពហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងបង្ហាញជូនលោកស្រីអំពីប្រតិចារឹកនៃការផ្សព្វផ្សាយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមការអនុញ្ញាតពីលោកប្រធាន។ នេះជាអត្ថបទដែលប្រតិចារឹកពីផ្សព្វផ្សាយនោះ ជាអកុសលគឺថាមានតែភាសាអង់គ្លេសទេ ប៉ុន្តែអនុលោមតាមការណែនាំរបស់តុលាការម្សិលមិញនោះ ខ្ញុំអាចនឹងអានឃ្លាដែលពាក់ព័ន្ធជូនសាក្សី ដើម្បីឲ្យគាត់ស្តាប់។ ឯកសារនោះ គឺ E3/118។ នេះគឺជាកម្មវិធីផ្សាយព័ត៌មានអន្តរជាតិ ខែមេសា ឆ្នាំ១៩៧៥ ហើយផ្នែកនេះ គឺស្ថិតនៅលើអង់គ្លេស ERN 00166996។

សូមការអនុញ្ញាតពីលោកប្រធាន ហើយសូមអនុញ្ញាតសេចក្តីដកស្រង់ខ្លី ដែលទាក់ទងអំពី ហ៊ូ នឹម ដើម្បីឲ្យដឹងថាតើសាក្សីគាត់អាចចាំអំពីខ្លឹមសារនៃការផ្សព្វផ្សាយនេះដែរឬទេ?

[១៤:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមអានបន្ត ដោយសារតែអ្នកបកប្រែនឹងមានការលំបាក បកប្រែដំណាលគ្នាផងដែរ។ លោកស្រី ស សៀក ឯកសារនេះ -- សូមកែ គឺថាការបក -- ការផ្សព្វផ្សាយនេះ គេចាប់ផ្តើមដូចខាង

ក្រោមនេះ៖ “គឺថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ គឺផ្សាយនៅម៉ោង ២២:០៥ ដែលចាប់ផ្តើមឡើងដោយគឺសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺថារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ ហ៊ូ នឹម”។ អត្ថបទនោះ មួយផ្នែកទេ គឺដើម្បីឲ្យលោកស្រីនៅចាំទេ ថាលោក ហ៊ូ នឹម បាននិយាយអ៊ីចឹងដែរ ឬអត់?

[១៤:៣២:២៩]

“សូមគោរព ចំពោះព្រះសង្ឃគ្រប់ព្រះអង្គ។ សូមគោរព បងប្អូនជនរួមជាតិ ហើយសូមគោរពកងប្រដាប់អាវុធជាទីស្រឡាញ់ទាំងពីរភេទ ហើយនិងកម្មាភិបាលទាំងអស់”។ ប្រយោគបន្ទាប់និយាយថា “បន្ទាប់ពីការវាយប្រយុទ្ធដ៏ខ្លាំងក្លា ៥ឆ្នាំ ១ខែ ក្នុងកាលៈទេសៈដ៏លំបាក ដោយស្មារតីលះបង់ដ៏ខ្ពង់ខ្ពស់ ហើយនិងវីរបុរសបដិវត្តន៍ វីរភាពបដិវត្តន៍ ចក្រពត្តិអាមេរិក ដែលឃោរឃៅ និងយង់ឃ្នងនោះ។ ហើយយើងបានផ្តួលនូវក្រុម ហ្វាស៊ីស ដែលពុករលួយ ហើយនិងបនក្បត់ លន់ នល់, សិរីមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, សូស្តែន ហ្វែណង់ដេស។ កងទ័ពបដិវត្តន៍កម្ពុជា ហើយនិងប្រជាជនកមក្ពុជាដ៏មហិមា បានរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥”។ តើលោកស្រីនៅចាំខ្លឹមសារនៃការផ្សាយដែលចេញពីលោក ហ៊ូ នឹម នៅកាលនោះទេ នូវខ្លឹមសារដែលខ្ញុំអានអំមិញនេះ អម្បាញ់មិញនេះ?

[១៤:៣៤:០១]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នាងខ្ញុំមិនបានចាំ ហើយក៏មិនបានស្តាប់ផង។

**ស៖** នៅពេលដែលលោកស្រីប្រាប់ពីម្សិលមិញនោះ គឺថាប្រកាសអំពីការបរាជ័យរបស់ចក្រពត្តិ តើខុសពីអ្វីដែលខ្ញុំអាននេះ ឬក៏មានខ្លឹមសារប្រហាក់ប្រហែលនេះ?

**ឆ៖** ចាស ពេលដែលរំដោះទីក្រុងភ្នំពេញ គឺខ្លឹមសារ គឺប្រហាក់ប្រហែល ហើយនិងស្រដៀងហ្នឹង។ តែគ្រាន់ថា មិនដឹងលោកណាជាអ្នកនិយាយ គ្រាន់តែខ្លឹមសារ គឺវាស្របទៅតាមហ្នឹង។

**ស៖** ចង់ដឹងថា តើលោកស្រីចាំអំពីខ្លឹមសារនេះ ខ្ញុំសូមអានឯកសារមួយទៀត គឺថាតើវាស៊ីចង្វាក់គ្នាទៅនឹងអ្វីដែលលោកស្រីបានឮដែរឬក៏អត់?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានយើងខ្ញុំនៅតែចង់ឲ្យបង្ហាញឯកសារ E3/118 ERN ជាភាសាអង់គ្លេស 0016

6994 នេះគឺជាផ្សាយសំឡេងដែលខ្ញុំបានបញ្ជាក់ថា ផ្សាយនៅម៉ោងម្ភៃមួយដប់ប្រាំនាទី។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកស្រី សៀក ខ្ញុំសូមអានសារនេះ ខ្លីជូនលោកស្រី ថាតើលោកស្រីជួយជម្រាបផង លោកស្រីចាំទេនូវសារមួយនេះ? សារនេះគឺចាប់ផ្ដើម "សេចក្ដីថ្លែងការណ៍អបអរសាទរដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ហើយនិងកងទ័ពបដិវត្តន៍កម្ពុជា ដែលមានអគ្គបញ្ជា -- មេបញ្ជាការលោក ខៀវ សំផន ជូនចំពោះកងទ័ពបដិវត្តន៍កម្ពុជា ក៏ដូចប្រជាជនកម្ពុជាទាំងអស់"។ ហើយសារមួយទៀតដែលខ្ញុំចង់អានជូនលោកស្រីផងនោះ គឺថា ដែលលើកឡើងដោយខាងក្រោម៖ "នេះគឺជាជ័យជម្នះរបស់ប្រទេស និងប្រជាជនដ៏ក្លាហានរបស់យើង។ គឺជាជោគជ័យមួយដ៏ក្លាហាន អង់អាចក្លាហាន និងកងទ័ពស្នេហាជាតិកម្ពុជា ដើម្បីវាយប្រយុទ្ធជាមួយនឹងសត្រូវនៅគ្រប់សមរភូមិទាំងអស់ ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ ហើយបានពង្រឹងប្រជាជនចេញពីតំបន់ដែលយើងបានគ្រប់គ្រង។ យើងបានកម្ទេចខ្មាំងយ៉ាងជោគជ័យ និងយ៉ាងស្វាហាប់ ហើយនិងបានធ្វើឱ្យកងទ័ព ក៏ដូចសេដ្ឋកិច្ច និងអ្វីៗទាំងអស់កកស្ទះរហូតដល់យើងចូលទៅដល់ -- ឈានដល់ចំណុចមួយដែលថា ខ្មាំងនោះមិនអាចងើបរួច។ ចុងបញ្ចប់គឺថា ចុងបញ្ចប់គឺខ្មាំងបានបាត់បង់កម្លាំង បានរហូតដល់ខ្សោះឈាម ចប់ដង្ហើមងាប់"។ លោកស្រីនៅចាំត្រង់ចំណុចនេះទេ?

[១៤:៣៧:៥២]

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ការពិតគឺនាងខ្ញុំមិនបានស្ដាប់ ហើយក៏មិនបានតាមដាន ខ្ញុំមិនចាំទាល់តែសោះលោក។ ប្រសិនជាបានស្ដាប់អាចបានចាំខ្លះ។

**ស៖** ឥឡូវសូមចូលទៅអ្វីដែលលោកស្រីបានស្ដាប់ លោកស្រីនិយាយថា ការផ្សាយនេះនិយាយអំពីការទទួលជ័យជម្នះពីពួកចក្រពត្តិនិយម ជាជាងការនិយាយអំពីការរំដោះនោះ។ តើៗអ្វីខ្លះដែលលោកស្រីចាំនោះ? តើពួកចក្រពត្តិស្អីដែលខាងទាហានខ្មែរក្រហមនុ៎ងបានៗយកជ័យជម្នះនុ៎ង?

**ឆ៖** ចាស កាលពីសម័យនោះ យើងរំដោះពី លន់ នល់ ហើយចក្រពត្តិហ្នឹង គឺអង្គាល់នុ៎ងគឺថាចក្រពត្តិអាមេរិកាំងហ្នឹងហើយលោក។

[១៤:៣៩:០៩]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំចង់សួរលោកស្រីនូវការផ្សាយនេះ ចុងក្រោយតែមួយទៀតទេ នេះគឺឯកសារ E3/201 វាជាប្រតិចារឹក វាជាសេចក្ដីសង្ខេបនៃការផ្សាយព័ត៌មានពិភពលោក។ ផ្នែក

ពាក់ព័ន្ធនៃឯកសារនេះ គឺចាប់ផ្ដើមនៅ ERN ជាភាសាខ្មែរ 00292808, ERN ជាភាសាបារាំង 00612165, ERN អង់គ្លេស 00419512។

**លោក អាប់ឌុលឡាក់ ថាវីក៖**

ដោយសារថានេះជាប្រតិចារឹកលោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីអានមួយឃ្លា ឬក៏ពីរឃ្លា ដើម្បីចង់ដឹងថាតើសាក្សីគាត់ចាំ ឬក៏មិនចាំ? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៤:៤០:៣៨]

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកស្រី ស សៀក ទំព័រដែលខ្ញុំបានដកស្រង់ជូនទៅមេធាវីការពារក្ដីនោះ គឺមានចំណងជើងថា សាររបស់ ខៀវ សំផន នៅក្នុងទិវាអបអរសាទរនៅម៉ោងម្ភៃ -- សេវាផ្សព្វផ្សាយភ្នំពេញម៉ោងម្ភៃបី នៅថ្ងៃទី១៥ មេសា ១៩៧៧ ដែលមានចំណងជើងថា "អត្ថបទដែលថ្លែងដោយ ខៀវ សំផន ដែលជាប្រធានគណៈប្រធានរដ្ឋនៅទិវាខួបជ័យ -- មហាជ័យជម្នះ ១៧ មេសា និងជាថ្ងៃកំណើតរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា"។ លោកស្រី ស សៀក តើលោកស្រីចាំសុន្ទរកថាដែលថ្លែងដោយមេដឹកនាំប្រទេស ដូចដែលខ្ញុំជម្រាបជូនលោកស្រីនេះដែរឬទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោក ខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង។ ការពិតបើមានការណែនាំថា នៅផ្នែក ឬមួយក៏តាមមន្ទីរនានាឲ្យរង់ចាំស្ដាប់សេចក្ដីថ្លែងការណ៍របស់ផងលោក ខៀវ សំផន អាចនឹងនាងខ្ញុំបានចាំខ្លះ។ តែនេះខ្ញុំអត់ដឹង ហើយអត់ចាំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកនូវបន្ទប់សម្រាករបស់ -- សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញសាក្សីរូបនេះត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកស្រី សៀក ខ្ញុំសូមសួរសំណួរមួយទៀត អំពីសុន្ទរកថាដែលយើងបាននិយាយពីខាងដើមនេះ។ ខ្ញុំគិតថាលោកស្រីបាននិយាយថា បើសិនថាគេណែនាំឲ្យទៅស្តាប់ គឺថាយើងត្រូវតែទៅ ប៉ុន្តែលោកស្រីមិនចាំខ្លឹមសារនោះទេ។ ប៉ុន្តែខ្ញុំសួរថា តើគេបានណែនាំឲ្យចូលរួម រួមជាមួយកម្មាភិបាលនៅក្រសួងឃោសនាការទាំងអស់គ្នា ដើម្បីទៅស្តាប់សុន្ទរកថារបស់ថ្នាក់ដឹកនាំដែរឬទេ?

[១៥:០២:៥០]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកនៅក្នុងសំណួរនេះ ខ្ញុំបានឆ្លើយថា បើសិនជាមុននឹងសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ក្រោយពីពេលរំដោះហើយនោះឲ្យបងប្អូនទាំងអស់ប្រមូលគ្នាទៅស្តាប់ អាចនឹងបានទៅស្តាប់ ហើយខ្ញុំអាននឹងបានចងចាំខ្លះ ប៉ុន្តែនោះអត់បានស្តាប់ ហើយក៏អត់បានចាប់អារម្មណ៍អីទាំងអស់។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** នេះគឺមុនរំដោះ ចុះក្រោយថ្ងៃរំដោះយ៉ាងដូចម្តេចដែរ?

**ឆ៖** ផ្តល់សំណួរម្តងទៀត លោកចង់សួរថាម៉េចលោក?

**ស៖** ខ្ញុំគិតថាលោកស្រីនិយាយថា មុនពេលថ្ងៃរំដោះគឺគេបានណែនាំឲ្យប្រជាជនទៅចូលរួម

ស្តាប់សុន្ទរកថារបស់ ខៀវ សំផន ហើយប្រជាជនក៏ទៅ ហើយលោកស្រីក៏បានទៅដែរ។ ចុះថាលោកស្រីបាន -- បន្ទាប់ពីរំដោះវិញ តើកម្មាភិបាលគេណែនាំកម្មាភិបាល ឬប្រជាជនឲ្យទៅស្តាប់សុន្ទរកថារបស់លោក ខៀវ សំផន ដែរឬទេ?

[១៥:០៤:៥៥]

**ផ៖** ចាស ខ្ញុំអត់បានដឹងផង។

**ស៖** តើចម្លើយរបស់លោកស្រី ថាលោកស្រីមិនដឹង ឬក៏ៗមិនដែលឮ ឬក៏មិនដែលបានទៅស្តាប់សុន្ទរកថារបស់លោក ខៀវ សំផន?

**ផ៖** ចាស នាងខ្ញុំមិនបានទៅស្តាប់ ហើយក៏គ្មានការណែនាំឲ្យទៅស្តាប់ផង អត់បានចាប់អារម្មណ៍អីទាំងអស់ខ្លួននាងខ្ញុំ។

**ស៖** ម្សិលមិញលោកស្រីបាននិយាយថាៗ លោកស្រីបានឃើញលោក ខៀវ សំផន នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ តើលោកស្រីធ្លាប់ឃើញសមាជិកក្រុមគ្រួសារគាត់ទេ គឺប្រពន្ធគាត់ និងកូនគាត់នៅពេលណាមួយក្រោយពីខែមេសា ឆ្នាំ១៩៧៥នោះ?

**ផ៖** ចាស ពេលនុំងឃើញតែគាត់មកនៅកន្លែងឃោសនាការ ២-៣ថ្ងៃ ហើយគាត់ចេញទៅវិញរហូត ខ្ញុំមិនដែលបានឃើញផង។

[១៥:០៦:៣៤]

**ស៖** លោកស្រីថា បានឃើញគាត់ ២-៣ថ្ងៃនៅក្រសួងឃោសនាការ។ ២-៣ថ្ងៃ ថាតើនៅខែមេសា ឆ្នាំ១៩៧៥ ឬក៏ក្រោយពីនោះមក?

**ផ៖** ចាស ១៩៧៥ ហ្នឹងហើយ ក្រោយពីនាងខ្ញុំមកពីស្កុតមក មកដល់ឃោសនាការហ្នឹង។ ហើយក្រោយពីគាត់ចេញទៅ មិនដឹងជាគាត់នៅកន្លែងណា រហូតខ្ញុំមិនដែលឃើញគាត់ផង។ លែងឃើញគាត់ មិនដឹងគាត់ទៅនៅកន្លែងណា?

**ស៖** នៅពេលដែលលោកស្រីបានឃើញគាត់ ២-៣ថ្ងៃនោះ ថាតើគាត់ធ្វើអ្វីដែរ លោក ខៀវ សំផន? ហើយតើលោកស្រីឃើញគាត់នៅកន្លែងណា ដោយច្បាស់លាស់នោះ?

**ផ៖** ចាស គាត់មកនៅឃោសនាការហ្នឹង នៅលំហមួយ ហើយគាត់នៅសម្រាកនៅហ្នឹងគ្រែដែក នៅនឹងកន្លែងក្មេងៗ កន្លែងសិល្បៈដែរ ព្រោះអត់មានកន្លែង។ អង្កាល់ណោះអត់មានស្គាល់ទីកន្លែងណាដែលចូលមក អីចឹងហាក់បីដូចជាថារួមគ្នានៅហ្នឹងជាមួយគាត់ហ្នឹង ១ថ្ងៃ ២ថ្ងៃហ្នឹង។

[១៥:០៧:៥៦]

**ស៖** តើទីកន្លែងហ្នឹងនៅកន្លែងណា? ជាកន្លែងនៅក្រសួងឃោសនាការ ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឬក៏កន្លែងណាមួយផ្សេងពីនេះ?

**ឆ៖** ចាស កន្លែងឃោសនាការ មកដល់កន្លែងឃោសនាការហ្នឹងតែម្ដង។

**ស៖** នៅពេលដែលលោកស្រីឆ្លើយម្សិលមិញ គឺថាលោកមិនដែលបានឃើញលោក ខៀវ សំផន ទេ ក្រោយពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ តើត្រឹមត្រូវទាំងស្រុងអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំស្ដាប់ដូចអត់ទាន់។

**ស៖** សំណួរខ្ញុំឱ្យ -- ចង់ឱ្យលោកស្រីបញ្ជាក់ថា តើលោកស្រីបានឃើញលោក ខៀវ សំផន នៅក្រសួងឃោសនាការដែរឬទេ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មកនោះ?

**ឆ៖** ចាស ក្រោយពេលរំដោះហ្នឹងបានឃើញគាត់។ ពេលរំដោះហើយ។

[១៥:០៩:១៨]

**ស៖** ក្រោយពីគាត់សម្រាកនៅគ្រែដេកនោះ -- គ្រែដែកនោះ តើលោកស្រីបានឃើញគាត់ធ្វើអ្វី បានជួបជាមួយអ្នកណាផ្សេងទៀតទេ គាត់នោះ?

**ឆ៖** ចាស គាត់សម្រាកនៅហ្នឹង មិនមានជួបអីជាមួយពីណាផង សម្រាកធម្មតា ប្រាជ្ញព្រោកជាមួយបងប្អូនធម្មតា។ ពីព្រោះអីទើបតែទៅដល់ភ្លាមអ៊ីចឹង គាត់ក៏មិនដឹងដើរទៅណា អីឯណា។ នៅហ្នឹង១យប់ ២យប់ ហើយគាត់ចេញទៅបាត់ទៅ ក៏ខ្ញុំមិនដឹងថាគាត់ទៅកន្លែងណា។

**ស៖** តើលោកស្រីបាននិយាយជាមួយគាត់ទេ?

**ឆ៖** អត់បាននិយាយទេ។

**ស៖** ត្រឡប់ទៅសំណួរដែលខ្ញុំបានសួរលោកស្រីពីខាងដើម។ តើលោកស្រីធ្លាប់បាននិយាយទៅរក ឬក៏ជួបជាមួយសមាជិកណាមួយនៃក្រុមគ្រួសាររបស់គាត់ដែរឬទេ?

**ឆ៖** ក្រោយៗ មកបាននាងខ្ញុំស្គាល់។ ពីមុនមក ខ្ញុំអត់ស្គាល់ផង។

**ស៖** តើកាលបរិច្ឆេទក្រោយមកហ្នឹង ដែលបានស្គាល់ហ្នឹងពេលណា?

**ឆ៖** ចាស ស្គាល់គាត់ជាក់លាក់មែនទែននៅឆ្នាំចិតសិប -- ពី៧៩មក។

**ស៖** ឥឡូវនេះ តើលោកស្រីចាំដែរឬទេអំពី ដែលថាប្ដីរបស់លោកស្រី តាសុត ហ្នឹងត្រូវបានសម្លាសដោយអ្នកស៊ើបអង្កេតរបស់តុលាការនេះ។

**ឆ៖** ចាស ខ្ញុំចាំ គ្រួសារខ្ញុំបានសម្ភាសជាមួយក្រុមការងាររបស់តុលាការមែន។

[១៥:១១:៤៣]

**ស៖** តាមដែលខ្ញុំយល់ត្រឹមត្រូវនោះ ថាតើប្ដីរបស់លោកស្រីស្លាប់ ហើយឬក៏នៅរស់ទេ ឈ្មោះ សុត ថា នោះ?

**ឆ៖** ចាស គាត់ស្លាប់ហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ដើម្បីកំណត់ត្រាតុលាការ ខ្ញុំមានឯកសារ -- ខ្ញុំចង់យោងទៅឯកសារ ដែលខ្ញុំបានបញ្ជាក់ពីបទសម្ភាសន៍ដែលខ្ញុំបានពិភាក្សាជាមួយលោកស្រី ស សៀក រកឃើញនៅក្នុង ឯកសារ E3/464, ឯកសារ D369/22។ ខ្ញុំចង់ពិភាក្សាជាមួយលោកស្រី សៀក ដោយសង្ខេបទេ គឺឱកាសមួយដែលអ្នកស៊ើបអង្កេតទៅជួបជាមួយអតីតស្វាមីរបស់លោកស្រីនោះ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី។

[១៥:១២:៥៥]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកស្រីចៅក្រម ហើយនិងភាគី និងសាធារណជន។ ឥឡូវនេះ សហព្រះរាជអាជ្ញា គាត់ពិនិត្យមើលនូវអ្វីដែលស្ថិតនៅក្នុងចម្លើយនៅចំណុចនេះ។ ខ្ញុំសូម ជំទាស់ក្នុងការប្រើផ្នែកណាមួយនៃចម្លើយនេះ ហើយយើងបានបង្ហាញថា សាក្សីនោះគាត់បានស្លាប់ ហើយ។ គាត់មិនអាចមកតទល់បានទេ។ បើសិនជាចង់ដាក់ចម្លើយរបស់គាត់មុខអង្គជំនុំជម្រះ ដើម្បី សួរហ្នឹង គឺត្រូវមានវិធីសាស្ត្រឲ្យត្រឹមត្រូវ។ ប៉ុន្តែទាក់ទងនឹងខ្លឹមសារសួរសំណួរអ្វីនៅក្នុងចម្លើយនេះ ហើយបញ្ជាក់អ្វីៗដែលបានសួរ ហើយនិងសូមជំទាស់បើសហព្រះរាជអាជ្ញានឹងត្រូវសួរនោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះហើយ ជាអ្វីដែលតែងតែមានការជំទាស់។

[១៥:១៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំនឹងនិយាយដោយខ្លីទេ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ខ្ញុំគាំទ្រទាំងស្រុងទៅនឹងការជំទាស់របស់លោកមេធាវី កាណាវាស។

**លោក អាប់ឌុលឡាក់ ថារីក៖**

បញ្ហាទាក់ទងទៅនឹងការជំទាស់ជាមុននេះ ដោយសារគាត់មិនទាន់ឮសំណួរទេ ប៉ុន្តែការជំទាស់នោះមិនត្រឹមត្រូវ។ ហើយដើម្បីកំណត់ត្រាតុលាការ ខ្ញុំមិនមានចេតនាថា នឹងធ្វើដូចអ្វីដែលមេធាវីជំទាស់នោះទេ។ ហើយខ្ញុំនឹងសួរលោកស្រី សៀក អំពីខ្លឹមសាររបស់ចម្លើយរបស់ប្តីរបស់គាត់ទេ។ ខ្ញុំនឹងសួរបញ្ហាទាក់ទងទៅនឹងព័ត៌មានផ្សេងទេ។ បាទ ហើយភាពពាក់ព័ន្ធនឹងបានឃើញនៅពេលដែលខ្ញុំសួរពិភាក្សាជាមួយគាត់នោះឯង។

[១៥:១៤:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៥:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់ខាងមេធាវីការពារក្តី សមស្របចំពោះការដែលប៉ុនប៉ងរបស់លោកតំណាងសហព្រះរាជអាជ្ញា ក្នុងការប្រើប្រាស់ឯកសារក្នុងការតាំងឯកសារអ្នកដែលស្លាប់ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។ ប៉ុន្តែបញ្ហាដែលលោកតំណាងសហព្រះរាជអាជ្ញា គាត់មានបំណងនិងរបៀបក្នុងការសួរនេះ ផ្សេងពីការគិត និងសេចក្តីជំទាស់របស់មេធាវីការពារក្តី។ ដូច្នេះ អង្គជំនុំជម្រះបដិសេធនូវការជំទាស់នេះ ហើយអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញា អាចតាំងសំណួរដេញដោលបាន។ ហើយរង់ចាំស្តាប់ការសួរដេញដោលជាក់ច្បាស់សិនមើល ថាតើវាមានបញ្ហាអ្វីខ្លះ ដែលពាក់ព័ន្ធនឹងឯកសារដែលគាត់ចង្អុលបង្ហាញអម្បាញ់មិញនេះ?

[១៥:១៦:៥៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ឯកសារដែលខ្ញុំចង់ពិភាក្សាជាមួយសាក្សីដោយសង្ខេបនោះ គឺ D369/40 គឺជា គឺនៅក្នុងឯកសារ -- ជាបញ្ជីឯកសាររបស់យើងខ្ញុំដែលដាក់ចំពោះមុខអង្គជំនុំជម្រះ។ ភាពពាក់ព័ន្ធនៃឯកសារនេះ គឺមានសេចក្តីសង្ខេបដែលសាក្សីរូបនេះ បាននិយាយជូនទៅសហចៅក្រម

ស៊ើបអង្កេត ហើយជាកំណត់ហេតុសួរចម្លើយរបស់សហចៅក្រមស៊ើបអង្កេត។ ហើយខ្ញុំសូមជម្រាបតុលាការថា ចំណុចនេះវាមានការពាក់ព័ន្ធ ដោយសារមានពាក្យដែលសាក្សីរូបនេះបាននិយាយជូនទៅសហចៅក្រមស៊ើបអង្កេត គឺមិនមែនជាចម្លើយរបស់ប្តីគាត់ដែលបានខូចទៅហើយនោះទេ។ ហើយសូមជម្រាបថាអាចនឹងជាជំនួយ ហើយយើងអាចនឹងអានផ្នែកដែលពាក់ព័ន្ធនេះ ហើយពេលនោះ លោកស្រីចៅក្រមអាចនឹងសម្រេច ថាតើអនុញ្ញាត ឬក៏មិនអនុញ្ញាតឲ្យខ្ញុំសួរសំណួរតទៅទៀតនោះ?

[១៥:១៨:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ មុននឹងអាចជំទាស់ ខ្ញុំសូមឲ្យគេប្រាប់ខ្ញុំឲ្យបានច្បាស់ ថាតើលោកសហព្រះរាជអាជ្ញាអាចប្រាប់បានទេថា ឯកសារនេះ ត្រូវបានសាក្សីឃើញរួចមកហើយ ហើយមានសាក្សីចុះហត្ថលេខានៅលើឯកសារនេះទេ?

[១៥:១៨:៤៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ដូចដែលមេធាវីអាចដឹងហើយ គឺថារបាយការណ៍របស់សហចៅក្រមស៊ើបអង្កេតនោះ គឺជាកំណត់ត្រាផ្លូវការរបស់តុលាការហើយ មិនឲ្យសាក្សីចុះហត្ថលេខាទេ ប៉ុន្តែពេលខ្លះ គឺមានព័ត៌មានដែលពាក់ព័ន្ធទៅនឹងពេលដែលប្រមូលភស្តុតាងនោះ។ ហើយយើងខ្ញុំបានដាក់ស្នើដើម្បីឲ្យតុលាការទទួលស្គាល់ ហើយឯកសារនេះ នៅក្នុងតាមវិធាន៨០ ហើយវាស្ថិតនៅក្នុងបញ្ជីឯកសាររបស់យើងខ្ញុំ។ ហើយខ្ញុំមិនយល់ថា តើបញ្ហា ថាតើសាក្សីចុះហត្ថលេខា មិនចុះហត្ថលេខានោះ? នេះជាឯកសារផ្លូវការរបស់តុលាការ ប្រសិនមានអ្វីពាក់ព័ន្ធ ថាតើឯកសារនេះអាចប្រើ មិនប្រើនោះ គឺថាមិនទាក់ទងថា ឯកសារត្រូវបានមានចុះហត្ថលេខាដោយសាក្សីនោះទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមការបញ្ជាក់នេះ លោកប្រធាន ពីព្រោះថាប្រសិនបើខ្ញុំស្តាប់ច្បាស់នោះ គឺថាសហព្រះរាជអាជ្ញា គាត់មានសិទ្ធិក្នុងការប្រើប្រាស់ឯកសារតាមតែគាត់ចង់បាន ដើម្បីយកមកសួរនាំ។ ដូច្នេះ ការសួរទៅលើខ្លឹមសារនៃឯកសារនេះ ទៅកាន់សាក្សីរូបនោះ ត្រូវតែគិតទៅដល់អ្វី -- ចំណុចទាំងនេះផងដែរ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ដោយបានស្ដាប់មេធាវីការពារក្ដីបានលើកដំណើរមួយ ហើយខ្ញុំត្រូវអានសេចក្ដីសង្ខេបនៅក្នុងផ្នែកនេះ គឺវាមានភាពពាក់ព័ន្ធ គឺជាពាក្យរបស់គាត់ដូចដែលអ្នកស៊ើបអង្កេតបានបញ្ជាក់ ហើយដើម្បីឱ្យសាក្សីបញ្ជាក់ថា តើគាត់នឹកឃើញថា គាត់បាននិយាយអ៊ីចឹងដែរឬទេ ទៅ -- នៅពេលនោះនុះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៥:២០:៥១]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ សូមអនុញ្ញាតមន្ត្រីតុលាការប្រគល់ឯកសារជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

កុំអាលសិន! កុំអាលទាន់បញ្ជូនឯកសារ។

សាក្សីលោកស្រី ស សៀក យើងសង្កេតមើលលោកស្រីទៅទំនងជាមិនចេះអក្សរទេ។ មើលឯកសារហ្នឹងដូចជាមិនចេះអក្សរទេ។ ឥឡូវយើងសួរសាជាថ្មី ពីព្រោះយើងអាចមានការយល់ខុសដោយសារនៅក្នុងកំណត់ហេតុ ដែលលោកស្រីបានឆ្លើយចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតថាប្រកាសថា លោកស្រីចេះអក្សរ ចេះអាន ចេះសរសេរ យល់បានភាសាខ្មែរ។ ប៉ុន្តែនៅអាកប្បកិរិយានៅចំពោះមុខយើងនេះ ដូចជាទំនងជាមិនចេះអក្សរទេ។ យើងបារម្ភថា ការយកឯកសារជាអក្សរទៅឱ្យលោកស្រីអាននេះ វាគ្រាន់តែជានីតិវិធី វាអត់មានប្រយោជន៍អ្វីទេ។ សំណួរសួរថា តើលោកស្រីដែលធ្លាប់បានចូលរៀនទេ? ហើយរៀនបានកម្រិតណាដែរអក្សរខ្មែរនោះ?

[១៥:២២:០២]

**លោកស្រី ស សៀក៖**

ចាស លោកប្រធាន ខ្ញុំរៀនអក្ខរកម្មពីដើមឡើយ អត់មានបានថ្នាក់រៀនផង។ ហើយអានអីបានតិចតួចបំផុត ចាស។ ព្យាង្គតម្រួតមើលមិនរួច រៀនដោយខ្លួនឯងតិចតួចពីសម័យនោះ។

**ប្រធានអង្គជំនុំ៖**

ពេលដែលដាក់ឯកសារជូនទៅតាំងពីម្សិលមិញរហូតដល់ពីម៉ោងតាំងពីពេលបាយ ម៉ោងមួយ

រសៀល មួយកន្លះចាប់ផ្តើមដំណើរការសវនាការហ្នឹង លោកស្រីអានឯកសារដែលគេដាក់ជូនទៅឱ្យលោកស្រីពិនិត្យហ្នឹងបានទេ?

**លោកស្រី ស សៀក៖**

ចាស បានទាល់តែយូរ។ មើលបានតិចៗ។

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារស្ថានភាពសាក្សីមិនចេះអក្សរទេ ការដែលធ្វើនីតិវិធីរបៀបបង្ហាញឯកសារនោះសម្រាប់អ្នកចេះអក្សរ បើចេះអានទៅអាចដំណើរការបាន។ គាត់អត់ចេះអានផង អង្គជំនុំជម្រះមិនចាំបាច់អនុញ្ញាតឱ្យផ្តល់ឯកសារជាលាយលក្ខណ៍អក្សរជូនទៅសាក្សីទេ។

[១៥:២៣:២៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមអរគុណចំពោះការណែនាំនេះបាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឃ្លាដែលខ្ញុំចង់អានជូនលោកស្រីសាក្សីស្តាប់នោះ គឺខ្លីទេ។ គឺស្ថិតនៅខ្មែរ ERN 00498437, បារាំង ERN 00498434 ហើយនិង 00492721 លោកស្រី សៀក ឯកសារហ្នឹងគឺចុះថ្ងៃទី -- សូមទោស គឺថាការប្រជុំនោះ ដែលឯកសារនេះរៀបរាប់នោះ គឺធ្វើឡើងនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១០។ បាទ គឺថាប្រហែលជាមុនពេលដែលគ្រួសារលោកស្រីបានស្លាប់ទៅនោះ។ របាយ-ការណ៍នេះ និយាយថា ពីព្រោះថា មិនអាចតបានហ្នឹងដោយគ្រួសារលោកស្រីហ្នឹងមានជំងឺ ផ្នែកដែលខ្ញុំអានជូនស្តាប់នេះ គឺដូចខាងក្រោមនេះ៖ សូមដកស្រង់ “ព័ត៌មានដែលគាត់បានផ្តល់នៅក្នុងការសម្ភាសចុងក្រោយដល់យើង គឺជាព័ត៌មានទូទៅ ហើយសង្ខេប ប៉ុន្តែគាត់បានដឹងច្រើនជាងអ្វីដែលគាត់បន្ថែម។ ក្នុងពេលនោះ គឺប្រពន្ធរបស់គាត់បានចូលរួម គឺថាមួយសប្តាហ៍មុនដែលយើងបង្ហាញខ្លួននេះ គឺប្រពន្ធ -- ប្រពន្ធ ខៀវ សំផន បានទៅជួប សុត ថា ដែលសួរគាត់ តើលោកបានចាំនៅឆ្នាំណាទេ នៅពេលដែលលោក ខៀវ សំផន ទៅព្រែកក្តាមនោះ?” លោកស្រីតើលោកស្រីបានចាំទេ នៅពេលដែល លោកចាំថាអ្នកស៊ើបអង្កេតបានជួបទេ ហើយគាត់បានពិភាក្សាពីករណីមួយដែលថាប្រពន្ធលោក ខៀវ សំផន បានផ្ទះលោកស្រីបាននិយាយពីបញ្ហាដូចខ្ញុំអានហ្នឹងទេ?

[១៥:២៥:៣០]

**ឆ៖** ចាស លោកខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង។ ដំបូងឡើយលោកប្រធានសួរថា ខ្ញុំស្គាល់លោក ខៀវ សំផន ទេពីអង្កាល់នោះ អង្កាល់នោះខ្ញុំអត់ស្គាល់ទេ តែក្រោយ៧៩នេះគឺខ្ញុំស្គាល់។ តែក្នុងគាត់ទៅហ្នឹង គាត់ទៅមែន ទៅផ្ទះខ្ញុំនឹងដើម្បីស្វែងទៅរកជួបគ្រួសារខ្ញុំ ដើម្បីចង់សួរជាក់លាក់ថា លោក ខៀវ សំផន គាត់ដែលទៅព្រៃកក្កាមទេ ហើយនិងដែលមកឃោសនាការទេ? ចាស កន្លែងហ្នឹងខ្ញុំចាំ។ ទៅមែនគាត់បានទៅ ហើយគាត់ក៏បានណែនាំដែរថា បើខាងក្រុមការងារស៊ើបអង្កេតសួរអី មានអីឆ្លើយទៅមិនបាច់លាក់ទេ ឆ្លើយឲ្យអស់ទៅ គាត់បានជម្រាបទៅខាងគ្រួសារខ្ញុំអ៊ីចឹង។ តែគាត់ទៅហ្នឹងមិនបានជួបទេ គ្រួសារខ្ញុំគាត់មកប្រចាំការនៅពោធិ៍សាត់នេះ។ គាត់បានព្រោកប្រាជ្ញគ្នាលេងនៅត្រឹមហ្នឹង តែខ្ញុំបានជួបគាត់ តែមិនដឹងថាថ្ងៃណា ខែណាទេ ចាស។

[១៥:២៦:៤០]

**ស៖** តើនេះជាពេលម្តងគត់ ដែលលោកស្រីបានជួបជាមួយគាត់ ហើយបានពិភាក្សាដែលថាអ្វីដែលប្តីលោកស្រីដឹង និងលោកស្រីដឹងអំពីលោក ខៀវ សំផន។ តើជួបតែម្តងហ្នឹងទេឬ?

**ឆ៖** ចាស ខ្ញុំជួបប្រពន្ធគាត់ ដែលគាត់ទៅហ្នឹង តែខ្ញុំស្គាល់គាត់ ពីរយៈ៧៩មកខ្ញុំស្គាល់គាត់ហើយ។ តែនេះគាត់ទៅ គាត់ស្វែងរកគ្រួសារខ្ញុំទេ តែអត់បានជួបទេ។ តែក្រោយមកក្រុមការងារដែលបានចុះទៅចង់សួមសម្ភាសដល់គ្រួសារខ្ញុំ គាត់សម្ភាសមិនកើត ដោយគាត់អង្គុយមិនបាន គាត់មានជំងឺបេះដូងរីក ចាស។

**ស៖** តើលោកស្រី ឬក៏ប្តីរបស់លោកស្រីបានសួរគាត់ថា ហេតុអ្វីបានជាគាត់ចាប់អារម្មណ៍ ថាតើ សុត ថា បានឃើញលោក ខៀវ សំផន នៅព្រៃកក្កាម ឬក៏នៅក្រសួងឃោសនាការនោះ?

**ឆ៖** ចាស ប្រពន្ធគាត់ទៅសួរហ្នឹង ដោយសារគាត់ថា លោក ខៀវ សំផន គាត់ភ្លេច ភ្លេចអស់ហើយ ទៅមែន ឬអត់ គាត់ទៅបញ្ជាក់ត្រង់ហ្នឹង។

[១៥:២៨:១៩]

**ស៖** តាមបើខ្ញុំយល់ត្រឹមត្រូវចម្លើយរបស់លោកស្រីនោះ គាត់បានប្រាប់លោកស្រីថា ឲ្យប្រាប់ការពិតទាំងអស់ទៅ អ្វីដែលលោកស្រី ឬក៏ប្តីរបស់លោកស្រីដឹងនោះ។ តើអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** ចាស ពិតមែន បើមានការសួរពីក្រុមសង្កេតការណ៍។ គាត់បានជម្រាបអ៊ីចឹងមែន។

**ស៖** សំណួរចុងក្រោយមួយអំពីចំណុចនេះ ហើយដែលលោកស្រីបានឆ្លើយពីម្សិលមិញ ហើយនិងថ្ងៃនេះ។ តើលោកស្រីដឹងប្រាប់តុលាការអ្វីៗទាំងអស់ ដែលលោកស្រីបានដឹង បានឮ ហើយពីការពិត

ទាំងអស់អំពីលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** ចាស ខ្ញុំថ្ងៃនេះខ្ញុំសម្ដែងការស្មោះ ខ្ញុំស្គាល់ត្រឹមណា ឃើញគាត់កន្លែងត្រឹមណា ខ្ញុំបានរាយរាប់ជម្រាបលោក លោកស្រីទាំងអស់។

**ស៖** ខ្ញុំនឹងចូលទៅដល់បរិបទថ្មីមួយទៀត ប្រធានថ្មីមួយទៀតលោកស្រី សៀក។ នៅក្នុងបទសម្ភាសន៍របស់លោកស្រី គេសួរលោកស្រីអំពីការប្រជុំដែលធ្វើឡើងនៅក្រសួងឃោនាការ ហើយនិងការប្រជុំដែលលោកស្រីបានចូលរួម។ តើលោកស្រីអាចប្រាប់ខ្ញុំបានទេ តើការប្រជុំនោះជាការប្រជុំអ្វីខ្លះដែលលោកស្រីបានចូលរួមចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៧ នោះ?

**ឆ៖** ចាស ក្នុងការប្រជុំ ចង់និយាយថា ពីសម័យនោះគ្រាន់តែថារៀបជាក្រុម ប្រជុំពីជីវភាពអីហ្នឹងនាងខ្ញុំដឹង ហើយនិងចែកការងារ ត្រូវការសម្ដែង ឬត្រូវការថតរឿងអី ឬក៏ថតចម្រៀងអី តែការងារអ្វីៗទៀតនាងខ្ញុំដូចមិនបានចងចាំទេលោក។

**ស៖** តើអ្នកណាជាអ្នកដឹកនាំអង្គប្រជុំដែលលោកស្រីបានចូលរួមហ្នឹង?

**ឆ៖** ចាស នៅតាមក្រុម ឧទាហរណ៍ថាមួយក្រុមមានគ្នា ១២នាក់អីចឹង គឺ ក្រុមក្មេងៗពួកខ្ញុំហ្នឹង គឺក្មេងៗហ្នឹង ទៅប្រជុំជីវភាពអីចឹង។ ជាក់ស្ដែងដូចថា កន្លះខែម្ដង ឬមួយក៏មួយអាទិត្យម្ដងអីខ្ញុំមិនសូវចាំជាក់លាក់ដែរ វាយូរឆ្នាំពេកហើយ។

[១៥:៣១:៤៣]

**ស៖** តើលោកស្រីមានបានចូលរួម នៅក្នុងកិច្ចប្រជុំស្វ័យទិតៀនណាមួយទេ នៅក្រសួងឃោនាការនុ៎ង?

**ឆ៖** ចាស នៅក្នុងក្រុមបាន ជីវភាព។ ពេលប្រជុំ ប្រធានបើកអង្គប្រជុំទៅ ហើយម្នាក់ៗសម្ដែងនូវការខ្វះខាតខ្លួនឯង រួចហើយដាក់ខ្លួនដើម្បីឲ្យសមូហភាពនៅក្នុងក្រុមហ្នឹងជួយកសាង ចំណុចណាដែលយើងមិនបានលើកឡើងបង្ហាញដល់សមូហភាព ចាស។ ដោយសភាពរាបសា មិនខឹងសម្បាគ្នាអីទាំងអស់។ ជួយគ្នាម្ដងៗម្នាក់ៗអីចឹង ឬក៏ជំរុញការងារអីចឹងចាស។

**ស៖** នៅក្នុងអង្គប្រជុំដែលលោកស្រីបានចូលរួមនោះ តើវាជាកិច្ចប្រជុំជួបជុំស្វ័យទិតៀន ឬក៏កិច្ចប្រជុំបែបផ្សេង ហើយថាតើលោក ហ៊ូ នឹម បានចូលរួមដែរទេ?

**ឆ៖** អត់ទេលោក ក្មេងៗក្រុមគ្នាឯង តាមក្រុម។ ប្រជុំទិតៀនកសាងគ្នាហ្នឹង លើកពីកំហុសរៀងខ្លួន ដូចខ្ញុំបានបញ្ជាក់ខាងលើអីចឹង។ ឲ្យជួយគ្នាម្ដងម្នាក់ កែលម្អនៃការខ្វះខាតតិចតួចជាធ្វើការងារ

មិនទាន់ម៉ោងពេលវេលាអី ឬមួយក៏ពេលហូបចុកអីយឺតយ៉ាវអី ចុងភៅរង់ចាំអ៊ីចឹងលោក។

[១៥:៣៣:៣៣]

**ស៖** ចុះកិច្ចប្រជុំដែលនិយាយអំពីខ្លឹមសារនៃការផ្សព្វផ្សាយតាមវិទ្យុ តើលោកស្រីបានធ្លាប់ចូលរួមជាមួយលោក ហ៊ូ នឹម ដើម្បីនិយាយអំពីការផ្សាយវិទ្យុនេះដែរឬទេ?

**ឆ៖** ចាស ទាក់ទងនឹងសំណួរនេះនៅថ្ងៃមួយនោះ គេថាប្រជុំរួមផ្នែកការងារដែលថា សិល្បៈអ៊ីចឹងមួយផ្នែក ហើយអ្នកនិពន្ធអីខ្លះទៅ ឬមួយអ្នកបច្ចេកទេសអ៊ីចឹង ប្រជុំរួមគ្នា ដើម្បីដកពិសោធន៍ដែលម្ដង។ ចាស មានលោក ហ៊ូ នឹម ចូលរួមដែរ ប្រជុំពេលព្រឹក។ តែការប្រជុំហ្នឹងមិនបានយូរដែរ ដោយសារលោករវល់ អ៊ីចឹងទៅក៏រំសាយគ្នាវិញ។ ប្រជុំពិសោធនការងារថ្ងៃណោះ ចាស ខ្ញុំហ្នឹង ខ្ញុំចាំ។

**ស៖** តើនេះគឺជាពេលតែមួយទេដែលលោកស្រីបានចូលរួមប្រជុំជាមួយនឹងគាត់ហ្នឹង ជាមួយលោក ហ៊ូ នឹម ហ្នឹង?

**ឆ៖** ចាស ពេលតែម្ដងហ្នឹង ខ្ញុំមិនដែលបានប្រជុំជាមួយគាត់ផង ទើបថ្ងៃនោះឯងបានប្រជុំដកពិសោធន៍ កែលម្អក្មេងៗ។ ចង់និយាយថា របាំអីវាមិនឯកភាពគ្នាអី ធ្វើជើងធ្វើដៃអី វាមិនឯកភាពគ្នាអ៊ីចឹងលោក បានផ្ដល់មតិជួយកែលម្អអ៊ីចឹង។

**ស៖** លោកស្រីបាននិយាយថា កិច្ចប្រជុំហ្នឹងខ្លីទេ ដោយសារតែគាត់រវល់ គាត់ក៏ចាកចេញទៅ។ តើលោកស្រីដឹងថានៅពេលដែលមានការសន្ទនាគ្នាតាមទូរស័ព្ទហ្នឹងទៅ គាត់ក៏ចេញទៅហ្នឹង ដឹងថាគាត់ទៅណាទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងដែរ ប៉ុនគ្រាន់ថាឮសូរសំឡេងគាត់ថា គាត់ទៅឥឡូវហើយៗ អាចគាត់ចេញទៅធ្វើការ។ ប្រហែលជាទៅធ្វើការ តែមិនដឹងទិសដៅគាត់ទៅត្រង់ណាទេ ហើយក៏រំសាយពួកខ្ញុំឈប់សម្រាកសិនទៅ។

[១៥:៣៦:១០]

**ស៖** លោកស្រី ខ្ញុំសូមជូននូវសារមួយគឺថា បង្ហាញជូនលោកស្រី ខ្ញុំសូមអានជូនលោកស្រីតែម្ដង ដោយសារតែលោកស្រីអានមិនបានលឿន។ ឯកសារនេះ គឺជាឯកសារ E3/379 គឺជាកំណត់ហេតុស្ដាប់ចម្លើយដែលយើងបានមើលរួមមកហើយ។ ERN ពាក់ព័ន្ធនោះគឺជាភាសាខ្មែរ 00294809, ERN ជាភាសាបារាំង 00385205 ដល់ 06, អង់គ្លេស 0003233 -- អង់គ្លេសសូមកែតម្រូវ 00032333 (ស៊ីក)។ ខ្ញុំសូមអាន "សំណួរ៖ តើលោកស្រីដឹងថា គេចាប់ ហ៊ូ នឹម ដែរឬទេ? ខ្ញុំដឹងថា គេចាប់ ហ៊ូ នឹម

ពីព្រោះនៅពេលវេលាម៉ោងប្រាំបីព្រឹក មានការប្រជុំកែអត្ថបទសិល្បៈដឹកនាំដោយ ហ៊ូ នឹម ស្រាប់តែមានទូរស័ព្ទរោទ៍។ ហើយគាត់និយាយតបទូរស័ព្ទនោះថា បាទៗបង បាទបង ខ្ញុំទៅឥឡូវនេះហើយ។ ហើយគាត់បានប្រាប់សមាជិកថា ប្រសិនបើគាត់ទៅប្រជុំ បើឃើញឡានទៅខ្លួនឯងមានបង់ក្រមា ហើយស្បែកជើងពុំ។ នៅម៉ោងបី ឃើញមានឡានទាហានមកយកប្រពន្ធគាត់ទៀត"។ លោកស្រី ស សៀក តើលោកស្រីធ្វើម៉េចបានជាលោកស្រីដឹងថា គាត់ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ចាស នៅចំណុចនេះ គឺពីព្រោះអីលោក ហ៊ូ នឹម ថ្ងៃហ្នឹងមានទូរស័ព្ទរោទ៍មែន តែក៏គ្រាន់ថា គាត់ចេញទៅហ្នឹង គាត់ធ្វើដំណើរទៅហ្នឹង តាំងពីនោះមកមិនដែលឃើញមកទទួលខុសត្រូវពួកខ្ញុំវិញផង រហូតទល់សព្វថ្ងៃហ្នឹងក៏មិនដែលឃើញគាត់។ ហើយគាត់ទៅហ្នឹងយ៉ាងប្រញាប់ប្រញាល់មែនដោយមានទូរស័ព្ទហៅគាត់ហ្នឹង។ គាត់ទៅនោះ គាត់បើកឡានទៅខ្លួនឯង បង់កក្រមា ហើយនិងពាក់ស្បែកជើងពុំ។ គាត់ទៅខ្លួនឯងទេ មិនមានបងប្អូនណាមកយកគាត់ទេ។ ជាក់ស្តែងខ្ញុំឃើញមែន ជាក់លាក់នឹងភ្នែក។

ឯការសន្និដ្ឋានថា ចាប់នេះ ថ្ងៃដែលសម្អាសហ្នឹង សូមទោសទៅ ខ្ញុំដូចតវ៉ាបន្តិចចុះ ខ្ញុំមិនបានឆ្លើយថាចាប់ទេ ថាគាត់ទៅធ្វើការ។ គាត់សុំរំសាយការងារហ្នឹង សុំទៅធ្វើការ តែគ្រាន់ថាខាងសង្កេតការណ៍ គាត់អានឲ្យស្តាប់អ៊ីចឹង ខ្ញុំស្តាប់មិនទាន់ ដោយលឿនពេក ហើយក៏អត់បានកែវិញត្រង់ហ្នឹង។

[១៥:៣៩:២៣]

**ស៖** ខ្ញុំសូមចូលទៅនិយាយអំពីលោក ហ៊ូ នឹម នៅក្រសួងដទៃទៀត ខ្ញុំចង់សួរលោកស្រីអំពីមេដឹកនាំជាន់ខ្ពស់ដទៃទៀត ដែលលោកស្រីបានជម្រាបជូនអ្នកស៊ើបអង្កេត។ តើលោកស្រីមានដឹងថាជោគវាសនារបស់ កុយ ធួន យ៉ាងម៉េចដែរទេ? មានអ្វីកើតឡើងចំពោះគាត់ទេ?

**ឆ៖** ចាស តាំងពីនោះមក មកទល់ឥឡូវ ខ្ញុំមិនដឹងយ៉ាងម៉េចទេ។ ខ្ញុំអត់ដែលឃើញគាត់ដែរ។ គ្រាន់តែខ្ញុំស្គាល់គាត់ ស្គាល់ហ្នឹងតាមរយៈសិល្បៈភូមិភាគ ឧត្តរចាស់ហ្នឹង ហើយក្រុមសិល្បៈនាងខ្ញុំហ្នឹងបានរួមសហការគ្នាសម្តែងពេលទទួលភ្ញៀវ ឬមួយក៏សម្តែងនៅតាមជនបទអីម្តងម្កាលតែប៉ុណ្ណឹង។ ស្គាល់គាត់។ តែគ្រាន់តែថាក្រោយមកមានការផ្សព្វផ្សាយ ដូចថាលោកក្បត់អី អាហ្នឹងខ្ញុំមិនដឹងដែរ។ ប៉ុន្តែគ្រាន់ថាបានឮតាមៗគេ ជាក់ស្តែងឮមែន។ តែត្រង់គាត់ថា កំណត់ថាគាត់ស្លាប់ឬរស់? ខ្ញុំមិនដឹងដែរ។

**ស៖** លោកស្រី សៀក រហូតមកដល់ថ្ងៃនេះ លោកស្រីនៅ តើលោកស្រីនៅតែមិនដឹងថាមានអ្វី

កើតឡើងចំពោះ កុយ ធួន ទេឬ? តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ក្នុងចិត្តនាងខ្ញុំសន្និដ្ឋានថា ប្រហែលជាគាត់ស្លាប់ហើយ បានជាមិនឃើញ។

**ស៖** បន្ទាប់ពីគាត់បាត់ខ្លួនទៅនោះ តើមានអ្នកណាផ្សេងទៀត ឬក៏មានអ្នកណាផ្សេងធ្វើការនៅក្រុមសិល្បៈបាត់ខ្លួនដែរឬទេ?

**ឆ៖** ក្រោយមក គឺនៅក្រសួងនាងខ្ញុំក៏មានផ្លាស់ប្តូរមនុស្សជាក្មេងៗសិល្បៈអីខ្លះ ហើយបងៗប្រុសជាអ្នកចម្រៀង ឬក៏អ្នកអានវិទ្យុអីខ្លះ។ ការដកផ្លាស់ឲ្យទៅធ្វើស្រែនៅតាឡី, នៅជ័យដំ, នៅកន្ទួតអី។ តែខ្ញុំមិនស្គាល់មូលដ្ឋាននុ៎ងទេ គ្រាន់តែបានឮ ហើយនិងបានដឹងថា បងប្អូនចេញពីនុ៎ងទៅ ក៏បាត់ពីនាងខ្ញុំ ក៏ដឹងតែថាគេទៅកន្លែងផ្សេងហើយ គេដកចេញពីកន្លែងហ្នឹងហើយ។

[១៥:៤២:១៥]

**ស៖** តើលោកស្រីបានឃើញអ្នកដែលថា គេបានដកយកទៅហ្នឹងបានឃើញ ក្រោយៗមកទៀតបានជួបទេ?

**ឆ៖** ចាស ខ្ញុំអត់បានជួបទេ ព្រោះអីក្រោយមក ខ្ញុំឈប់នៅក្រសួងឃោសនាការហ្នឹងហើយខ្ញុំមកនៅមន្ទីររោងពុម្ព អត់មាន១ការទាក់ទងការងារអីទៀតទេ។ ហើយក្រោយមកទៀត ក៏នាងខ្ញុំ គេត្រូវដកមក ប-២០ ដីក្រហមនេះដែរ។ អ៊ីចឹងរឿង អ៎!សូមទោស រឿងសុខទុក្ខរបស់បងប្អូនដែលខ្ញុំធ្លាប់ស្គាល់ហ្នឹង ខ្ញុំអត់អាចបានដឹងទេលោក។

**ស៖** អ្នកណាប្រាប់លោកស្រីថា កុយ ធួន នេះជាភ្នាក់ងារ សេ.អ៊ី.អា?

**ឆ៖** ចាស ក្រោយពីដឹងថាលោក កុយ ធួន គេត្រូវដកហ្នឹងហើយ នៅមន្ទីរខ្ញុំហ្នឹង មានប្រធានខ្ញុំគឺឈ្មោះ សៅ។ អង្កាល់ណោះ ខ្ញុំមិនទាន់បានចេញទេ នៅហ្នឹងរួមគ្នានៅឡើយ។

**ស៖** សំណួរលោកស្រីបានជម្រាបជូនតុលាការថា កាលពីម្សិលមិញបានជម្រាបជូនតុលាការថានៅក្នុងឆ្នាំ១៩៧៧ និងរោងពុម្ព គឺថាបានដាក់បញ្ចូលគ្នា។ ហើយនៅពេលនោះ គឺ យុន យ៉ាត បានក្លាយទៅជាក្រសួងដែលបានប្រហាច់បញ្ចូលគ្នានេះ។ តើ យុន យ៉ាត នោះគាត់នៅតែដឹកនាំក្រសួងហ្នឹងរហូតដល់ឆ្នាំ១៩៧៩ ឬក៏យ៉ាងណាដែរ?

**ឆ៖** ចាស អង្កាល់ឆ្នាំ៧៧ នាងខ្ញុំនៅក្នុងក្រសួងឃោសនាអប់រំហ្នឹង ក្រសួងពីរហ្នឹង មន្ទីររោងពុម្ព ហើយនិងមន្ទីរឃោសនាការ គេប្រើពាក្យថា ក្រសួងឃោសនាអប់រំ។ ដូច្នេះឆ្នាំ៧៧ នាងខ្ញុំនៅហ្នឹងដល់ពេលឆ្នាំ -- ដើមឆ្នាំ៧៨ ហ្នឹងគេដកនាងខ្ញុំចេញពីហ្នឹងទៀតហើយ។ នាងខ្ញុំអត់បានដឹង។ ចាស ខ្ញុំទៅ

ឆ្ងាយពីភ្នំពេញហើយ ទៅនៅស្រុកស្ទឹងត្រង់ខាងជើង។

**ស៖** ក្រៅពីលោកស្រី យុន យ៉ាត តើលោកស្រីស្គាល់មេដឹកនាំជាន់ខ្ពស់ដទៃៗទៀត ដែលគ្រប់គ្រងក្រសួងព័ត៌មាន និងឃោសនាការនេះដែរឬទេ? សូមកែប្រែ គឺក្រសួងអប់រំនិងឃោសនាការនេះដែរឬទេ?

**ស៖** ចាស មុននឹងខ្ញុំចេញទៅហ្នឹង ខ្ញុំស្គាល់ឈ្មោះ តាឆយ មួយ ដែលខ្ញុំបានបញ្ជាក់លោកតាំងពីម្សិលមិញម្ល៉េះ នូវសំណួរហ្នឹង។

[១៥:៤៥:៥៤]

**ស៖** សូមអរគុណ។ និយាយអំពីការបាត់ខ្លួនមនុស្សពីក្រសួងឃោសនាការ ដោយសារតែទាំងនេះ ត្រូវបានគេដកខ្លួនចេញ។ ទី១ ហ៊ូ នឹម ហើយក្រោយមក លោកស្រីបានលើកឈ្មោះពីរបីនាក់ផ្សេងទៀតនោះ ហើយនិងប្រពន្ធគាត់ តើក្នុងចំណោមកម្មាភិបាលទាំងអស់ហ្នឹង តើលោកស្រីបានដឹងអំពីការចាកចេញរបស់កម្មាភិបាលណាដែរឬទេ?

**ឆ៖** ចាស លោក នៅពេលនុ៎ង មានតែលោក ហ៊ូ នឹម ហ្នឹងហើយ ហើយប្រពន្ធគាត់ ហើយនិងក្មេងៗស្រករៗខ្ញុំហ្នឹង។ ចាស ខ្ញុំដឹងតែប៉ុណ្ណឹង។ ក្មេងៗ ពូៗ បងៗខ្លះ ដូចខ្ញុំបានរៀបរាប់ពីខាងលើថា ចេញទៅធ្វើស្រែ ធ្វើអីហ្នឹង។

**ស៖** ហើយតើលោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែលដកអ្នកទាំងនោះចេញពីក្រសួងហ្នឹង?

**ឆ៖** ចាស ពេលដែលផ្លាស់ពួកខ្ញុំស្គាល់ៗហ្នឹង ចេញដោយអត់ឃើញមកវិញ មានការព្រួយបារម្ភភ័យព្រួយដែរ។ អត់ឃើញមកវិញ មិនដឹងថាទៅធ្វើស្រែនៅម្តុំណា អីម្តុំណា អីចឹងលោក។

[១៥:៤៧:៥៣]

**ស៖** លោកស្រី សៀក អ្នកណាជាអ្នកធ្វើសេចក្តីសម្រេចដកអ្នកទាំងនោះ ផ្លាស់ប្តូរអ្នកទាំងនោះចេញពីក្រសួងហ្នឹង?

**ឆ៖** ចាស ខ្ញុំអត់បានដឹង។

**ស៖** នៅពេលដែលពួកគាត់ចាកចេញទៅ តាមដែលលោកស្រីដឹងនោះ តើពួកគាត់ហ្នឹង ចេញធ្វើដំណើរចេញទៅដោយខ្លួនឯង ឬក៏មានគេយករថយន្តអីមកដឹកពួកគាត់?

**ឆ៖** ចាស មានរថយន្តមកយក។

**ស៖** តើនោះជារថយន្តរបស់ក្រសួងឃោសនាការ ឬក៏ជារថយន្តដែលត្រូវគ្រប់គ្រងកាន់កាប់ដោយអ្នកដទៃ ឬក៏ជារថយន្តដែលមកពីអង្គភាពផ្សេង?

[១៥:៤៩:០៥]

**ឆ៖** ភាគច្រើននៅក្នុងក្រសួងជូនទៅ។ រថយន្តក្រសួងខ្លួនឯងហ្នឹង ជូនទៅ។ រថយន្តហ្នឹង ច្រើនមកពីក្រសួងថ្មី មន្ទីរ យុន យ៉ាត។

**ស៖** នៅពេលដែលថាមានរថយន្តផ្សេង គឺរថយន្តដែលមិនមែនមក -- រថយន្តដែលមិនត្រឹមតែមកក្រសួងអប់រំ និងឃោសនាការទេ តើរថយន្តមកពីកន្លែងផ្សេងណាដែរអ៊ីចឹង?

**ឆ៖** ចាស ដូចមកយកប្រពន្ធលោក ហ៊ូ នឹម ខ្ញុំឃើញរថយន្តយោធា មកយក។ តែក្រោយមកៗមានតែក្នុងក្រសួងខ្លួនឯង ដែលជូនទៅ។

**ស៖** លោកបានជម្រាបជូនអង្គជំនុំជម្រះប៉ុន្មាននាទីមុននេះថា នៅពេលមួយនោះ លោកស្រីផ្ទាល់ត្រូវបានគេផ្លាស់ទៅវត្តបទុម តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាមានអ្វីកើតឡើង?

**ប្រធានអង្គជំនុំ៖**

កុំអាលៗនេះ មានបញ្ហា។ មន្ត្រីរដ្ឋបាលតុលាការមើលសាក្សី គាត់យ៉ាងម៉េច? គាត់មានបញ្ហាអី?

*(មីក្រូហ្វូនមិនដំណើរការ)*

[១៥:៥១:១៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ ហើយដោយសារមានបញ្ហារន្ធត់ខាងផ្លូវអារម្មណ៍របស់សាក្សី យើងមិនអាចបន្តដំណើរការសវនាការសម្រាប់ថ្ងៃនេះបានទេ។ អង្គជំនុំជម្រះសម្រេចលើកសវនាការសាកសួរដេញដោលសាក្សីរូបនេះទៅរសៀលថ្ងៃចន្ទ ទី២០ ខែសីហា ឆ្នាំ២០១២វិញ។

សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ គ្រាន់តែជាមតិយោបល់បន្តិចតែប៉ុណ្ណោះ ចំពោះសាក្សីប្រភេទដូចលោកស្រីនេះ គួរតែមានអ្នកខាងសុខភាពផ្លូវចិត្តមកអង្គុយជិតគាត់ពេលដែលគាត់ផ្តល់សក្ខីកម្ម លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ប៉ុន្តែគាត់បានផ្តល់សក្ខីកម្មល្អណាស់ប៉ុន្មាន១ថ្ងៃហើយ ដូចជាមិនទាន់មានបញ្ហាអីទេ។ ទើបអម្បាញ់មិញនេះដែលមានសំណួរពាក់ព័ន្ធជាមួយនឹងសហការីរបស់គាត់ដែលមានការបាត់ខ្លួនជាបន្តបន្ទាប់ទេ ទើបមានការរំជួលចិត្តនោះ។ អង្គជំនុំជម្រះនឹងពិនិត្យបញ្ហានេះ ជាក់ស្តែងនៅសប្តាហ៍ក្រោយ។

[១៥:៥២:៣៥]

បាទ ឥឡូវកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវ -- ក៏សមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២០ ខែសីហា ឆ្នាំ២០១២ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ នៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មលោក សួង ស៊ីគឿន ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ហើយនិងបន្តស្តាប់សក្ខីកម្មសាក្សី ស សៀក ដែលក្រុមមេធាវី -- ដោយតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមភាគីនិងសាធារណជនជ្រាប។

[១៥:៥៣:១៧]

លោកស្រី ស សៀក ឥឡូវនេះអង្គជំនុំជម្រះសម្រេចឈប់មុនពេលកំណត់បន្តិចទេ តែ១០មីនុតប៉ុណ្ណោះ ដោយសារបញ្ហាសម្ពាធផ្លូវអារម្មណ៍របស់លោកស្រី ប៉ុន្តែអង្គជំនុំជម្រះនៅត្រូវការស្តាប់សក្ខីកម្មរបស់លោកស្រីតទៅទៀតដែលត្រូវធ្វើនៅថ្ងៃចន្ទ ទី២០ ខែសីហា ឆ្នាំ២០១២ គឺដើមសប្តាហ៍ក្រោយ។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ សប្តាហ៍ក្រោយទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ -- អ៎! នៅៗ មកកាន់ទីកន្លែងរង់ចាំនៅបរិវេណនៃ អ.វ.ត.ក នេះវិញនៅថ្ងៃចន្ទ សប្តាហ៍ក្រោយ។ ហើយក៏សូមជម្រាបទៅខាងអង្គភាពគាំពារសាក្សី/អ្នកជំនាញផងដែរ អំពីស្ថានភាពអារម្មណ៍របស់គាត់នៅពេលនេះ ដើម្បីឲ្យមានការជួយជ្រោមជ្រែងគាត់ បើសិនជាមានយថាហេតុអ្វីនោះ គឺអាចរកគ្រូពេទ្យដើម្បីពិគ្រោះ និងពិនិត្យសុខភាពគាត់ផង។

[១៥:៥៤:៣៦]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី២០ ខែសីហា ឆ្នាំ២០១២ វេលាម៉ោងប្រាំបួនព្រឹក។ ហើយដោយឡែក គឺភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះ គឺ យើងនឹងបន្តការងារកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃស្អែក ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៥៥ នាទី)*